**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការសង្គ្រោះចំពោះការបំពានកិច្ចសន្យា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ក. **ហុំ ស្រីម៉ិច**

ក. **ប៉ូច លីនដា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ព្រុំ រិទ្ធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ហ៊ុំ ស្រីម៉ិច** និង **ម៉ូវ លីនដា** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ ឆ្នាំសិក្សា២០១៨ ដល់២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមថ្លែងអំណរគុណ និងសម្តែងនូវភាពកតញ្ញូយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

**លោកឪពុក អ្នកម្តាយ** ដែលលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាយើងខ្ញុំឱ្យធំដឹងក្តី ព្រមទាំងឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងទាំងផ្នែកស្មារតី ផ្នែកសេដ្ឋកិច្ច កម្លាំងកាយ កម្លាំងចិត្ត ផ្តល់ភាពកក់ក្តៅ ជាពិសេសផ្តល់ការអប់រំទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ជួយជំរុញតម្រង់ផ្លូវឱ្យកូនសមប្រកបឆ្ពោះទៅកាន់មាគ៌ាមួយដែលជោគជ័យ រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រកម្រិតឧត្តមសិក្សា។

**ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យទាំងអស់** នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការបណ្តុះបណ្តាល បង្ហាត់បង្រៀនដល់យើងខ្ញុំទាំងពីររហូតបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

ជាពិសេស **សាស្ត្រាចារ្យបណ្ឌិត ព្រុំ រិទ្ធី** ជាសាស្ត្រាចារ្យណែនាំ ដែលបានលះបង់អស់ពីកម្លាំងកាយចិត្ត និងពេលវេលាផ្ទាល់ខ្លួនយ៉ាងមានតម្លៃដើម្បីបង្ហាត់បង្ហាញផ្លូវល្អៗ បានផ្តល់អនុសាសន៍ជាច្រើនទាក់ទងវិធីសាស្ត្រស្រាវជ្រាវ ការប្រមូលឯកសារ ការសរសេរអត្ថបទ ការវិភាគទិន្នន័យសម្រាប់ជាជំនួយចំពោះការចងក្រងកិច្ចការស្រាវជ្រាវ ជាពិសេសបានត្រួតពិនិត្យ កែតម្រូវលើអត្ថបទនៃកិច្ចការស្រាវជ្រាវមួយនេះយ៉ាងហ្មត់ចត់ធ្វើឱ្យកាន់តែល្អប្រសើរបន្ថែមទៀត និងលេចចេញជារូបរាងប្រកបដោយជោគជ័យ។

សូមអរគុណដល់មិត្តភក្តិទាំងអស់គ្នាជានិច្ចកាលតែងតែជួយគាំទ្រ និងជួយលើកទឹកចិត្ត។

ជាកិច្ចចុងក្រោយនេះ យើងខ្ញុំសូមសម្តែងនូវការដឹងគុណជាអនេកប្បការ និងសូមគោរពជូនពរ លោកអ្នកទាំងអស់គ្នាឱ្យជួបប្រទះតែសំណាងល្អ សុខភាពល្អ និងសម្រេចជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# អារម្ភកថា

ជាបឋម យើងខ្ញុំជានិស្សិតដែលកំពុងសិក្សាឆ្នាំទី៤ ជំនាញនីតិសាស្ត្រ ជំនាន់២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមធ្វើគារវកិច្ចគោរពជម្រាបសួរសម្ដេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូជាទីគោរពដ៏ខ្ពង់ខ្ពស់ សិស្ស-និស្សិត និងមិត្តរួមថ្នាក់ទាំងអស់ជាទីរាប់អាន។ យើងខ្ញុំពិតជាមានក្ដីសោមនស្សរីករាយ និងសប្បាយខ្លាំងជាអនេកក្រៃលែង ដែលមានឱកាសចងក្រងនូវអត្ថបទកិច្ចការស្រាវជ្រាវមួយនេះឡើង។

ចំពោះកិច្ចការស្រាវជ្រាវមួយនេះ គឺសិក្សាផ្ដោតសំខាន់ទៅលើ «**ការសង្គ្រោះចំពោះការបំពានកិច្ចសន្យា**»។ ការសង្គ្រោះចំពោះការបំពានកិច្ចសន្យា គឺជាប្រធានបទមួយដែលមានសារសំខាន់ក្នុងសង្គមខ្មែរបច្ចុប្បន្ន ដែលត្រូវយកមកប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាជាច្រើនទាក់ទងនឹងភាគីនៃកិច្ចសន្យាដែលមិនបានបំពេញកាតព្វកិច្ចតាមការកំណត់។ លើសពីនេះគឺមានមុខងារជួយស្វែងរកផលប្រយោជន៍ឡើងវិញដល់ភាគីដែលបាត់បង់ដោយសារមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងទៀត។ ដើម្បីឱ្យកាន់តែស៊ីជម្រៅលើប្រធានបទនេះ យើងខ្ញុំបានបកស្រាយដោយដកស្រង់ចេញពី បទប្បញ្ញត្តិច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា លើកយកឯកសារចាស់ៗថ្មីៗជាច្រើន ដែលបានវិវត្តមកដល់បច្ចុប្បន្ន គឺក្នុងហេតុផលចង់ឱ្យកិច្ចការស្រាវជ្រាវមួយនេះកាន់តែច្បាស់លាស់បន្ថែមទៀត។ ជាពិសេស ចំពោះការធ្វើកិច្ចការស្រាវជ្រាវនេះ ពិតជាគេចមិនផុតពីកំហុសខុសឆ្គងដោយអចេតនានោះទេ ដូចសុភាសិតមួយពោលថា **ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច** ដោយសារតែកត្តានេះហើយ ទើបធ្វើឱ្យការស្រាវជ្រាវនេះនឹងអាចមានចន្លោះខ្វះខាតណាមួយដែលតម្រូវឱ្យបំពេញបន្ថែម។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំទាំងអស់គ្នានឹងព្យាយាមឱ្យអស់ពីលទ្ធភាព និងសមត្ថភាពហើយក៏សូមស្វាគមន៍នូវរាល់មតិរិះគន់ មតិស្ថាបនាទៅលើចំណុចខ្វះខាតរបស់អត្ថបទនេះដើម្បីឱ្យកាន់តែស៊ីជម្រៅ មានអត្ថន័យខ្លឹមសារពេញលេញបរិបូរណ៍។

ជាទីបញ្ចប់ យើងខ្ញុំទាំងអស់គ្នាសូមគោរពជូនពរដល់សាស្ត្រាចារ្យ និងមិត្តនិស្សិតរួមថ្នាក់ទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការអាន ការស្ដាប់នូវខ្លឹមសារដែលបានចងក្រងនេះ ឱ្យជួបតែសំណាងល្អ សូមទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈគ្រប់ពេលវេលា។

# មាតិកា


ទំព័រ

**សេចក្ដីផ្ដើម** ........ ១

## ជំពូកទី១
## មូលហេតុនៃការសង្គ្រោះកិច្ចសន្យា

**ផ្នែកទី១. ការមិនអនុវត្តកិច្ចសន្យា** ........ ៤

**ផ្នែកទី២. ការយឺតយ៉ាវក្នុងការអនុវត្ត** ........ ៥

កថាខណ្ឌទី១. ការកំណត់ពេលពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច ........ ៥

កថាខណ្ឌទី២. ការកំណត់ពេលមិនពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច ........ ៦

កថាខណ្ឌទី៣. ករណីមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ច ........ ៧

**ផ្នែកទី៣. ការអនុវត្តកាតព្វកិច្ចមិនពេញលេញ** ........ ៨

កថាខណ្ឌទី១. ការបំពេញតាវកាលិកមិនពេញលេញ ........ ៨

កថាខណ្ឌទី២. ការអនុវត្តកាតព្វកិច្ចបានតែមួយភាគ ........ ៩

កថាខណ្ឌទី៣. ករណីផ្សេងៗដែលមិនបានអនុវត្តពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច ........ ៩

**ផ្នែកទី៤. អលទ្ធភាពក្នុងការអនុវត្ត** ........ ៩

កថាខណ្ឌទី១. អលទ្ធភាពវាយតម្លៃតាមស្ថានភាពសង្គម ........ ១០

កថាខណ្ឌទី២. អលទ្ធភាពវាយតម្លៃតាមស្ថានភាពសេដ្ឋកិច្ច ........ ១២

**ផ្នែកទី៥. ករណីផ្សេងៗនៃការមិនអនុវត្តកាតព្វកិច្ច ឬគ្មានការអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យា** ........ ១៣

## ជំពូកទី២
## ការដោះស្រាយតាមរយៈការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ

**ផ្នែកទី១. សញ្ញាណនៃការអនុវត្តដោយបង្ខំ** ........ ១៤

**ផ្នែកទី២. ការដាក់ពាក្យសុំអនុវត្តដោយបង្ខំ** ........ ១៥

កថាខណ្ឌទី១. អ្នកដាក់ពាក្យសុំ ........ ១៥

កថាខណ្ឌទី២. ស្ថាប័នមានសមត្ថកិច្ចទទួលពាក្យ ........ ១៦

១. តុលាការអនុវត្ត ........ ១៦

២. អាជ្ញាសាលា ........ ១៧

**ផ្នែកទី៣. កម្មវត្ថុនៃសិទ្ធិទាមទារ** ........ ១៨

កថាខណ្ឌទី១. កម្មវត្ថុនៃសិទ្ធិទាមទារមានគោលបំណងសងជាប្រាក់ ........ ១៩

១. ចលនវត្ថុ ........ ១៩

២. អចលនវត្ថុ ........ ២០

៣. សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងៗ ........ ២១

កថាខណ្ឌទី២. កម្មវត្ថុនៃសិទ្ធិទាមទារគ្មានគោលបំណងសងជាប្រាក់ ........ ២២

១. ការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ........ ២២

២. ការអនុវត្តដោយបង្ខំលើកាតព្វកិច្ចសកម្មភាព ........ ២៣

## ជំពូកទី៣

## ការទាមទារសំណងនៃការខូចខាត

**ផ្នែកទី១. លក្ខខណ្ឌនៃការទទួលខុសត្រូវសំណងការខូចខាត** ........ ២៥

កថាខណ្ឌទី១. សំណងនៃការខូចខាតទូទៅ ........ ២៥

កថាខណ្ឌទី២. លក្ខខណ្ឌពិសេសពាក់ព័ន្ធនឹងកាតព្វកិច្ចជាប្រាក់ ........ ២៧

**ផ្នែកទី២. អំពីការខូចខាត និងទំហំនៃសំណងការខូចខាត** ........ ២៨

កថាខណ្ឌទី១. ទស្សនៈអំពីការខូចខាត ........ ២៨

កថាខណ្ឌទី២. ទំហំនៃសំណងការខូចខាត ........ ២៩

កថាខណ្ឌទី៣. ការគណនា និងអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងខូចខាត ........ ៣២

១. ការកំណត់ទុកជាមុននូវចំនួននៃសំណង ........ ៣២

២. មូលហេតុបន្ថយសំណងនៃការខូចខាត ........ ៣៣

៣. គោលការណ៍នៃការសងសំណងជាប្រាក់ ........ ៣៣

៤. អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារ ........ ៣៤

## ជំពូកទី៤

## ការសង្គ្រោះដោយការរំលាយកិច្ចសន្យា

**ផ្នែកទី១. ការរំលាយកិច្ចសន្យាដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច** ........ ៣៦

កថាខណ្ឌទី១. កិច្ចសន្យាអញ្ញមញ្ញ ........ ៣៧

កថាខណ្ឌទី២. ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ........ ៣៨

១. ការមិនអនុវត្តកាតព្វកិច្ចក្នុងរយៈពេលសមរម្យ ..... ៣៨

២. ការអនុវត្តកាតព្វកិច្ចក្រោយពេលកំណត់ ..... ៣៩

៣. ការមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បង ..... ៤០

៤. ការបំពានកិច្ចសន្យានាំឱ្យបាត់បង់ទំនុកចិត្ត ..... ៤៣

**ផ្នែកទី២. វិធីសាស្ត្ររំលាយកិច្ចសន្យា** ..... ៤៥

កថាខណ្ឌទី១. សិទ្ធិរបស់ភាគីក្នុងការរំលាយកិច្ចសន្យា ..... ៤៥

កថាខណ្ឌទី២. ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ..... ៤៥

**ផ្នែកទី៣. អានុភាពនៃការរំលាយកិច្ចសន្យា** ..... ៤៧

កថាខណ្ឌទី១. អានុភាពចំពោះគូភាគីនៃកិច្ចសន្យា ..... ៤៧

កថាខណ្ឌទី២. អានុភាពចំពោះតតិយជន ..... ៤៨

**ផ្នែកទី៤.ការរំលត់នៃសិទ្ធិរំលាយកិច្ចសន្យា** ..... ៤៨

កថាខណ្ឌទី១. ការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយអាជ្ញាយុកាល ..... ៤៨

កថាខណ្ឌទី២. ការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយសារកម្មវត្ថុនៃកិច្ចសន្យាបានខូចខាត ឬបាត់បង់ ..... ៤៩

**សេចក្តីសន្និដ្ឋាន** ..... ៥១

**អនុសាសន៍** ..... ៥២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ប្រសាសន៍អំពាវនាវដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាមានដូចតទៅ «អំពាវនាវឱ្យវិស័យឯកជន និងវិស័យឯកជនយោគយល់គ្នាក្នុងការរកស៊ីជាមួយគ្នា នោះបិតនៅត្រង់ថាឯកជនមួយគាត់បើកអាជីវកម្ម ក៏ប៉ុន្តែអាជីវកម្មនេះ គាត់មិនមានទីតាំងខ្លួនឯងទេ គាត់ទៅជួលហាងពីម្ចាស់មួយទៀត ដល់អាជីវកម្មរបស់គាត់ពេលនេះកំពុងធ្លាក់ចុះ ឬរហូតដល់បិទទ្វារ ដូច្នេះសូមឱ្យគូភាគីធ្វើការយោគយល់គ្នា កាត់បន្ថយនៃការបង់ ឬពន្យារ ឬក៏គិតថាមិនឱ្យបង់ នេះគ្រាន់តែជាការអំពាវនាវ មិនមែនជាការកាត់ក្តីដល់គូភាគីទេ ព្រោះនេះជាការអនុវត្តកិច្ចសន្យារបស់គូភាគីប៉ុណ្ណោះ ដូចនេះសុំឱ្យមានការយោគយល់គ្នាលើបញ្ហានឹង ខ្ញុំបានស្តាប់នូវមនុស្សមួយចំនួនដែលបានរកស៊ីជួលអគារ ឬទីតាំងគេ ឥឡូវម្ចាស់ដើមទារពេញថ្លៃក្នុងពេលដែលគ្នារកចំណូលអត់បាន ចឹងទេសុំកុំកាប់មេមាន់ទទួលទាន គួរត្រូវរក្សាមេមាន់នេះ ដើម្បីថ្ងៃក្រោយឱ្យវាមានពងកូនតទៅទៀត បើសិនកាប់គ្នាក្នុងពេលនេះគឺបានសេចក្តីថាហាងនេះនឹងបិទ បិទរហូតគ្មានអ្នកណាជួលទៅថ្ងៃក្រោយ ប៉ុន្តែបើសិនជាអនុគ្រោះឱ្យគ្នា១ខែ ២ខែ ឬក៏បញ្ចុះថ្លៃ ៥០ភាគរយ ៦០ភាគរយ ៧០ភាគរយ គឺយើងអាចរក្សាអតិថិជននេះឱ្យជួលត្រឡប់មកវិញ នៅពេលដែលសភាពការណ៍បានបានវិបម្រាស់ត្រឡប់មកវិញ»។ នេះគឺជាការអំពាវនាវដល់ម្ចាស់ទីតាំងនានាដែលបានជួលទីកន្លែងរបស់ខ្លួនឱ្យអ្នកដទៃរកស៊ី ត្រូវមានការយោគយល់ចំពោះការបង់ថ្លៃសេវា ជួលទីតាំង ឬអាចទម្លាក់តម្លៃពេលបង់លុយ ឬទម្លាក់តម្លៃក្នុងកាលៈទេសៈប្រទេសកម្ពុជា កំពុងតែជួបវិបត្តិនៃការរាតត្បាតវីរុស COVID-19។ សេចក្តីអំពាវនាវនេះ បានធ្វើនៅព្រឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ នៅក្នុងឱកាសដែលសម្តេច បានអញ្ជើញជាអធិបតីភាព រៀបចំសន្និសីទសារព័ត៌មានធ្វើជូនជនរួមជាតិក្រោយបញ្ចប់ការបើកសម័យប្រជុំពេញអង្គរដ្ឋសភា ដើម្បីបោះឆ្នោតផ្តល់សេចក្តីទុកចិត្តលើការតែងតាំង និងកែសម្រួលសមាសភាពរដ្ឋាភិបាល។[1] ចំពោះសេចក្តីអំពាវនាវនេះមិនមែនជាបទប្បញ្ញត្តិច្បាប់ដែលអាចយកទៅដោះស្រាយ កាត់ក្តីដល់គូភាគីក្នុងកិច្ចសន្យាណាមួយនោះទេ ផ្ទុយទៅវិញជាការយោគយល់គ្នាទៅវិញទៅមកក្នុងពេលសង្គមជួបប្រទះភាពរឹករវប៉ុណ្ណោះ មានន័យថានៅពេលណាដែលមានការបំពានកិច្ចសន្យាកើតឡើង មិនមែនត្រូវប្រើមធ្យោបាយសម្របសម្រួលបែបនេះរហូតទេ។

រីឯការធ្វើទំនាក់ទំនងក្នុងសង្គម មិនខុសពីការបង្កើតកិច្ចសន្យាប៉ុន្មាននោះទេ គឺទាមទារឱ្យភាគីក្នុងកិច្ចសន្យាមានភាពស្មោះត្រង់ ត្រឹមត្រូវ ជាពិសេសគាប់បីគោរព និងអនុវត្តតាមនូវខ្លឹមសារដែលខ្លួនបានព្រមព្រៀង ទើបធ្វើឱ្យកិច្ចសន្យានោះមានដំណើរការល្អ និងបញ្ចប់ទៅដោយរលូន។ ប៉ុន្តែផ្ទុយទៅវិញ ក្នុងករណីដែល

---

[1] Youtube channel : FRESH NEWS, បានផ្សព្វផ្សាយថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០, តំណភ្ជាប់: https://youtu.be/JsC1aCTE-WM , បានចូលមើលថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២២។

ភាគីនៃកិច្ចសន្យាមិនបានចូលរួមអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យានោះទេ នោះអាចបកស្រាយបានថាការបំពានកិច្ចសន្យាត្រូវបានកើតឡើង ដែលជាហេតុផលធ្វើឱ្យភាគីម្ខាងក្នុងកិច្ចសន្យានោះបាត់បង់នូវប្រយោជន៍ផ្ទុយពីការព្រមព្រៀង នាំឱ្យភាគីដែលបាត់បង់ប្រយោជន៍នោះមិនសុខចិត្ត និងឈានដល់ការស្វែងរកនូវដំណោះស្រាយ គឺជា «**ការសង្គ្រោះចំពោះការបំពានកិច្ចសន្យា**» ។

ការសង្គ្រោះចំពោះការបំពានកិច្ចសន្យា គឺជាមធ្យោបាយ ឬជានីតិវិធីនៃការដោះស្រាយមួយដែលអាចយកមកប្រើប្រាស់ បន្ទាប់ពីមានការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាង ហើយបង្កព្យសនកម្មដល់ភាគីម្ខាងទៀត។ ត្រង់ចំណុចនេះ បើគូភាគីក្នុងកិច្ចសន្យាអនុវត្តខ្លឹមសារនៃការព្រមព្រៀង ឬមិនមានបញ្ហាណាមួយកើតឡើងជាយថាហេតុ នោះឈានដល់ចំណុចបញ្ចប់នៃកិច្ចសន្យា គឺភាគីត្រូវបានរលត់កាតព្វកិច្ចដូចមានកំណត់ក្នុងការព្រមព្រៀងនោះ។ ប៉ុន្តែក្នុងករណី ដំណើរការនៃការអនុវត្តកិច្ចសន្យារបស់ភាគីមានបញ្ហាណាមួយកើតឡើងដោយសារបញ្ហារបស់ភាគីខ្លួនឯង ឬដោយសារបញ្ហាប្រធានសក្តិផ្សេងៗ ដែលធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់ភាគីម្ខាងទៀត ក្លាយជាហេតុផលធ្វើឱ្យភាគីនោះមានសិទ្ធិទាមទារនូវការខាតបង់ដែលផ្ទុយនឹងខ្លឹមសារនៃកិច្ចសន្យា ដោយការប្រើប្រាស់នូវនីតិវិធីមួយហៅថា ការសង្គ្រោះចំពោះការបំពានកិច្ចសន្យា។

ចំពោះប្រធានបទនេះបានរំលេចចេញនូវចំណោទបញ្ហាមួយចំនួនដូចជា តើមូលហេតុនៃការបំពានកិច្ចសន្យាមានអ្វីខ្លះ ទើបនាំឱ្យមានការសង្គ្រោះកិច្ចសន្យាកើតមានឡើង? តើការសង្គ្រោះចំពោះការបំពានកិច្ចសន្យាមានលក្ខណៈដូចម្តេច ហើយមានដំណើរការនីតិវិធីយ៉ាងណា? ក្រៅពីការសង្គ្រោះកិច្ចសន្យាដែលបានកំណត់តាមច្បាប់ តើអាចមាននីតិវិធីសម្របសម្រួលផ្សេងៗទៀតឬទេ?

ដាក់ស្តែងកិច្ចការស្រាវជ្រាវមួយនេះ មានគោលបំណងស្វែងយល់ពីតថភាពដែលកើតឡើងក្នុងកិច្ចសន្យាដូចជា ការរំលោភបំពានលើកិច្ចសន្យាផ្សេងៗរបស់ភាគីណាមួយ ឈានដល់ការស្វែងរកវិធីសាស្ត្រសង្គ្រោះចំពោះការបំពានកិច្ចសន្យានេះ ដែលជានីតិវិធីមួយជួយស្វែងរកផលប្រយោជន៍របស់ភាគីដែលខាតបង់ឡើងវិញ ផ្តល់ជាមេរៀន និងដាក់ទណ្ឌកម្មទៅលើបុគ្គលក្នុងសង្គមដែលរំលោភបំពានកិច្ចសន្យា ជាពិសេសគឺចង់ចែករំលែក និងបង្ការទៅកាន់ភាគីក្នុងកិច្ចសន្យាទាំងអស់មិនគួរមានការបំពានកិច្ចសន្យាឡើយ ទោះបីក្នុងបរិបទសង្គមណាក៏ដោយ។

ខ្លឹមសារនៃកិច្ចការស្រាវជ្រាវខាងលើ ផ្តោតសំខាន់លើការសង្គ្រោះចំពោះការបំពានកិច្ចសន្យា នោះមានន័យថា រាល់ការមិនអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យាទាំងអស់ ត្រូវប្រើប្រាស់បញ្ញត្តិរួមយកមកសង្គ្រោះដែលមានចែងក្នុងក្រមរដ្ឋប្បវេណី គន្ថីទី ៤ ជំពូកទី៤ លើកលែងមានចែងក្នុងកិច្ចសន្យាពិសេសផ្សេងៗ។ ប៉ុន្តែដោយសារ

ក្នុងក្របខណ្ឌគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ទម្រង់នៃកិច្ចសន្យាដែលជាប្រភពមួយនៃកាតព្វកិច្ច មានច្រើនបែប ច្រើនយ៉ាង ដូច្នេះកិច្ចការស្រាវជ្រាវនេះបានកំណត់វិសាលភាពដោយលើកយកតែការសង្គ្រោះចំពោះការបំពានកិច្ចសន្យា ចំពោះកិច្ចសន្យាខ្ចីបរិភោគ ភតិសន្យា កិច្ចសន្យាលក់ទិញ កិច្ចសន្យាដឹកជញ្ជូនជាដើម ពីព្រោះថាក្នុងប្រទេសកម្ពុជាឃើញមានបញ្ហានៃការមិនអនុវត្តលើកិច្ចសន្យាទាំងនេះញឹកញាប់។

អំពីនីតិវិធី ឬវិធីសាស្រ្តនៃការស្រាវជ្រាវលើកិច្ចការនេះ ប្រភេទឯកសារជាច្រើនដែលមានប្រភពច្បាស់លាស់ និងអាចជឿជាក់បានត្រូវបានបញ្ចូលក្នុងអត្ថបទ ដោយក្នុងនោះរួមមានបទប្បញ្ញត្តិគតិយុត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ថ្នាក់ដឹកនាំ ប្រភពស្នាដៃរបស់អ្នកនិពន្ធដូចជា ឯកសាររបស់សាស្រ្តាចារ្យដែលមានបទពិសោធន៍ជាច្រើន គេហទំព័រទាំងក្នុង និងក្រៅប្រទេសផងដែរ ដើម្បីធ្វើជាមូលដ្ឋានគ្រឹះក្នុងការបម្រើឱ្យកិច្ចការស្រាវជ្រាវមួយនេះប្រព្រឹត្តិទៅបានយ៉ាងល្អ។

គ្រប់ដំណើរការតាក់តែងអត្ថបទ ឬឯកសារផ្សេងៗទាមទារឱ្យកំណត់ទុកជាមុននូវប្លង់ និងចំណុចគោលសំខាន់ៗ ដើម្បីងាយស្រួលដល់អ្នកសិក្សាស្រាវជ្រាវចងក្រងជាអត្ថបទ មិនខុសគ្នាដែរ ចំពោះកិច្ចការស្រាវជ្រាវស្តីពី «**ការសង្គ្រោះចំពោះការបំពានកិច្ចសន្យា**» ប្លង់នៃកិច្ចការស្រាវជ្រាវសំខាន់ៗត្រូវបានបែងចែកមានដូចជា ជំពូកទី១ **មូលហេតុនៃការសង្គ្រោះកិច្ចសន្យា** ដែលនឹងបកស្រាយពីមូលហេតុផ្សេងៗដែលនាំឱ្យមាននីតិវិធីសង្គ្រោះកិច្ចសន្យា។ ជំពូកទី២ **ការដោះស្រាយតាមរយៈការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ**។ ជំពូកទី៣ **ការទាមទារសំណងនៃការខូចខាត**។ ជំពូកទី៤ **ការសង្គ្រោះដោយការរំលាយកិច្ចសន្យា**។

# ជំពូកទី១

# មូលហេតុនៃការសង្គ្រោះ

# កិច្ចសន្យា

# ជំពូកទី១

# មូលហេតុនៃការសង្គ្រោះកិច្ចសន្យា

## ផ្នែកទី១. ការមិនអនុវត្តកិច្ចសន្យា

នៅពេលមានការព្រមព្រៀងចំពោះកិច្ចសន្យារួចហើយ ភាគីក្នុងកិច្ចសន្យាត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របទៅតាមខ្លឹមសារដែលបានកំណត់នោះ ស្របតាមគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់។ ក្នុងករណីដែលកូនបំណុល ឬម្ចាស់បំណុល ឬភាគីណាមួយនៃកិច្ចសន្យាមិនបំពេញកាតព្វកិច្ចតាមខ្លឹមសារដែលបានព្រមព្រៀងគ្នា ដោយមូលហេតុណាមួយផ្ទុយពីការព្រមព្រៀងនៃកិច្ចសន្យា ឬតាមបញ្ញត្តិច្បាប់នាំឱ្យភាគីដែលមិនអនុវត្តកាតព្វកិច្ចនោះត្រូវតែទទួលខុសត្រូវតាមបញ្ញត្តិច្បាប់ដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានកំណត់និយមន័យ ការមិនអនុវត្តកិច្ចសន្យា សំដៅទៅលើករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដែលបានកើតឡើងពីកិច្ចសន្យា។[2] ការមិនអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា ជាស្ថានភាពដែលម្ចាស់បំណុលរងការខូចខាត ឬបាត់បង់ទំនុកចិត្តក្នុងការបន្តអនុវត្តកិច្ចសន្យា។[3] ដើម្បីងាយស្រួលយល់ឱ្យកាន់តែច្បាស់ ភាគីត្រូវយល់ដឹងពីករណីយកិច្ច និងពិចារណាលើសកម្មភាពដែលត្រូវអនុវត្តនៅក្នុងកិច្ចសន្យា និងសកម្មភាពដែលមិនត្រូវអនុវត្តនៅក្នុងកិច្ចសន្យា។ ដូច្នេះ ទើបក្រមរដ្ឋប្បវេណីចែងបញ្ញត្តិនេះឡើងក្នុងគោលបំណងការពារផលប្រយោជន៍ ដល់ជនរងគ្រោះដែលទទួលរងការបំពានកិច្ចសន្យា។

ចំពោះទម្រង់នៃការមិនអនុវត្តកាតព្វកិច្ចវិញ យោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ គឺជាទម្រង់ដែលភាគីក្នុងកិច្ចសន្យាមានកាតព្វកិច្ចត្រូវធ្វើតាមការព្រមព្រៀង ប៉ុន្តែភាគីបានបំពានលើខ្លឹមសារនៃកិច្ចសន្យា ឬមិនបានបំពេញសកម្មភាពនៃផ្នែកណាមួយដែលមានចែងនៅក្នុងកិច្ចសន្យាដែលបានបង្កើតឡើង។

ក្នុងកិច្ចសន្យាបានកំណត់នូវកាតព្វកិច្ចឱ្យភាគីបំពេញ ប៉ុន្តែភាគីក្នុងកិច្ចសន្យាមិនអាចអនុវត្តកាតព្វកិច្ចបាន ជាហេតុនាំឱ្យកើតឡើងនូវទម្រង់នៃការមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដែលនឹងត្រូវបកស្រាយនៅក្នុងផ្នែកបន្តបន្ទាប់ទៀត ក្នុងជំពូកទី១នេះ។ក្នុងន័យនេះ ការកំណត់ថាភាគីមិនអនុវត្តកាតព្វកិច្ចដែលកើតពីកិច្ចសន្យា លុះត្រាតែភាគីមិនបានអនុវត្តស្របទៅតាមទម្រង់ណាមួយ ទើបចាត់ទុកថាមិនអនុវត្តកាតព្វកិច្ចជាហេតុនាំឱ្យមានការបំពាន រីឯភាគីទទួលនូវការបំពានមានសិទ្ធិទាមទារទទួលបាននូវការសង្គ្រោះចំពោះការបំពានកិច្ចសន្យា។[4]

---

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៨៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១។

[3] មេធាវី អ៊ីវ ប៉ូលី, *ស្តីពី ការរំលាយកិច្ចសន្យា*, ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៧, ទំព័រ ១១។

[4] លោកស្រី ប៉ូលី បញ្ញា និងលោក ព្រុំ វិទ្ធី, *អំពី នីតិកិច្ចសន្យាពិសេស ភាគ១*, បោះពុម្ពលើកទី១ ឆ្នាំ២០២១, ទំព័រ ៦២។

## ផ្នែកទី២. ការយឺតយ៉ាវក្នុងការអនុវត្ត

ការយឺតយ៉ាវក្នុងការអនុវត្ត គឺជាសកម្មភាពដែលអាចចាត់ទុកថា កូនបំណុលបានអនុវត្តយឺតយ៉ាវ ខណៈដែលដល់ពេលកំណត់ហើយតែពុំបានអនុវត្តកាតព្វកិច្ច។ ការយឺតយ៉ាវក្នុងការអនុវត្តជាប្រភេទមួយនៃការបំពានកិច្ចសន្យា។ កាតព្វកិច្ចដែលបានកើតឡើង ប្រសិនបើមានការកំណត់ពេលអនុវត្តហើយវិធីអនុវត្តនីមួយៗ មានភាពខុសគ្នាក្នុងការសម្រេចអំពីការកន្លងហួសនៃការកំណត់ពេលត្រូវអនុវត្ត។[5] បើទោះបីជាភាគីបានអនុវត្តកិច្ចសន្យាក៏ដោយ ប៉ុន្តែភាគីបានអនុវត្តកាតព្វកិច្ចផុតហួសរយៈពេលកំណត់ ឬលើសកាលបរិច្ឆេទដែលមាននៅក្នុងលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា ក្នុងករណីនេះក៏ចាត់ទុកជាការយឺតយ៉ាវដែរ។ ម្យ៉ាងវិញទៀត ចំពោះការយឺតយ៉ាវក្នុងការអនុវត្តនេះ គឺជាប្រភពដែលភាគីម្ចាស់បំណុលអាចកំណត់ថាជាការមិនអនុវត្តកិច្ចសន្យាបាន ហើយកូនបំណុលត្រូវតែទទួលខុសត្រូវនូវទង្វើរបស់ខ្លួនដែលបណ្តាលមកពីការយឺតយ៉ាវនោះ។

ហេតុដូច្នេះ ទើបក្នុងក្រមរដ្ឋប្បវេណីមានចែងអំពីការយឺតយ៉ាវក្នុងការអនុវត្តមកធ្វើជាមូលហេតុដែលនាំឱ្យមានការសង្គ្រោះចំពោះការបំពានកិច្ចសន្យា។ កូនបំណុល ត្រូវចាត់ទុកថាមានការយឺតយ៉ាវក្នុងការអនុវត្តក្នុងករណីដែលខ្លួនមិនបានអនុវត្តកាតព្វកិច្ច នៅពេលដែលបានកំណត់ដូចខាងក្រោមនេះ៖

### កថាខណ្ឌទី១. ការកំណត់ពេលពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច

ប្រសិនបើមានការកំណត់ពេលពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដល់ការកំណត់នោះ[6] កិច្ចសន្យាដែលមានកំណត់ពេលពិតប្រាកដ ដែលមានការកំណត់ពេលវេលាជាក់លាក់ដូចជា ថ្ងៃ ទី ខែ ឆ្នាំ ដើម្បីឱ្យត្រឹមត្រូវ និងងាយស្រួលក្នុងការបំពេញកាតព្វកិច្ច។ នៅក្នុងកិច្ចសន្យាដែលភាគីទាំងសងខាងបានធ្វើការព្រមព្រៀងលើការកំណត់ពេលជាក់លាក់ក្នុងរយៈពេលបំពេញកាតព្វកិច្ច ឬផ្តល់តាវកាលិកទៅវិញទៅមក នោះភាគីត្រូវតែធ្វើការអនុវត្តតាមការកំណត់ បើពុំនោះទេ ករណីដែលដល់ពេលកំណត់ហើយមិនបានអនុវត្ត ភាគីនោះអាចកំណត់ថាជាការមិនអនុវត្តកិច្ចសន្យាដោយមូលហេតុ ការយឺតយ៉ាវក្នុងការអនុវត្តកិច្ចសន្យាមានកំណត់ពេលពិតប្រាកដ។

ក្នុងករណីនេះ ភាគីម្ខាងមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនដោយមូលហេតុយឺតយ៉ាវជាហេតុដែលអាចបណ្តាលឱ្យភាគីម្ខាងទៀតត្រូវរងព្យសនកម្ម ឬបាត់បង់ផលប្រយោជន៍ពីការយឺតយ៉ាវនោះ បាត់បង់ការទុកចិត្តលើការបំពេញកាតព្វកិច្ច ជាពិសេសដោយសារតែការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចក៏អាចឈានដល់ការខូច

---

[5] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណីរបស់ក្រសួងយុត្តិធម៌, *សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២ គន្ថីទី ៤, ស្តីពី «កាតព្វកិច្ច»* ឆ្នាំ២០១០, ទំព័រ ១០៤។

[6] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៩១ កថាខណ្ឌទី១ ចំណុច ក។

ខាតប្រយោជន៍ធ្ងន់ធ្ងរទៀតផង។

ក្នុង**កិច្ចសន្យាខ្ចីបរិភោគ**[7]មួយ ដែលភាគីកូនបំណុលបានយល់ព្រមគ្រប់ចំណុចនៃកិច្ចសន្យា បន្ទាប់មកភាគីសងខាងបានព្រមព្រៀងគ្នាចំពោះការកំណត់ពេលពិតប្រាកដ ដើម្បីឱ្យកូនបំណុលងាយស្រួលក្នុងការអនុវត្តកាតព្វកិច្ច ម្ចាស់បំណុល និងកូនបំណុលបានកំណត់ នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២។ ក្នុងករណីនេះប្រសិនបើភាគីកូនបំណុលបានអនុវត្តកាតព្វកិច្ច នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ នោះគ្មានបញ្ហាទេ។ ប៉ុន្តែប្រសិនបើកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២នោះទេ រហូតឈានដល់ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២២មកដល់ត្រូវបានចាត់ទុកថាការយឺតយ៉ាវក្នុងការអនុវត្តក្នុងកិច្ចសន្យាដែលមានការកំណត់ពេលពិតប្រាកដដោយផ្អែកតាមលក្ខខណ្ឌកំណត់។

### កថាខណ្ឌទី២. ការកំណត់ពេលមិនពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច

ប្រសិនបើមានកំណត់ពេលមិនពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដែលកូនបំណុលនោះដឹងថាដល់ពេលកំណត់ហើយ[8] ក្នុងចំណុចនេះនិយាយអំពីកិច្ចសន្យាដែលមានការកំណត់ពេលមិនពិតប្រាកដសំដៅដល់ការព្រមព្រៀងរវាងភាគីដែលមិនបានកំណត់លើកាលបរិច្ឆេទដូចជា ថ្ងៃទី ខែ ឆ្នាំពិតមកដល់ ឬមិនដឹងប្រាកដថានឹងមកដល់ពេលណា ប៉ុន្តែភាគីក៏នៅតែអនុវត្តកាតព្វកិច្ចនោះដដែល។ ភាគីអាចធ្វើកិច្ចសន្យាមិនថាជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ថានឹងបំពេញកាតព្វកិច្ចដោយការបានផលពីសកម្មភាពអ្វីមួយមកបំពេញកាតព្វកិច្ចដែលបានព្រមព្រៀង។

តាមរយៈកិច្ចសន្យាខ្ចីបរិភោគ ភាគីអ្នកខ្ចី «តទៅនេះហៅថា កូនបំណុល» បានខ្ចីប្រាក់ពីភាគីអ្នកឱ្យខ្ចី «តទៅនេះហៅថា ម្ចាស់បំណុល» ចំនួន ១០ លានរៀល ក្នុងគោលបំណងដើម្បីផ្គត់ផ្គង់ជីវភាពរបស់ខ្លួនជាបណ្ដោះអាសន្នដោយសន្យាថាប្រមូលផលបាននឹងសងទៅម្ចាស់បំណុលវិញ។ ប៉ុន្តែ ដោយសារតែអាកាសធាតុរាំងស្ងួត ជាមូលហេតុនាំឱ្យដំណាំមិនទទួលបានផលតាមការរំពឹងទុក ហើយគាត់ក៏មានគម្រោងថានឹងលក់ដីដើម្បីទទួលបានចំណូលហើយក៏មានជំនឿថាអាចមានលទ្ធភាពក្នុងការសងប្រាក់បាន ម្យ៉ាងវិញទៀតគាត់បានសន្យាថានៅពេលលក់ដីបានគាត់នឹងទូទាត់ទាំងប្រាក់ដើម និងការប្រាក់គ្រប់ចំនួនទៅកាន់ភាគីម្ចាស់បំណុលវិញ។ យ៉ាងណាមិញភាគីម្ចាស់បំណុល ក៏បានយល់ព្រមនូវសំណើរបស់កូនបំណុលដែរ។

---

[7] **កិច្ចសន្យាខ្ចីបរិភោគ** សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថាអ្នកឱ្យខ្ចីមានករណីយកិច្ចប្រគល់ការប្រើប្រាស់ដោយសេរីនូវប្រាក់ ស្បៀងអាហារ ឬវត្ថុជំនួសផ្សេងទៀត ក្នុងអំឡុងពេលដែលមានកំណត់ ឱ្យទៅភាគីម្ខាងទៀតក្នុងអំឡុងពេលមានដែនកំណត់ឱ្យទៅភាគីម្ខាងទៀតហៅថាអ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីយកិច្ចសងទៅឱ្យអ្នកឱ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទ គុណភាព និងចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ។ (ដកស្រង់ចេញពី ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៥៧៨)

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៩១ កថាខណ្ឌទី១ ចំណុច ខ។

ករណីនេះ ការកំណត់ពេលមិនពិតប្រាកដក្នុងកិច្ចសន្យាដើម្បីអនុវត្តកាតព្វកិច្ច។ ក្នុងកិច្ចសន្យាប្រភេទបែបនេះ នៅពេលដែលកូនបំណុលបានសន្យាថានឹងសងក្នុងឱកាសណាមួយ (ឧទាហរណ៍ លក់ដីបាន ដល់រដូវប្រមូលផលដំណាំ...) លុះដល់ពេលដែលឱកាសនោះមកដល់ភាគីកូនបំណុលត្រូវតែអនុវត្តក្នុងកិច្ចសន្យា ឬជាការជូនដំណឹងទៅភាគីម្ចាស់បំណុលក្នុងលក្ខខណ្ឌដែលបានព្រមព្រៀង។ បន្ទាប់មកនៅពេលដែលកូនបំណុលយល់ព្រមអនុវត្តកាតព្វកិច្ចនោះមិនជាបញ្ហាទេ ប៉ុន្តែប្រសិនបើកូនបំណុលដល់ពេលវេលាអនុវត្តហើយមិនអនុវត្តបណ្តាលឱ្យហួសពេលដូចបានព្រមព្រៀង រួចអនុវត្តកាតព្វកិច្ចជាក្រោយ នោះភាគីត្រូវតែទទួលខុសត្រូវចំពោះការយឺតយ៉ាវក្នុងកិច្ចសន្យាកំណត់ពេលវេលាមិនច្បាស់លាស់។

**កថាខណ្ឌទី៣. ករណីមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ច**

ប្រសិនបើមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ចទេ នៅពេលដែលកូនបំណុលនោះទទួលការទាមទារឱ្យអនុវត្ត[9] ក្នុងករណីមិនមានកំណត់ពេលនៅចំណុចនេះ សំដៅដល់កិច្ចសន្យាដែលភាគីសងខាងមិនបានកំណត់ពេលវេលា ថ្ងៃ ទី ខែ ឆ្នាំក្នុងការអនុវត្តកាតព្វកិច្ចឡើយ។ ដោយសារតែគ្មានកំណត់រយៈពេលនៃកិច្ចសន្យាកូនបំណុលអាចសង ឬផ្តល់ពេលណាក៏បាន។ ដូច្នេះ ភាគីជាម្ចាស់បំណុលអាចទាមទារ ឬធ្វើការដាស់តឿនឱ្យភាគីដែលជាកូនបំណុលអនុវត្តកាតព្វកិច្ចនៅពេលណាដែលម្ចាស់បំណុលត្រូវការ (ពេលដែលសមរម្យ) ហើយកូនបំណុលបានយល់ព្រមទទួលការទាមទារនេះ កូនបំណុលចាំបាច់ត្រូវអនុវត្តនៅថ្ងៃនោះតាមការកំណត់រវាងភាគីសងខាង។ ប៉ុន្តែ ប្រសិនបើថ្ងៃដែលទទួលការទាមទារបានកន្លងហួសនោះត្រូវបានចាត់ទុកថាមិនបានអនុវត្តកាតព្វកិច្ច។

ជាក់ស្តែង ភាគីបានព្រមព្រៀងបង្កើតនូវ **កិច្ចសន្យាខ្ចីប្រើ**[10] ចំពោះកិច្ចសន្យាប្រភេទនេះទោះបីជាភាគីម្ចាស់បំណុល មិនយកថ្លៃឈ្នួលក៏ដោយ ប៉ុន្តែ ភាគីក៏មានការព្រមព្រៀងលើការប្រើប្រាស់ និងសម្រាប់អាស្រ័យផលលើវត្ថុនោះដែរ។ ដូច្នេះ ក្នុងករណីដែលអាចកើតមានឡើងគឺ ភាគីសងខាងរវាងអ្នកខ្ចី និងអ្នកឱ្យខ្ចី បានព្រមព្រៀងលើកិច្ចសន្យាខ្ចីប្រើដោយប្រើប្រាស់ ព្រមទាំងអាស្រ័យផលលើដីចម្ការដំណាំដំឡូង។ ក្នុងករណីជាកិច្ចសន្យាដែលមិនកំណត់ពេលនោះទេ ភាគីអ្នកឱ្យខ្ចីអាចមានសិទ្ធិទាមទារដីដែលជាកិច្ចសន្យាខ្ចីប្រើនេះពេលណាក៏បានអាស្រ័យលើសំណើ និងស្នើការទទួលបានយល់ព្រមរបស់ភាគីអ្នកខ្ចីផងដែរ។

ដូច្នេះ ទម្រង់សម្រាប់អនុវត្តកិច្ចសន្យាចំពោះលក្ខខណ្ឌក្នុងការកំណត់ពេលវេលាអាស្រ័យលើភាគីអ្នកកំណត់ដើម្បីទាមទារឱ្យភាគីម្ខាងទៀតអនុវត្តកាតព្វកិច្ចអាចជាការកំណត់ពេលវេលាពិតប្រាកដ ការកំណត់ពេល

---

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៩១ កថាខណ្ឌទី១ ចំណុច គ។

[10] **កិច្ចសន្យាខ្ចីប្រើ** សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ឱ្យភាគីម្ខាងទៀតប្រើប្រាស់និងអាស្រ័យផលនូវវត្ថុណាមួយដោយមិនឱ្យបង់ថ្លៃ។ (ដកស្រង់ចេញពីក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៦២៥)

មិនច្បាស់លាស់ និងការមិនមានកំណត់ពេលវេលា។ យ៉ាងណាមិញកូនបំណុលក៏ត្រូវតែអនុវត្តតាមការកំណត់ដែលក្នុងកិច្ចសន្យាដែលព្រមព្រៀង ដោយឡែកបើកូនបំណុលមិនបានអនុវត្តតាមកាលបរិច្ឆេទទនោះមានន័យថា បានយឺតយ៉ាវក្នុងការអនុវត្តដែលជា មូលហេតុនាំឱ្យកូនបំណុលត្រូវតែទទួលខុសត្រូវការខូចខាតដែលបណ្តាលមកពីការមិនអនុវត្តរបស់ខ្លួនតាមច្បាប់កំណត់ផងដែរ។

## ផ្នែកទី៣. ការអនុវត្តកាតព្វកិច្ចមិនពេញលេញ

ការអនុវត្តកាតព្វកិច្ចមិនពេញលេញ គឺសំដៅលើសកម្មភាពដែលកូនបំណុលបានអនុវត្តកាតព្វកិច្ច ប៉ុន្តែការផ្តល់តាវកាលិកមិនពេញលេញ ឬករណីដែលអនុវត្តតែមួយផ្នែកនៃកាតព្វកិច្ច ឬករណីផ្សេងទៀតដែលគ្មានការអនុវត្តឱ្យបានពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច។[11]

### កថាខណ្ឌទី១. ការបំពេញតាវកាលិកមិនពេញលេញ

ករណីដែលកាតព្វកិច្ចត្រូវបានអនុវត្តតែតាវកាលិកមិនបានពេញលេញ សំដៅលើស្ថានភាពដែលកូនបំណុលបានអនុវត្តកាតព្វកិច្ចតាមខ្លឹមសារនៃកិច្ចសន្យា និងអនុវត្តតាមពេលវេលាកំណត់ក៏ប៉ុន្តែ តាវកាលិកនៃការអនុវត្តនោះ គឺមានវិការៈ[12] ណាមួយដែលបណ្តាលឱ្យខូចប្រយោជន៍របស់ម្ចាស់បំណុល។

ឧទាហរណ៍ នៅក្នុងកិច្ចសន្យាលក់ទិញមួយ ដែលអ្នកទិញបានកម្មង់ទិញកុំព្យូទ័រពីអ្នកលក់ ចំនួន ១០ គ្រឿងដែលមានតម្លៃ ៥០០០ (ប្រាំពាន់) ដុល្លារសហរដ្ឋអាមេរិក ដោយកំណត់ចំនួន ១ សប្តាហ៍ដើម្បីទទួលបានឥវ៉ាន់ពីអ្នកលក់។ ១ សប្តាហ៍ក្រោយមកភាគីអ្នកលក់បានប្រគល់ជូនអ្នកទិញនូវចំនួនកុំព្យូទ័រចំនួន ១០ គ្រឿងដែលស្របតាមការដែលបានព្រមព្រៀងពិតប្រាកដមែន ប៉ុន្តែ ក្នុងចំណោមកុំព្យូទ័រចំនួន ១០ គ្រឿងមានកុំព្យូទ័រចំនួន ៣ គ្រឿងបានបែកកញ្ចក់។ ក្នុងករណីនេះជាការបំពេញតាវកាលិកមានវិការៈដែលជាកំហុសខ្វះការប្រុងប្រយ័ត្នរបស់អ្នកលក់បណ្តាលឱ្យមានការខូចខាតកុំព្យូទ័រជាហេតុនាំឱ្យ មានការអនុវត្តមិនបានពេញលេញតាមកិច្ចព្រមព្រៀង។

---

[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៩៣។

[12] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *ស្តីពីសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១,* បោះពុម្ពលើកទី១ ឆ្នាំ២០១៣, ទំព័រ ១៦០។

**កថាខណ្ឌទី២. ការអនុវត្តកាតព្វកិច្ចបានតែមួយភាគ**

ករណីកាតព្វកិច្ចត្រូវបានអនុវត្តបានតែមួយភាគ សំដៅលើស្ថានភាពដែលកូនបំណុលបានអនុវត្តកាតព្វកិច្ចតាមខ្លឹមសារនៃកិច្ចសន្យា និងអនុវត្តតាមពេលវេលាកំណត់រួចហើយ ប៉ុន្តែតាវកាលិកនៃការអនុវត្តនោះគឺបានអនុវត្តមួយភាគ[13] នៃកាតព្វកិច្ចទាំងស្រុង។

ក្នុងកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់មួយ ដែលភាគីកូនបំណុលបានខ្ចីប្រាក់ពីម្ចាស់បំណុលចំនួន ១០០០០ (មួយម៉ឺន) ដុល្លារសហរដ្ឋអាមេរិក ដោយបានយល់ព្រមលើលក្ខខណ្ឌកំណត់នូវអាត្រាការប្រាក់ ៣% ក្នុង ១ (មួយ) ខែ ស្មើនឹង ៣០០ (បីរយ) ដុល្លារក្នុង ១ ខែព្រមទាំងរំលោះប្រាក់ដើម ១០០០ (មួយពាន់) ដុល្លារសហរដ្ឋអាមេរិក ក្នុង១ ខែ និងមានរយៈពេលខ្ចីចំនួន ១០ខែ។ ក្រោយពីបានប្រគល់កម្មវត្ថុនៃកិច្ចសន្យារួចរាល់ភាគីបានបំពេញតាវកាលិករបស់ខ្លួនជារៀងរាល់ខែរហូតដល់ខែទី៥ នៃកិច្ចសន្យា។ លុះចាប់ខែទី ៦ កូនបំណុលមិនបានបំពេញតាវកាលិកទៀតឡើយ មិនតែប៉ុណ្ណោះកូនបំណុលបានយកប្រាក់ដែលខ្លួនមានយកទៅទិញដីទៅវិញ ជាហេតុនាំឱ្យកូនបំណុលបានអនុវត្តតាវកាលិកបានតែមួយភាគនៃកាតព្វកិច្ចទាំងស្រុង។

**កថាខណ្ឌទី៣. ករណីផ្សេងៗដែលមិនបានអនុវត្តពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច**

ក្នុងករណីដទៃទៀតដែលមិនបានអនុវត្តឱ្យពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច គឺពិបាកបកស្រាយថាវាកើតឡើងក្នុងរូបភាពបែបណាណាស់សម្រាប់ទិដ្ឋភាពជាក់ស្តែងបច្ចុប្បន្ន។ ប៉ុន្តែសង្ឃឹមថានឹងត្រូវបានបកស្រាយតាមរយៈយុត្តិសាស្ត្ររបស់តុលាការក្នុងការអនុវត្តកិច្ចការជាក់ស្តែងនាពេលអនាគត។ ហើយតាមស្ថានភាពជាក់ស្តែង មានការពិបាកនឹងបែងចែកថា តើជា «ករណីដទៃទៀត ដែលមិនអាចអនុវត្តបានពេញលេញតាមខ្លឹមសារនៃកាតព្វកិច្ច» នៃមាត្រា ៣៩៣ ឬជា «ករណីផ្សេងទៀតនៃការមិនអនុវត្តកាតព្វកិច្ច» នៃមាត្រា ៣៩៤? ប៉ុន្តែម្ចាស់បំណុលអាចជ្រើសរើសលក្ខខណ្ឌណាមួយដែលស្រួលអះអាង និងបញ្ជាក់ភស្តុតាងបានក្នុងចំណោមលក្ខខណ្ឌទាំងពីរនេះ ដើម្បីទាមទារឱ្យកូនបំណុលទទួលទណ្ឌកម្មនៃកិច្ចសន្យាដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ចបានគ្រប់គ្រាន់។[14]

**ផ្នែកទី៤. អលទ្ធភាពក្នុងការអនុវត្ត**

ចំពោះពាក្យអលទ្ធភាពក្នុងការអនុវត្ត បើបកស្រាយក្នុងន័យសាមញ្ញ គឺមានន័យខ្លីដែលបញ្ជាក់ពីកិច្ចការណាមួយដែលត្រូវបំពេញ ប៉ុន្តែគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីធ្វើវាឱ្យបានសម្រេច។

ផ្ទុយមកវិញ បើក្រឡេកមើលក្នុងក្រមរដ្ឋប្បវេណីដែលបានបញ្ញត្តិពីអលទ្ធភាពក្នុងការអនុវត្ត គឺជាមូល

[13] ស៊ុម សុខម្ភ, *ស្តីពី បច្ចេកទេស និងវិធីសាស្ត្របទស្រាយគតិយុត្តនានា* (រាជបណ្ឌិតសភាវិជ្ជាជីវតុលាការ),ទំព័រ ៦ ចំណុច១.៣។

[14] ស៊ុម សុខម្ភ, *ស្តីពី បច្ចេកទេស និងវិធីសាស្ត្របទស្រាយគតិយុត្តនានា* (រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ), ទំព័រ ៦ ចំណុច១.១។

ហេតុមួយដែលបង្កើតឱ្យមានការសង្គ្រោះចំពោះការបំពានកិច្ចសន្យា[15] ហើយអត្ថន័យរបស់វាមិនត្រឹមតែបញ្ជាក់ពីភាពគ្មានលទ្ធភាពដើម្បីបំពេញដូចការបកស្រាយក្នុងន័យសាមញ្ញទេ គឺបានបញ្ចូលបន្ថែមនូវលក្ខខណ្ឌមួយចំនួនទៀត ដែលលក្ខខណ្ឌនោះក៏បញ្ជាក់ថាជាស្ថានភាពដែលអលទ្ធភាពក្នុងការអនុវត្តផងដែរ។ អលទ្ធភាពក្នុងការអនុវត្ត ត្រូវបានគេកំណត់យកមកធ្វើជាមូលហេតុនៃការសង្គ្រោះលើការបំពានកិច្ចសន្យា ដើម្បីជួយស្វែងរកផលប្រយោជន៍ដល់ភាគីនៃកិច្ចសន្យាដែលខាតបង់តាមរយៈវិធីសង្គ្រោះដូចមានចែងក្នុងក្រមរដ្ឋប្បវេណីផងដែរ។

ចំណុចដំបូង គឺប្រសិនបើគ្មានលទ្ធភាពក្នុងការអនុវត្តទេ ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាព។ អលទ្ធភាពនេះ ត្រូវរាប់បញ្ចូលទាំងករណីដែលការអនុវត្តកាតព្វកិច្ចនោះ ត្រូវបានវាយតម្លៃថា មិនអាចធ្វើកើតតាមស្ថានភាពសង្គម ឬស្ថានភាពសេដ្ឋកិច្ច។[16]

ចំពោះអលទ្ធភាពក្នុងការអនុវត្ត ដែលបានកំណត់ក្នុងចំណុចខាងលើ បានបង្ហាញពីនិយមន័យនៃអលទ្ធភាពក្នុងការអនុវត្ត គឺសំដៅលើភាគីក្នុងកិច្ចសន្យាដែលជាអ្នកអនុវត្តកាតព្វកិច្ច ឬអ្នកអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យា នៅពេលដែលបុគ្គលនោះគ្មានលទ្ធភាពក្នុងការអនុវត្ត ដូច្នេះការអនុវត្តកាតព្វកិច្ចនឹងក្លាយជាអលទ្ធភាព ចំណុចនេះចង់បង្ហាញឱ្យឃើញថា កម្មវត្ថុនៃការផ្តល់តាវការលិកណាមួយដែលភាគីអ្នកអនុវត្តកាតព្វកិច្ចមិនអាចបំពេញបាននឹងកំណត់ថា អលទ្ធភាពសូម្បីតែការមិនអាចអនុវត្តបាននឹងត្រូវបានវាយតម្លៃតាមស្ថានភាពសង្គម ឬស្ថានភាពសេដ្ឋកិច្ចសុទ្ធតែកំណត់យកជាអលទ្ធភាពក្នុងការអនុវត្តទាំងអស់។

**កថាខណ្ឌទី១. អលទ្ធភាពវាយតម្លៃតាមស្ថានភាពសង្គម**

ការមិនអនុវត្តកាតព្វកិច្ចត្រូវបានវាយតម្លៃតាមស្ថានភាពសង្គម ភាគច្រើនមានលក្ខណៈខុសប្លែកគ្នាតាមស្ថានភាពកើតឡើងក្នុងសង្គមដូចជា បញ្ហាផ្សេងៗដែលធ្វើឱ្យមានការបំពានកាតព្វកិច្ច។ ជាក់ស្តែង បញ្ហារីករាលដាលវីរុសកូវីដ១៩ ក្នុងសហគមន៍កម្ពុជា «ព្រឹត្តិការណ៍២០ កុម្ភៈ ២០២១» បានធ្វើ**ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃវីរុសកូវីដ១៩**[17] និងបានកែសម្រួលបន្ថែមទៀតទៅលើសេចក្តីសម្រេចបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដែលបាន

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧,មាត្រា ៣៩៩ វាក្យខណ្ឌទី២។

[16] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៩២ កថាខណ្ឌទី១។

[17] សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៤៩សសរ, *ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩*, ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១។ (សូមមើលឧបសម្ព័ន្ធទី១)

ហាមឃាត់មិនឱ្យចេញពីទីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្នរបស់ខ្លួន ត្រង់ប្រការ២ និងប្រការ៣[18] ប្រសិនគ្មានការងារចំបាច់ដែលត្រូវបំពេញ។

ការបិទខ្ទប់នេះ ធ្វើឡើងដើម្បីបង្ការការរីកសាយភាយ រាលដាលក្នុងសហគមន៍ ប៉ុន្តែស្របពេលនោះក៏បង្កឱ្យមានផលប៉ះពាល់ដល់សកម្មភាពប្រចាំថ្ងៃ ក៏ដូចជាការងារមួយចំនួនត្រូវបានផ្អាកបណ្តោះអាសន្ន ក្នុងនោះបញ្ហាពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ច ក្នុងកិច្ចសន្យាមួយចំនួនបានកើតឡើងផងដែរ ដូចជាអាចបណ្តាលឱ្យមានការយឺតយ៉ាវក្នុងការអនុវត្ត ឬការបំពេញតាវកាលិកនៃកិច្ចសន្យាបានត្រឹមមួយផ្នែក ឬមិនពេញលេញ ដោយសារតែមានបម្រាមហាមឃាត់ឆ្លងពីខេត្តមួយទៅខេត្តមួយ និងមានបម្រាមគោលចរហាមឃាត់ការធ្វើដំណើរ ជាពិសេសប្រជាពលរដ្ឋក្នុងតំបន់បិទខ្ទប់ក្នុងរាជធានីភ្នំពេញ និងនៅក្រុងតាខ្មៅនៃខេត្តកណ្តាលគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីអនុវត្តតាមកិច្ចសន្យា ដោយហេតុថាក្នុងកំឡុងពេលបិទខ្ទប់នោះ ត្រូវបានហាមឃាត់ការធ្វើដំណើរចេញពីលំនៅឋាន សកម្មភាពការងារមួយចំនួនត្រូវបានហាមឃាត់ បើទោះបីជាការធ្វើដំណើរផ្សេងៗ ឬសកម្មភាពមួយចំនួនមិនមានការរារាំង ក៏ត្រូវអនុវត្តតាមវិធានការច្បាប់របស់រាជរដ្ឋាភិបាលយ៉ាងម៉ឺងម៉ាត់បំផុត មានន័យថាត្រូវមានលិខិតអនុញ្ញាត និងលិខិតបញ្ជាក់ការងារផ្សេងៗ។

ដូច្នេះ ករណីបំពេញការងារមួយចំនួនតូចដែលមិនអាចទទួលបានលិខិតអនុញ្ញាតក្នុងការបំពេញការងារនោះអាចប្រឈមមុខបាត់បង់ការងារ បាត់បង់ប្រាក់ខែជាហេតុនាំឱ្យមិនមានលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា (អាចជាកិច្ចសន្យាខ្ចីបរិភោគជាប្រាក់ ឬភតិសន្យាដែលជាកិច្ចសន្យាជួលបន្ទប់ស្នាក់នៅផងដែរ)។

ករណីមួយចំនួនធំនៃកម្មកររោងចក្រក្នុងរាជធានីភ្នំពេញ ជាប្រជាពលរដ្ឋចំណាកស្រុកពីខេត្តនានាទូទាំងប្រទេសមកធ្វើការនៅរាជធានីភ្នំពេញ និងបង្កើតភតិសន្យា (ជួលបន្ទប់ស្នាក់នៅ) កំឡុងពេលបិទខ្ទប់ រោងចក្រក៏ដូចជាកន្លែងបំពេញការងារមួយចំនួនត្រូវបានផ្អាកបណ្តោះអាសន្ន ឬបិទតែម្តងជាហេតុធ្វើឱ្យបុគ្គលិក កម្មករមិនមានលុយគ្រប់គ្រាន់ដើម្បីបង់ថ្លៃជួល នេះជាករណីអលទ្ធភាពក្នុងការអនុវត្តរបស់កូនបំណុលក្នុងភតិសន្យា។

ចំពោះ **កិច្ចសន្យាដឹកជញ្ជូន**[19]វិញ ទំនិញមួយចំនួនដែលមានការបន្ទាន់ភ្លាមខណៈពេលនោះមិនទាន់មានលិខិតអនុញ្ញាតពីអាជ្ញាធរ ក៏អាចបណ្តាលឱ្យខកខានដឹកអីវ៉ាន់ឱ្យភ្ញៀវផងដែរ ដែលអាចកំណត់ថាជាអលទ្ធភាពក្នុងការអនុវត្ត។

---

[18] សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៥០សសរ, *ស្តីពីការកែសម្រួលវិធានការដែលត្រូវអនុវត្តក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩*, ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១។ (សូមមើលឧបសម្ព័ន្ធទី២)

[19] **កិច្ចសន្យាដឹកជញ្ជូន** ជាកិច្ចសន្យាដែលអ្នកដឹកជញ្ជូនដឹកអ្នកដំណើរ ភារៈវត្ថុ ឬទំនិញពីកន្លែងមួយទៅកន្លែងមួយទៀតដោយយកថ្លៃតាមការព្រមព្រៀងឬតាមថ្លៃកំណត់របស់រដ្ឋ។ (ដកស្រង់ចេញពីក្រឹត្យច្បាប់លេខ៣៨, ស្តីពី កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា, មាត្រា ៨៣)

**កថាខណ្ឌទី២. អលទ្ធភាពវាយតម្លៃតាមស្ថានភាពសេដ្ឋកិច្ច**

ការមិនអនុវត្តកាតព្វកិច្ចត្រូវបានវាយតម្លៃតាមស្ថានភាពសេដ្ឋកិច្ច ជាករណីមួយដែលអាចវាយតម្លៃលើស្ថានភាពសេដ្ឋកិច្ចផ្ទាល់របស់អ្នកអនុវត្តកាតព្វកិច្ច យកមកធ្វើជាមូលហេតុនៃការសង្គ្រោះកិច្ចសន្យាថា តើមានលទ្ធភាពផ្នែកសេដ្ឋកិច្ចគ្រប់គ្រាន់ដែរឬទេ ដើម្បីបំពេញតាវកាលិកដែលស្របតាមខ្លឹមសារនៃកិច្ចសន្យានោះ? ជាក់ស្តែង ទាក់ទងនឹងកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ ដែលបានកំណត់ថានឹងត្រូវសង ៣ ខែក្រោយបន្ទាប់ពីកាលបរិច្ឆេទចុះកិច្ចសន្យា ប៉ុន្តែស្រាប់តែដល់ពេលនោះ សមាជិកគ្រួសាររបស់ភាគីអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា បានជួបគ្រោះថ្នាក់ចរាចរណ៍ ហើយត្រូវចំណាយលុយចំនួនច្រើនយកទៅព្យាបាល ធ្វើឱ្យភាគីនៃកិច្ចសន្យាលែងមានលុយ ដើម្បីសងដល់ភាគីឱ្យខ្ចីដែលជាកម្មវត្ថុនៃការផ្តល់តាវកាលិកតាមកិច្ចសន្យាដែលត្រូវសងតាមកាលបរិច្ឆេទនោះ គេកំណត់ថាជាអលទ្ធភាពនៃការអនុវត្តតាមស្ថានភាពសេដ្ឋកិច្ច។

រីឯចំណុចចុងក្រោយ គឺប្រសិនបើមិនអនុវត្តកាតព្វកិច្ចនៅពេលកំណត់ដែលត្រូវអនុវត្តមានពិតប្រាកដមុនពេលកំណត់ដែលត្រូវអនុវត្តនាំឱ្យ ការអនុវត្តកាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាពនៅពេលនោះ។[20]

ទាក់ទងនឹងស្ថានភាពមួយដែលភាគីកិច្ចសន្យាដែលជាអ្នកអនុវត្តកាតព្វកិច្ច នៅមុនពេលដែលដល់កាលបរិច្ឆេទអនុវត្តកាតព្វកិច្ច ប៉ុន្តែភាគីនោះគ្មានសមត្ថភាព និងលទ្ធភាពដើម្បីបំពេញតាមកម្មវត្ថុនៃការផ្តល់តាវកាលិកនៃកិច្ចសន្យា ទោះបីជាមិនទាន់ដល់ពេលអនុវត្តកាតព្វកិច្ចក៏ដោយ តាមក្រមរដ្ឋប្បវេណី មាត្រា ៣៩២ កថាខណ្ឌទី២ បានកំណត់ជាអលទ្ធភាពក្នុងការអនុវត្តផងដែរ។ ជាក់ស្តែងក្នុងកិច្ចសន្យាលក់ទិញ ដែលមានចែងក្នុងមាត្រា ៥១៥[21] នៃក្រមរដ្ឋប្បវេណី ដែលខ្លឹមសារនៃកិច្ចសន្យាបានកំណត់ដោយភាគីក្នុងកិច្ចសន្យា ចំពោះការលក់ទិញដែលមានកម្មវត្ថុជាវត្ថុជាក់លាក់ណាមួយដូចជាវត្ថុបុរាណ ដែលបានកំណត់ដូចមានកិច្ចសន្យាហើយបានកំណត់កាលបរិច្ឆេទ និងទីកន្លែងដើម្បីប្រគល់វត្ថុនោះ ប៉ុន្តែ មុនកាលបរិច្ឆេទកំណត់អនុវត្តកាតព្វកិច្ចរបស់អ្នកលក់ ស្រាប់តែវត្ថុនោះត្រូវបែកខូចខាត បើទោះបីជាមិនទាន់ដល់ពេលកំណត់ក៏ដោយ ក៏ធ្វើឱ្យការអនុវត្តកាតព្វកិច្ចរបស់ភាគីអ្នកលក់មិនអាចអនុវត្តបាន ក្លាយទៅជាអលទ្ធភាពក្នុងការអនុវត្តដែលជាមូលហេតុនៃការសង្គ្រោះលើកិច្ចសន្យា ដោយសារតែកម្មវត្ថុនៃការផ្តល់តាវកាលិកក្នុងកិច្ចសន្យាលក់ទិញនោះជាវត្ថុជាក់លាក់មិនអាចប្តូរ ឬជំនួសបានឡើយ ។

[20] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៩២ កថាខណ្ឌទី២។

[21] **ការលក់ទិញ** សំដៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា អ្នកលក់មានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិ ឱ្យភាគីម្ខាងទៀតហៅថាអ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចចេញថ្លៃជាប្រាក់ឱ្យអ្នកលក់។ (ដកស្រង់ចេញពី ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៥១៥)

## ផ្នែកទី៥. ករណីផ្សេងៗនៃការមិនអនុវត្តកាតព្វកិច្ច ឬគ្មានការអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យា

ត្រង់ផ្នែកនេះ នឹងបកស្រាយទាក់ទងនឹងការបំពាន ឬការមិនអនុវត្តកាតព្វកិច្ចផងដែរ ដែលមានលក្ខណៈផ្ទុយពីបញ្ញត្តិនៃការមិនអនុវត្តកាតព្វកិច្ចផ្សេងទៀតដែលចែងក្នុងមាត្រា ៣៩១ មាត្រា ៣៩២ មាត្រា ៣៩៣ នៃក្រមរដ្ឋប្បវេណី មានន័យថាប្រសិនបើមានករណីផ្សេងៗទៀតដែលបញ្ញត្តិនៃការយឺតយ៉ាវក្នុងការអនុវត្ត ការអនុវត្តកាតព្វកិច្ចមិនពេញលេញ អលទ្ធភាពក្នុងការអនុវត្ត មិនអាចគ្របដណ្តប់ទៅលើសកម្មភាពនៃការបំពានកិច្ចសន្យាបាន នោះនឹងយកមាត្រា ៣៩៤ នៃក្រមរដ្ឋប្បវេណីមកធ្វើជាមូលហេតុនៃការសង្គ្រោះកិច្ចសន្យាវិញ។ ក្រៅពីបញ្ញត្តិនៃមាត្រា ៣៩១ (ការយឺតយ៉ាវក្នុងការអនុវត្ត) មាត្រា ៣៩២ (អលទ្ធភាពក្នុងការអនុវត្ត) និងមាត្រា ៣៩៣ (ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ) នៃក្រមនេះ ករណីដែលមានការបំពានករណីយកិច្ចផ្សេងៗ ដែលកើតឡើងពីកិច្ចសន្យា ក៏ត្រូវចាត់ជាការមិនអនុវត្តកាតព្វកិច្ចដែរ។[22]

ដូច្នេះ ការបំពានកិច្ចសន្យាក្នុងទម្រង់នៃករណីផ្សេងៗទៀត មានន័យថាក្រៅពីបញ្ញត្តិនៃមាត្រា ៣៩១ មាត្រា ៣៩២ មាត្រា ៣៩៣ នៃក្រមរដ្ឋប្បវេណី បើមានករណីការបំពានលើកិច្ចសន្យា ឬមិនអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យាកើតឡើង នោះអាចចាត់ទុកថាជាកាមិនអនុវត្តកាតព្វកិច្ចផងដែរ ឬអាចនិយាយម៉្យាងទៀតថា បញ្ញត្តិនៃមាត្រា ៣៩៤ នេះមិនមានភាពចាំបាច់ឡើយ បើមានបញ្ញត្តិទូទៅ (ការយឺតយ៉ាវក្នុងការអនុវត្ត អលទ្ធភាពក្នុងការអនុវត្ត ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ) អាចគ្របដណ្តប់លើសកម្មភាពដែលទាក់ទងនឹងការមិនអនុវត្តកាតព្វកិច្ចនោះ ប៉ុន្តែបើបញ្ញត្តិទូទៅនេះមិនអាចគ្របដណ្តប់លើគ្រប់សកម្មភាពនៃការមិនអនុវត្តកាតព្វកិច្ចបានទេ អាចមានករណីមួយចំនួនផងដែរ។ ម៉្យាងវិញទៀត បើមានករណីមួយចំនួននោះកើតឡើងដែលមិនស្ថិតក្រោមបញ្ញត្តិទូទៅក្នុងមាត្រា ៣៩១ មាត្រា ៣៩២ មាត្រា ៣៩៣ នៃក្រមរដ្ឋប្បវេណី នោះទើបមានបញ្ញត្តិនៃមាត្រា ៣៩៤ នេះដើម្បីផ្តល់នូវមធ្យោបាយចុងក្រោយដើម្បីជួយសង្គ្រោះចំពោះកិច្ចសន្យា ទាក់ទងនឹងសកម្មភាពអ្នកបំពានលើកិច្ចសន្យា នោះអាចមានហេតុផលយ៉ាងគ្រប់គ្រាន់ដើម្បីធ្វើជាមូលហេតុឱ្យអ្នកអនុវត្តកាតព្វកិច្ចនោះទទួលខុសត្រូវដោយស្របច្បាប់។ ឧទាហរណ៍ ក្នុងខ្លឹមសារមួយចំនួននៃកិច្ចសន្យាលក់ទិញមួយ ដែលភាគីបានព្រមព្រៀងកំណត់ដូចជា ភាគីអ្នកទិញត្រូវប្រគល់ប្រាក់ជាប្រភេទដុល្លារ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២១ ប៉ុន្តែ មកដល់កាលបរិច្ឆេទប្រគល់ប្រាក់ភាគីអ្នកទិញបានប្រគល់ប្រាក់រៀលទៅវិញ។ ត្រង់ចំណុចនេះបើទោះបីជាមិនមែនជាការបំពានកាតព្វកិច្ចធ្ងន់ធ្ងរ ប៉ុន្តែភាគីអ្នកទិញបានបំពានខ្លឹមសារមួយនៃកិច្ចសន្យាក្នុងចំណោមខ្លឹមសារផ្សេងៗទៀត ដែលភាគីទាំងពីរបានព្រមព្រៀងគ្នា ករណីនេះក៏អាចកំណត់ថាជាការបំពានកិច្ចសន្យាផងដែរ។

[22] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៩៤។

# ជំពូកទី២

# ការដោះស្រាយតាមរយៈការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ

# ជំពូកទី២

# ការដោះស្រាយតាមរយៈការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ

ជាការចាប់ផ្ដើមនៃការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ ឃើញថាមានមូលហេតុជាច្រើនដែលបណ្ដាលឱ្យភាគីម្ចាស់បំណុលជ្រើសរើសវិធីសង្គ្រោះកិច្ចសន្យាមួយនេះ ក្នុងចំណោមវិធីសង្គ្រោះកិច្ចសន្យាផ្សេងទៀត។ ប៉ុន្តែម្ចាស់បំណុលត្រូវបានអនុញ្ញាតឱ្យជ្រើសរើសមធ្យោបាយសង្គ្រោះលើសពីមួយ កុំឱ្យតែមធ្យោបាយទាំងនោះមានលក្ខណៈផ្ទុយគ្នា។[23]

## ផ្នែកទី១. សញ្ញាណនៃការអនុវត្តដោយបង្ខំ

ក្នុងករណីភាគីកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ភាគីម្ចាស់បំណុលអាចដាក់ពាក្យបណ្ដឹងដើម្បីឱ្យតុលាការចេញសាលក្រម ឬសាលដីកាស្ថាពរដែលបង្គាប់ឱ្យផ្ដល់តាវកាលិក។ បន្ទាប់ពីសាលក្រម ឬសាលដីកាសម្រេចនូវសិទ្ធិទាមទារនោះចូលជាស្ថាពរ កូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តទេ ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំបាន លើកលែងតែករណីដែលកាតព្វកិច្ចមានលក្ខណៈមិនអាចអនុវត្តដោយបង្ខំបាន។[24]

ការអនុវត្តដោយបង្ខំ គឺជានីតិវិធីតាមផ្លូវតុលាការក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ ដែលបានកំណត់នៅក្នុងនីតិឯកជនដោយប្រើអំណាចរបស់រដ្ឋ។[25]

ការអនុវត្តដោយបង្ខំ ជានីតិវិធីឯករាជ្យ មិនមែនជានីតិវិធីបន្ទាប់ ឬបន្តពីនីតិវិធីបណ្ដឹងទេ វាចាប់ផ្ដើមដោយការដាក់ពាក្យសុំដោយម្ចាស់បំណុលដែលត្រូវការឱ្យមានការសម្រេចសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ។[26]

មួយវិញទៀត ការអនុវត្តដោយបង្ខំ ជានីតិវិធីមួយអនុញ្ញាតបុគ្គលដែលមានសិទ្ធិទាមទារ សិទ្ធិប្រាតិភោគដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀតធ្វើការសម្រេចសិទ្ធិនោះដោយការអនុវត្តដោយបង្ខំ។[27]

---

[23] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៩៥។

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៩៦។

[25] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ស្តីពី «ការអនុវត្តដោយបង្ខំ និងកាចាត់ចែងរក្សាការពារ»*, ឆ្នាំ២០០៩, ទំព័រ ១១។

[26] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ស្តីពី «ការអនុវត្តដោយបង្ខំ និងកាចាត់ចែងរក្សាការពារ»*, ឆ្នាំ២០០៩, ទំព័រ ២។

[27] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី, *ដកស្រង់ពីសទ្ទានុក្រមច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី*, ឆ្នាំ២០០៧។

## ផ្នែកទី២. ការដាក់ពាក្យសុំអនុវត្តដោយបង្ខំ

ពាក្យសុំអនុវត្តដោយបង្ខំត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរព្រមទាំងបញ្ជាក់នូវចំណុចដូចខាងក្រោម៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណនៃលិខិតអនុវត្ត
- សេចក្តីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល
- សញ្ញាណនៃទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនិងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់
- ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំអោយអនុវត្តដោយបង្ខំ តាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំ សុំអនុវត្តបង្ខំនៃផ្នែកណាមួយនៃសិទ្ធិទាមទារដែលសរសេរនៅក្នុងលិខិតអនុវត្ត បង្គាប់ឱ្យសងជាប្រាក់ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និងទំហំនៃសេចក្តីសុំនោះក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ។[28]

### កថាខណ្ឌទី១. អ្នកដាក់ពាក្យសុំ

ស្ថាប័នអនុវត្តមានសមត្ថកិច្ចអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុវត្តតាមពាក្យសុំរបស់ភាគី[29]។ ចំណែកឯវិសាលភាពនៃអ្នកដែលអាចអនុវត្តដោយបង្ខំអាចធ្វើបានដោយចង្អុលអ្នកដែលបានកំណត់ខាងក្រោមនេះ ជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្ត៖

- ភាគីដែលបញ្ជាក់នៅក្នុងលិខិតអនុវត្ត
- តតិយជនក្នុងករណីភាគីដែលត្រូវបានបញ្ជាក់ក្នុងលិខិតអនុវត្តធ្វើជាភាគីសម្រាប់តតិយជននោះ
- អ្នកដែលទទួលសិទ្ធិបន្ត ឬករណីយកិច្ចពីបុគ្គលដែលជាភាគីបញ្ជាក់នៅក្នុងលិខិតអនុវត្តនិងតតិយជនក្នុងករណី ភាគីដែលត្រូវបានបញ្ជាក់ក្នុងលិខិតអនុវត្តធ្វើជាភាគីសម្រាប់តតិយជននោះក្រោយលិខិតអនុវត្តនោះត្រូវបានធ្វើឡើង។[30]

---

[28] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៣៤៩។

[29] **ភាគី** ក្នុងន័យនេះសំដៅទៅលើម្ចាស់បំណុលនៃការអនុវត្ត។ (ដកស្រង់ចេញពី ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ស្តីពី «ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ»* ឆ្នាំ២០០៩, ទំព័រ ៣៤)

[30] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៣៥១។

## កថាខណ្ឌទី២. ស្ថាប័នមានសមត្ថកិច្ចទទួលពាក្យ

ទីកន្លែងដែលត្រូវដាក់ពាក្យអនុវត្តដោយបង្ខំ គឺជាស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច (តុលាការអនុវត្ត ឬ អាជ្ញាសាលា)។[31] ស្ថាប័នអនុវត្ត សំដៅដល់ស្ថាប័នដែលមានសមត្ថភាពទទួលបន្ទុកកាន់អំណាចធ្វើការអនុវត្តដោយបង្ខំដែលជាអំណាចរបស់រដ្ឋ។ ដោយសារតែនីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជានីតិវិធីដាច់ដោយឡែក និងឯករាជ្យពីនីតិវិធីបណ្តឹង ដូច្នេះវាមិនចាំបាច់តុលាការដែលទទួលពាក្យបណ្តឹងត្រូវតែជាស្ថាប័នអនុវត្តទេ។ ផ្ទុយទៅវិញ ដោយគិតអំពីតម្រូវការនៃភាពងាយស្រួល និងឆាប់រហ័ស ការដាក់បន្ទុកទៅឱ្យស្ថាប័នមួយផ្សេងទៀតគឺជាការសមស្រប។ ហេតុដូច្នេះ បានជាច្បាប់បានចែងឱ្យតុលាការអនុវត្ត និងអាជ្ញាសាលាធ្វើជាស្ថាប័នអនុវត្ត។[32]

ស្ថាប័នអនុវត្តមានសមត្ថកិច្ចអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយ ស្ថាប័នអនុវត្តតាមពាក្យសុំរបស់ភាគី។ ស្ថាប័នអនុវត្ត គឺជាតុលាការអនុវត្ត ឬអាជ្ញាសាលា។ សាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំ គឺជាតុលាការអនុវត្ត។ ការសម្រេចសេចក្តីអំពីបណ្តឹងឧបាស្រ័យ ចំពោះការចាត់ចែងការអនុវត្តដែលធ្វើឡើងដោយសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ។[33] តុលាការអនុវត្ត និងអាជ្ញាសាលា គឺជាស្ថាប័នឯករាជ្យនៃអំណាចតុលាការ។ ស្ថាប័នទាំងពីរនេះមានចរិតលក្ខណៈផ្សេងពីគ្នា ហេតុនេះហើយបានជាច្បាប់ដាក់បន្ទុកការងារផ្សេងគ្នាឱ្យស្ថាប័ននីមួយៗ ដោយអាស្រ័យតាមកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងទៅតាមប្រភេទបែបបទនៃការអនុវត្តជាអាទិ៍។[34]

### ១. តុលាការអនុវត្ត

**តុលាការអនុវត្ត** គឺជាសាលាដំបូងដែលមានសមត្ថកិច្ចនៅក្នុងការអនុវត្តដោយបង្ខំ។[35]

សមត្ថកិច្ចរបស់តុលាការអនុវត្តក្នុងករណីដូចជា៖

- ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល នៅចំណុចនេះផងដែរ តុលាការអនុវត្ត អនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ឬក៏ប្រគល់ចលនវត្ថុ។[36]

---

[31] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៣៣១ កថាខណ្ឌទី២។

[32] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ស្តីពី «ការអនុវត្តដោយបង្ខំ និងកាចាត់ចែងរក្សាការពារ»*, ឆ្នាំ២០០៩, ទំព័រ ១៣។

[33] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៣៣៦។

[34] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ស្តីពី «ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ»*, ឆ្នាំ២០០៩, ទំព័រ ១៣។

[35] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៣៣៦ កថាខណ្ឌទី៣។

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤០២ កថាខណ្ឌទី១។

- ការអនុវត្តដោយបង្ខំ និងអនុវត្តសិទ្ធិលើប្រាតិភោគចំពោះអចលនវត្ថុក្នុងករណីនេះមានបែងចែកសមត្ថកិច្ចអនុវត្តសិទ្ធិប្រាតិភោគ ចំពោះអចលនវត្ថុរវាងសាលាដំបូងមានសមត្ថកិច្ចលើទីកន្លែងអចលនវត្ថុ និងសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងចុះបញ្ជី។[37]
- ការអនុវត្តដោយបង្ខំ និងការអនុវត្តសិទ្ធិចំពោះនាវា គឺតុលាការអនុវត្តលើទីកន្លែងដែលនាវាស្ថិតនៅមានសមត្ថកិច្ចចេញដីកាសម្រេចចាប់ផ្តើមអនុវត្តបង្ខំ។[38]
- ការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុ ក្នុងករណីវត្ថុដែលជាកម្មវត្ថុត្រូវបានកាន់កាប់ដោយតតិយជន ក្នុងករណីនេះ តុលាការអនុវត្តមានសមត្ថកិច្ចចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្តប្រើសិទ្ធិទាមទារតាមរយៈ ការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុត្រូវបានធ្វើដែលតុលាការតាមវិធីអនុវត្តរឹបអូសសិទ្ធិទាមទារឱ្យប្រគល់របស់កូនបំណុលនៃការអនុវត្តដែលមានចំពោះតតិយជន។[39]
- ការអនុវត្តដោយបង្ខំចំពោះកាតព្វកិច្ចដែលមានគោលបំណងឱ្យធ្វើឬមិនឱ្យធ្វើសកម្មភាពណាមួយ ក្នុងករណី នេះតុលាការអនុវត្តមានសមត្ថកិច្ចចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្តឱ្យតតិយជនបំពេញសកម្មភាពនោះជំនួសដោយប្រើសោហ៊ុយរបស់កូន បំណុលនៃការអនុវត្ត ឬចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តបង់នូវចំនួនទឹកប្រាក់ ជាការកំណត់ទទួលស្គាល់ថាសមរម្យដើម្បីធានាអនុវត្តកាតព្វកិច្ចទៅឱ្យម្ចាស់បំណុល នៃការអនុវត្តដោយភ្លាមៗ បើពុំបានអនុវត្តក្នុងអំឡុងពេលនោះ។[40]

### ២. អាជ្ញាសាលា

**អាជ្ញាសាលា** គឺជាស្ថាប័នយុត្តាធិការឯករាជ្យមួយ ដែលទទួលបន្ទុកធ្វើការបញ្ជូលឯកសារនានាដែលចេញដោយតុលាការ និងធ្វើការអនុវត្តដោយបង្ខំមួយចំនួនដែលច្បាប់បានកំណត់។[41] អាជ្ញាសាលា ជាមន្ត្រីរាជការដែលទទួលបាន ការតែងតាំងដោយប្រកាសរបស់ក្រសួងយុត្តិធម៌ចេញពីក្នុងចំណោម បុគ្គលដែលបានបំពេញគ្រប់លក្ខខណ្ឌទាមទារមួយចំនួន។[42] សមត្ថកិច្ចរបស់អាជ្ញាសាលាមានដូចជា៖

[37] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤១៨។

[38] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤៥៦។

[39] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៥២៦។

[40] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៥២៧។

[41] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ ស្តីពី «ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ»*, ឆ្នាំ២០០៩, ទំព័រ ១៥។

[42] ក្រុមប្រឹក្សាអ្នកច្បាប់ និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីព្រាងលើកទី៣ *ច្បាប់ស្តីពីអាជ្ញាសាលា,* មាត្រា ៤ ។

- ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ នៅក្នុងចំណុចនេះត្រូវធ្វើទៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំនោះស្ថិតនៅនិងមានសមត្ថកិច្ចដូចជាត្រូវចាប់ផ្ដើមដោយការរឹបអូសវត្ថុដែលជាកម្មវត្ថុ ឬត្រូវដាស់តឿនឱ្យកូនបំណុលនៃការអនុវត្តនោះសងដោយស្ម័គ្រចិត្តនៅមុនពេលចាប់ផ្ដើមរឹបអូស និងសមត្ថកិច្ចរបស់អាជ្ញាសាលាអាចក្នុងការទទួលសំណងនៃបំណុលនិងសំណងសោហ៊ុយសម្រាប់អនុវត្តដើម្បីម្ចាស់បំណុលនៃការអនុវត្តបាន។[43]
- ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ក្នុងករណីទោះបីជាម្ចាស់បំណុលនៃការអនុវត្តមិនដាក់លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិភោគដែលកំណត់ក្នុងមាត្រា ៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីទៅអាជ្ញាសាលាក៏ដោយបើបានដាក់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ឬបានដាក់ឯកសារដែលបញ្ជាក់ថាអ្នកកាន់កាប់ចលនវត្ថុបានយល់ព្រម ចំពោះការរឹបអូសក៏ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុអាចចាប់បានដែរ។[44]
- ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ គឺសំដៅដល់សមត្ថកិច្ចអាជ្ញាសាលាលើកន្លែងដែលវត្ថុជាកម្មវត្ថុស្ថិតនៅ រំលាយការកាន់កាប់វត្ថុ ហើយធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្តទទួលបាននូវការកាន់កាប់នោះ។[45]
- ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ គឺសំដៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងលើវត្ថុដែលជាកម្មវត្ថុស្ថិតនៅ ដកយកចលនវត្ថុពីកូនបំណុលនៃការអនុវត្ត ហើយប្រគល់ចលនវត្ថុនោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។[46]

## ផ្នែកទី៣. កម្មវត្ថុនៃសិទ្ធិទាមទារ

នៅក្នុងសាលក្រម ឬសាលដីកាស្ថាពរដែលសម្រេចនូវសិទ្ធិទាមទាររបស់ភាគីម្ចាស់បំណុល សង្កេតឃើញមាន ករណីខ្លះជាការទាមទារឱ្យសងជាប្រាក់ស្របទៅតាមកិច្ចសន្យា ដូចជាកិច្ចសន្យាខ្ចីបរិភោគដែលភ្ជាប់ការប្រាក់ ឬករណីខ្លះទៀតជាការទាមទារឱ្យប្រគល់វត្ថុណាមួយ អាចជាចលនវត្ថុ ឬអចលនវត្ថុជាដើម។ ដូច្នេះធ្វើឱ្យនីតិវិធីនៃការអនុវត្តដោយបង្ខំ អាចមានកម្មវត្ថុពីរយ៉ាង នោះគឺការទាមទារដែលមានគោលបំណងសងជាប្រាក់ និងមិនមែនជាប្រាក់។

---

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៣៨៤។

[44] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៥០០។

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៥២៤ កថាខណ្ឌទី១ ។

[46] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៥២៥ កថាខណ្ឌទី១ ។

**កថាខណ្ឌទី១. កម្មវត្ថុនៃសិទ្ធិទាមទារមានគោលបំណងសងជាប្រាក់**

ក្នុងចំណោមការអនុវត្តដោយបង្ខំជាច្រើនប្រភេទ ការអនុវត្តដើម្បីប្រមូលប្រាក់ដោយបង្ខំ ពីទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីសម្រេចនូវសិទ្ធិទាមទារដែលមានគោលបំណងសងជាប្រាក់ ហៅថាការអនុវត្តចំពោះសិទ្ធិទាមទារដែលមានគោលបំណងសងជាប្រាក់។[47]

ចំពោះកម្មវត្ថុនៃសិទ្ធទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលទាមទារពីភាគីកូនបំណុលនៃការអនុវត្តឱ្យសងជាប្រាក់ នោះការអនុវត្តដោយបង្ខំត្រូវមាននីតិវិធីដូចខាងក្រោម៖

**១. ចលនវត្ថុ**

ចំពោះ**ចលនវត្ថុ**[48] ពាក្យសុំអនុវត្តដោយបង្ខំ ត្រូវធ្វើទៅអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ច លើទីកន្លែង ដែលវត្ថុជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំស្ថិតនៅ។[49] បន្ទាប់មកទៀត អាជ្ញាសាលាត្រូវធ្វើការចុះរឹបអូសចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត[50] ដែលកាន់កាប់ ឬក្រៅពីកូនបំណុលនៃការអនុវត្តក្នុងករណីដែលតតិយជននោះមិនបដិសេធអំពីការប្រគល់។

នៅពេលការរឹបអូសចលនវត្ថុនោះបានជោគជ័យ គឺជាពេលមួយដែលអាជ្ញាសាលាចាប់ផ្ដើមធ្វើការដាក់លក់ចលនវត្ថុនោះ។ ដើម្បីធ្វើការលក់ចលនវត្ថុដែលត្រូវបានរឹបអូស អាជ្ញាសាលាត្រូវលក់តាមវិធីលក់ឡាយឡុងដោយផ្ទាល់មាត់ ឬដោយដាក់ស្រោមសំបុត្រ។[51] លើសពីនេះប្រាក់ដែលទទួលបានពីការលក់ចលនវត្ថុនោះ អាជ្ញាសាលាត្រូវធ្វើទុកនៅសាលាដំបូងដែលខ្លួនស្ថិតនៅ។[52] ឈានដល់ការចែកចំណែក ក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានពីការលក់ ឬប្រាក់ដែលបានពីការរឹបអូស អាចសងចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗ និងសោហ៊ុយសម្រាប់ការ

[47] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌, *សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ស្ដីពី «ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ»*, ឆ្នាំ២០០៩, ទំព័រ ៨០។

[48] **ចលនវត្ថុ** សំដៅលើវត្ថុក្រៅពីអចលនវត្ថុ ចំពោះទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន លើកលែងតែមានបញ្ញត្តិក្នុងច្បាប់ពិសេស ផលធម្មជាតិដែលមិនទាន់បំបែកពីលើដីនៅឡើយ ហើយអាចនឹងទទួលផលយ៉ាងច្បាស់ នៅកំឡុងពេលមួយខែ ក្រដាសប្រាក់កាក់ប្រាក់ ដែលមិនទាមទារឱ្យមាននីតិវិធីនៃការប្ដូរជាប្រាក់។

[49] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៣៨៤ កថាខណ្ឌទី១។

[50] ការរឹបអូសចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត មិនមែនគ្រប់ចលនវត្ថុទាំងអស់សុទ្ធតែអាចរឹបអូសបាននោះទេ ចំពោះប្រដាប់ស្លៀកពាក់ គ្រឿងបរិភោគ ឯកសារ ឧបករណ៍ចាំបាច់សម្រាប់ការសិក្សានៅសាលាជាដើម គឺមិនអាចត្រូវរឹបអូសឡើយ។ (ដកស្រង់ចេញពី ក្រមនីតិវិធីរដ្ឋប្បវេណី, មាត្រា ៣៨០)

[51] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៣៩៥ កថាខណ្ឌទី១។

[52] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៣៩៧ កថាខណ្ឌទី២។

អនុវត្តទាំងអស់បាន អាជ្ញាសាលាត្រូវចែកចំណែក ចំពោះម្ចាស់បំណុល ហើយត្រូវប្រគល់ប្រាក់នៅសេសសល់ទៅឱ្យកូនបំណុលនៃការអនុវត្តវិញ។[53]

**២. អចលនវត្ថុ**

ស្ថាប័នអនុវត្តដែលមានសមត្ថកិច្ចអនុវត្តដោយបង្ខំចំពោះ**អចលនវត្ថុ**[54] គឺខុសពីចលនវត្ថុដែលចំពោះចលនវត្ថុគឺជាសមត្ថកិច្ចរបស់អាជ្ញាសាលានៃសាលាដំបូង។ រីឯអចលនវត្ថុ គឺជាសមត្ថកិច្ចរបស់តុលាការអនុវត្តដែលបានកំណត់ដូចខាងក្រោម៖

- បើយកដី ឬអគារដែលបានចុះបញ្ជី ជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនោះ។
- បើយកចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬលើអគារដែលបានចុះបញ្ជី ឬសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគដែលបានចុះបញ្ជី ឬចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួមជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលត្រូវចុះបញ្ជី។[55]
- ចំពោះនីតិវិធីនៃការរឹបអូសអចលនវត្ថុត្រូវបានប្រកាសនៅពេលមានដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំនិងត្រូវបញ្ជូនដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំនេះទៅឱ្យកូនបំណុលនៃការអនុវត្ត។[56]

ការលក់ដោយបង្ខំនឹងត្រូវអនុវត្តបន្ទាប់ពីការឹបអូស ដែលជាវិធីអនុវត្តចំពោះអចលនវត្ថុដែលតាមរយៈ នោះតុលាការអនុវត្តរឹបអូសចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល រួចលក់អចលនវត្ថុនោះដោយបង្ខំ ហើយទើបយកប្រាក់ដែលបានមកពីការលក់នោះ ទៅសម្រេចសិទ្ធិទាមទារដែលមានគោលបំណងសងជាប្រាក់ឱ្យទៅម្ចាស់បំណុលនៃការអនុវត្ត។ ការលក់ដោយបង្ខំចាប់ផ្ដើមដោយ ដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ ដែលតុលាការចេញតាមពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ របស់ម្ចាស់បំណុលនៃការអនុវត្ត។[57]

---

[53] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៣៩៩ កថាខណ្ឌទី១។

[54] **អចលនវត្ថុ** សំដៅលើដី អគារ ដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤១៨។

[56] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤១៩។

[57] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤១៩ កថាខណ្ឌទី១។

នីតិវិធីបន្ទាប់ គឺជាការសងប្រាក់ដែលបានមកពីការលក់អចលនវត្ថុនោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ប៉ុន្តែក្នុងករណីដែលមានការទាមទារឱ្យចែកចំណែក[58] ពីម្ចាស់បំណុលផ្សេងទៀត ក៏ត្រូវបានអនុញ្ញាតផងដែរ និងត្រូវគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

### ៣. សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងៗ

ចំពោះសិទ្ធិលើបំណុល ពុំមានមាត្រាណានៃច្បាប់ណាមួយចែងអំពីនិយមន័យរបស់វានោះទេ ប៉ុន្តែសិទ្ធិលើបំណុល និងកាតព្វកិច្ចគឺមានលក្ខណៈស្រដៀង និងមានទំនាក់ទងគ្នា។ នៅក្នុងកិច្ចសន្យាមួយ ភាគីម្ខាងដែលទទួលបានផលប្រយោជន៍ ហៅថាម្ចាស់បំណុល ដែលមានសិទ្ធិទាមទារឱ្យកូនបំណុលធ្វើ ឬមិនធ្វើសកម្មភាពអ្វីមួយមកឱ្យខ្លួន។ ឧទាហរណ៍ A ជាអ្នកលក់ និង B ជាអ្នកទិញ នោះ A មានសិទ្ធិលើបំណុលទៅលើ B ដែលឱ្យ B បង់ប្រាក់នៃថ្លៃទិញមកឱ្យខ្លួន ចំពោះ B ក៏មានសិទ្ធិលើបំណុលចំពោះ A វិញដែរ ដែលអាចឱ្យប្រគល់វត្ថុ ឬផ្ទេរកម្មសិទ្ធិ និងការកាន់កាប់មកឱ្យខ្លួន។[59]

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជាការអនុវត្តដោយបង្ខំដើម្បីសម្រេចនូវសិទ្ធិទាមទារដែលមានកម្មវត្ថុជាការសងប្រាក់ ឬជាការប្រគល់ចលនវត្ថុរបស់កូនបំណុលហើយប្តូរជាប្រាក់នូវតម្លៃសេដ្ឋកិច្ចសិទ្ធិលើបំណុលនោះ។[60]

ស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច លើការអនុវត្តចំពោះសិទ្ធិលើបំណុល គឺជាសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលនៃការអនុវត្ត (សមត្ថកិច្ចសាលាជម្រះក្តីដែលបានកំណត់តាមលំនៅឋាន) គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ច ប៉ុន្តែបើគ្មានទីកន្លែងនេះទេ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់**កូនបំណុលទី៣**[61] គឺជាតុលាការអនុវត្តដែលមានសមត្ថកិច្ចវិញ)។[62]

---

[58] ការទាមទារឱ្យចែកចំណែក គឺជានីតិវិធីចូលរួមក្នុងនីតិវិធីលក់ដោយបង្ខំដែលកំពុងត្រូវបានចាប់ផ្តើម ដើម្បីទទួលការចែកចំណែក នៃម្ចាស់បំណុលក្រៅពីម្ចាស់បំណុលនៃការអនុវត្ត។ (ដកស្រង់ចេញពីសាស្ត្រាចារ្យHIGASHIO Kazuyuki និងសាស្ត្រាចារ្យ YUKAWA Ryo, *អត្ថបទស្លាយ អំពី ការអនុវត្តដោយបង្ខំ ការលក់ដោយបង្ខំនូវអចលនវត្ថុ*, ទំព័រ ៨៨)

[59] គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ នៃក្រសួងយុត្តិធម៌ រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, *ដកស្រង់ចេញពី មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១* , ទំព័រ ១ និងទំព័រ ២។

[60] សាស្ត្រាចារ្យHIGASHIO Kazuyuki និងសាស្ត្រាចារ្យ YUKAWA Ryo, *អត្ថបទស្លាយ អំពី ការអនុវត្តដោយបង្ខំ (ការលក់ដោយបង្ខំនូវអចលនវត្ថុ)*, ទំព័រ ៩២។

[61] កូនបំណុលនៃសិទ្ធិលើបំណុលដែលនឹងត្រូវរឹបអូស ហៅថាកូនបំណុលទី៣។ (ដកស្រង់ចេញពីក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤០២ កថាខណ្ឌទី២)

[62] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤០២ កថាខណ្ឌទី៣។

ការចាប់ផ្តើមអនុវត្តចំពោះសិទ្ធិលើបំណុលត្រូវចាប់ផ្តើម ដោយដីកាសម្រេចរឹបអូសរបស់តុលាការអនុវត្ត។[63]

ការអនុវត្តចំពោះសិទ្ធិលើបំណុល មានអានុភាពនៅពេលដែលដីកាសម្រេចរឹបអូសរបស់តុលាការអនុវត្ត បានបញ្ជូនដល់កូនបំណុលទី៣។

ចំពោះម្ចាស់បំណុលនៃការអនុវត្ត ដែលបានរឹបអូសសិទ្ធិលើបំណុលដែលមានគោលបំណងសងប្រាក់ (បំណុលដែលត្រូវប្រមូលសងជាប្រាក់) អាចប្រមូលបំណុលនោះបាន បើ ១សប្តាហ៍កន្លងហួស ក្រោយពីថ្ងៃដែលដីកាសម្រេចការឹបអូសត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត។ ប៉ុន្តែម្ចាស់បំណុលនៃការអនុវត្តនោះ មិនអាចទទួលការសងលើសតម្លៃនៃសិទ្ធិលើបំណុលរបស់ខ្លួន និងសោហ៊ុយសម្រាប់ការអនុវត្តឡើយ។[64] ដោយឡែកចលនវត្ថុវិញ ម្ចាស់បំណុលអាចអនុវត្តសិទ្ធិទាមទារឱ្យកូនបំណុលទី៣ ប្រគល់វត្ថុដែលជាកម្មវត្ថុនៃការរឹបអូសទៅអាជ្ញាសាលាដែលទទួលពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត បើអំឡុងពេល ១សប្តាហ៍ បានកន្លងហួស ដោយគិតពីថ្ងៃដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត។ បន្ទាប់មកទៀត អាជ្ញាសាលាមានសមត្ថកិច្ចយកចលនវត្ថុនោះលក់ និងប្រគល់ប្រាក់ទៅតុលាការអនុវត្តវិញ។[65]

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេង ក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និងសិទ្ធិលើបំណុល ត្រូវអនុវត្តតាមវិធីអនុវត្តចំពោះសិទ្ធិលើបំណុល លើកលែងតែមានបញ្ញត្តិពិសេស។[66]

## កថាខណ្ឌទី២. កម្មវត្ថុនៃសិទ្ធិទាមទារគ្មានគោលបំណងសងជាប្រាក់

នៅក្នុងកម្មវត្ថុនៃសិទ្ធិទាមទារដែលគ្មានគោលបំណងសងជាប្រាក់ គឺត្រូវបានអនុវត្តទៅលើចលនវត្ថុ អចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត ឬជាសិទ្ធិទាមទារឱ្យធ្វើ ឬមិនឱ្យធ្វើសកម្មភាពជាដើម។ លើសពីនេះ កម្មវត្ថុនៃការអនុវត្តដោយបង្ខំជាកម្មសិទ្ធិរបស់តតិយជនក៏អាចអនុវត្តដោយបង្ខំបានដែរ ប៉ុន្តែតតិយជនត្រូវប្រគល់វត្ថុនោះទៅឱ្យកូនបំណុលនៃការអនុវត្ត បន្ទាប់មកទើបចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្តសិទ្ធិទាមទារ។[67]

### ១. ការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ

ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ឬនាវា ឬវត្ថុផ្សេងទៀតដែលមនុស្សរស់នៅក្នុងនោះ ត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុជាកម្មវត្ថុស្ថិតនៅ រំលាយការកាន់កាប់វត្ថុជាកម្មវត្ថុរបស់កូនបំណុលនៃការអនុវត្ត ហើយធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្តទទួលបានការកាន់កាប់

[63] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤០៣ កថាខណ្ឌទី៤។

[64] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤១០ កថាខណ្ឌទី១។

[65] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤១៤។

[66] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៤១៦។

[67] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៥២៦ កថាខណ្ឌទី១។

នោះ។[68] មួយវិញទៀតការអនុវត្តដោយបង្ខំនេះ អាចធ្វើបានទាល់តែម្ចាស់បំណុលនៃការអនុវត្ត ឬតំណាងរបស់ខ្លួនបានបង្ហាញខ្លួននៅកន្លែងអនុវត្ត។

ការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុក្រៅពីចលនវត្ថុដែលមានចែងក្នុងមាត្រា ៥២៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវធ្វើតាមវិធីដែលអាជ្ញាសាលានៃសាលាដំបូង ដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុជាកម្មវត្ថុស្ថិតនៅ ដកយកចលនវត្ថុពីកូនបំណុលនៃការអនុវត្ត ហើយប្រគល់ចលនវត្ថុនោះ ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។[69]

**២. ការអនុវត្តដោយបង្ខំលើកាតព្វកិច្ចសកម្មភាព**

ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ត្រូវបានបែងចែកសកម្មភាពដែលអាចអនុវត្តជំនួសបាន និងសកម្មភាពដែលមិនអាចជំនួសបានដោយផ្អែកលើទស្សនទាននៃការអនុវត្តដោយបង្ខំ។ លើសពីនេះបានកំណត់ពីសកម្មភាពដែលអាចជំនួសបាន ដែលឱ្យតតិយជនបំពេញសកម្មភាពជំនួសកូនបំណុលនៃការអនុវត្តនោះ ត្រូវប្រើប្រាស់នីតិវិធីនៃការអនុវត្តជំនួស។ រីឯពាក់ព័ន្ធនឹងសកម្មភាពដែលមិនអាចជំនួសបាន មានន័យថាកូនបំណុលនៃការអនុវត្តត្រូវធ្វើសកម្មភាពនេះទើបមានអានុភាពដូចដែលបានកំណត់ ដោយប្រើប្រាស់វិធានបង្ខំដោយប្រយោល។[70]

បន្ទាប់ពីសាលក្រម ឬសាលដីកាដែលសម្រេចនូវសិទ្ធិទាមទារចូលជាស្ថាពរ ភាគីម្ចាស់បំណុលអាចដាក់ពាក្យសុំទៅស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច។ ត្រង់ផ្នែកនេះ នឹងបកស្រាយពាក់ព័ន្ធនឹងសិទ្ធិទាមទារដែលមានកម្មវត្ថុឱ្យធ្វើសកម្មភាព ឬមិនឱ្យធ្វើសកម្មភាព។

- **សិទ្ធិទាមទារឱ្យធ្វើសកម្មភាពដែលអាចជំនួសបាន**

ការអនុវត្តជំនួស សំដៅលើសិទ្ធិទាមទារដែលសកម្មភាពជាខ្លឹមសារនៃតាវកាលិក អាចបំពេញដោយអ្នកផ្សេងបាន ហើយសកម្មភាពដែលធ្វើដោយអ្នកផ្សេងនោះ នឹងនាំឱ្យកើតអានុភាពផ្នែកសេដ្ឋកិច្ច និងអានុភាពផ្នែកច្បាប់ ដូចគ្នានឹងករណីការធ្វើសកម្មភាពនោះដោយកូនបំណុលនៃការអនុវត្តដោយខ្លួនឯង។[71] ការអនុវត្ត

[68] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៥២៤ កថាខណ្ឌទី១។

[69] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៥២៥ កថាខណ្ឌទី១។

[70] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ស្តីពី «ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ»*, ឆ្នាំ២០០៩, ទំព័រ ១៨៣ ។

[71] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌, *សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២ ស្តីពី «ការអនុវត្តដោយបង្ខំ និងកាចាត់ចែងរក្សាការពារ»*, ឆ្នាំ២០០៩, ទំព័រ ១៨៤។

ដោយបង្ខំនេះ ត្រូវធ្វើតាមវិធីដែលតុលាការចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្តឱ្យតតិយជនបំពេញសកម្មភាពនោះជំនួស ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្តតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។[72]

– **វិធានការបង្ខំដោយប្រយោល**

កម្មវត្ថុនៃការអនុវត្តដោយបង្ខំក្នុងចំណុចនេះ គឺចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យធ្វើ ឬមិនឱ្យធ្វើសកម្មភាពណាមួយ ដែលអាចធ្វើបានតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តបង់ប្រាក់ដើម្បីធានាកាតព្វកិច្ច ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។[73]

[72] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៥២៧ កថាខណ្ឌទី១។

[73] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦, មាត្រា ៥២៨ កថាខណ្ឌទី១។

# ជំពូកទី៣

# ការទាមទារសំណងនៃ
# ការខូចខាត

# ជំពូកទី៣
# ការទាមទារសំណងនៃការខូចខាត

បន្ទាប់ពីបានឆ្លងកាត់ដំណាក់កាលបង្កើតកិច្ចសន្យារួចរាល់ភាគីត្រូវអនុវត្តកាតព្វកិច្ចដូចមានកំណត់ក្នុងកិច្ចសន្យា។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើមានភាគីម្ខាងណាមួយមិនអនុវត្តកាតព្វកិច្ចដូចមានកំណត់ក្នុងកិច្ចសន្យាទេ ភាគីម្ខាងទៀតអាចប្រើប្រាស់វិធីសង្គ្រោះចំពោះការមិនអនុវត្តកាតព្វកិច្ចនោះបាន តាមរយៈការទាមទារឱ្យអនុវត្តដោយបង្ខំ ការរំលាយកិច្ចសន្យា និងការទាមទារសំណងនៃការខូចខាត។ ការសង ចំពោះសំណងនៃការខូចខាត គឺជាការសង្គ្រោះមួយ ដែលត្រូវបានប្រើប្រាស់សម្រាប់ការមិនអនុវត្តកាតព្វកិច្ចគ្រប់ប្រភេទ។ ក្នុងន័យនេះ វាគឺជាការសង្គ្រោះដែលមានលក្ខណៈសាមញ្ញ និងងាយស្រួលជាងគេបំផុត។[74] ជាពិសេស សំណងនៃការខូចខាត គឺជាការជួសជុលព្យសនកម្មដែលម្ចាស់បំណុលបានទទួលរង ដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុលផងដែរ។

## ផ្នែកទី១. លក្ខខណ្ឌនៃការទទួលខុសត្រូវសំណងការខូចខាត

ជាទូទៅម្ចាស់បំណុល និងកូនបំណុល បន្ទាប់ពីបានឆ្លងកាត់ដំណាក់កាលបង្កើតកិច្ចសន្យារួចរាល់ ភាគីទាំងសងខាងសុទ្ធតែមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យារៀងៗខ្លួន។ ដូច្នេះហើយ កូនបំណុលត្រូវតែបំពេញតាវកាលិកដែលជាកម្មវត្ថុនៃកិច្ចសន្យា ចំណែកម្ចាស់បំណុលត្រូវតែបំពេញតួនាទីក្នុងនាមអ្នកត្រួតពិនិត្យការប្រតិបត្តិរបស់កូនបំណុល ផ្តល់សេវាកម្មផ្សេងៗ ព្រមទាំងប្រគល់តាវកាលិកដែលជាកម្មវត្ថុនៃកិច្ចសន្យាផងដែរ។ ក្នុងករណីមានការបំពានកាតព្វកិច្ចកើតឡើងដោយកូនបំណុលចំពោះម្ចាស់បំណុល នោះម្ចាស់បំណុលអាចទាមទារសំណងការខូចខាតដែលលក្ខខណ្ឌនៃការទាមទារត្រូវបានបញ្ញត្តិក្នុងមាត្រា ៣៩៨ ដល់មាត្រា ៤០៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### កថាខណ្ឌទី១. សំណងនៃការខូចខាតទូទៅ

សំណងនៃការខូចខាត គឺជាវិធីសង្គ្រោះទី២ដែលបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី ចំពោះការបំពានកិច្ចសន្យាដែលលក្ខខណ្ឌនៃការទទួលខុសត្រូវសំណងនៃការខូចខាតមានដូចជា៖

ក្នុងករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទេ ម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តកាតព្វកិច្ចនោះបាន។ ប៉ុន្តែក្នុងករណីដែលកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ កូនបំណុលនោះត្រូវរួចផុតពីការទទួលខុសត្រូវ

[74] សាស្ត្រាចារ្យ ហេង បូរ៉ា, *ស្តីពី នីតិកាតព្វកិច្ច* ,ទំព័រ ១០៤។

ក្នុងការសងសំណងខូចខាត[75] ក្នុងចំណុចនេះនឹងបកស្រាយអំពីការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតទូទៅ ព្រោះតែភាគីកូនបំណុលមិនអនុវត្តកាតព្វកិច្ច និងករណីយកិច្ចដែលស្របតាមការព្រមព្រៀងជាហេតុបង្កទៅជាកំហុស និងបាត់បង់អត្ថប្រយោជន៍របស់ភាគីម្ចាស់បំណុលក្នុងអំឡុងពេលអនុវត្តកាតព្វកិច្ច។

ពាក្យ «កំហុស» ត្រង់ចំណុចខាងលើអាចកំណត់ថា ជាកំហុសរបស់កូនបំណុលក្នុងករណីដែលបានកើតឡើងដោយសារៈ

- ការយឺតយ៉ាវក្នុងការអនុវត្ត
- អលទ្ធភាពក្នុងការអនុវត្ត
- ការអនុវត្តកាតព្វកិច្ចមិនពេញលេញ
- និងកំហុសក្នុងករណីផ្សេងៗទៀត។

ដោយសារករណីទាំងនេះជាមូលហេតុទាំងឡាយដែលនាំឱ្យមានការសង្គ្រោះកិច្ចសន្យា នោះកូនបំណុលត្រូវតែទទួលខុសត្រូវដោយសារកំហុសរបស់ខ្លួនផ្ទាល់ក្នុងការមិនអនុវត្តកាតព្វកិច្ច។ ផ្ទុយទៅវិញ ករណីដែលកូនបំណុលអាចរកហេតុផល ឬភស្តុតាងណាមួយដែលអាចបញ្ជាក់ថាខ្លួនគ្មានកំហុសពាក់ព័ន្ធនឹងការបំពានកិច្ចសន្យានេះ នាំឱ្យកូនបំណុលនឹងត្រូវរួចផុតពីការទទួលខុសត្រូវលើសំណងការខូចខាត។

ឧទាហរណ៍ នៅក្នុងកិច្ចសន្យាលក់ទិញ រវាងភាគីអ្នកលក់និងអ្នកទិញ ដែលភាគីអ្នកលក់មានកាតព្វកិច្ចប្រគល់តាវកាលិកដែលជាកម្មវត្ថុនៃកិច្ចសន្យា (ចលនវត្ថុ អចលនវត្ថុ...) ទៅឱ្យអ្នកទិញតាមការព្រមព្រៀង ប៉ុន្តែមុនពេលអនុវត្តកាតព្វកិច្ចមកដល់ អ្នកលក់បានធ្វើឱ្យតាវកាលិកនោះបាត់បង់ ខូចខាត ដែលមិនអាចយកអ្វីមកជំនួសវិញបាន ឬជួសជុលបានទេ ជាហេតុធ្វើឱ្យភាគីអ្នកលក់គ្មានលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចនៅពេលកាលបរិច្ឆេទមកដល់។ ចំណុចនេះហើយ ធ្វើឱ្យភាគីអ្នកទិញអាចទាមទារសំណងការខូចខាតដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ចរបស់អ្នកលក់។ ផ្ទុយមកវិញ ភាគីអ្នកលក់បានបកស្រាយថា តាវកាលិកនៃកិច្ចសន្យាត្រូវបានបាត់បង់នោះ គឺដោយសារមានករណី**ប្រធានសក្តិ**[76] ដែលមិនអាចដឹងជាមុន (បញ្ហាធំៗដូចជា រញ្ជួយដី រលកយក្សស៊ូណាមិ សង្គ្រាម ជាដើម) ជាហេតុធ្វើឱ្យវត្ថុនោះខូចខាត និងបាត់បង់។ ដូច្នេះ ភាគីអ្នកលក់ក៏អាចរួចផុតពីការទទួលខុសត្រូវលើសំណងការខូចខាតផងដែរ ដោយសារខ្លួនអាចអះអាងពីភាពសុចរិត និងគ្មានកំហុសដែលបណ្តាលឱ្យវត្ថុនោះខូចខាត ឬបាត់បង់។

---

[75] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៩៨ វាក្យខណ្ឌទី១។

[76] **ប្រធានសក្តិ** គឺជាព្រឹត្តិការណ៍ដែលកើតឡើងក្រៅពីឆន្ទៈមិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។ (ដកស្រង់ពី គណកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពពីទីស្តីការគណរដ្ឋមន្ត្រី *ស្តីពី «សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណីនិង នីតិវិធីរដ្ឋប្បវេណី»* ឆ្នាំ២០០៧)

ក្នុងករណីដែលកូនបំណុលឱ្យអ្នកដទៃទៀតធ្វើជាអ្នកជំនួយដើម្បីឱ្យជួយអនុវត្តកាតព្វកិច្ច កូនបំណុលនោះមិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាតបានទេ លើកលែងតែកូនបំណុលនោះមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុសក្នុងការជ្រើសតាំង និងការត្រួតពិនិត្យអ្នកជំនួយ ហើយអ្នកជំនួយនោះក៏គ្មានកំហុសដែរ។[77] ចំណុចនេះក៏ជាលក្ខខណ្ឌមួយទាក់ទងនឹងការទទួលខុសត្រូវលើសំណងការខូចខាតផងដែរ យោងតាមក្រមរដ្ឋប្បវេណី មាត្រា ៣៩៨ កថាខណ្ឌទី២ បានបន្ថែមអំពី «អ្នកជំនួយ» និងបានបញ្ជាក់នូវចំណុចរបស់អ្នកជំនួយ ដែលជាបុគ្គលអនុវត្តកាតព្វកិច្ច ឬអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យាឱ្យភាគីកូនបំណុល ប៉ុន្តែបើទោះបីជាក្នុងកិច្ចសន្យានោះ កូនបំណុលមិនបានអនុវត្តកាតព្វកិច្ចដោយផ្ទាល់ក្តី ជាគោលការណ៍កូនបំណុលត្រូវទទួលខុសត្រូវចំពោះសកម្មភាព របស់អ្នកជំនួយដែលបានកើតឡើងដោយសារការអនុវត្តរបស់អ្នកជំនួយ ពីព្រោះកូនបំណុលជាអ្នកជ្រើសតាំង និងជាអ្នកមានសិទ្ធិត្រួតពិនិត្យលើការប្រតិបត្តិផ្សេងៗរបស់អ្នកជំនួយនោះ។ ផ្ទុយមកវិញ ករណីនេះកូនបំណុលក៏អាចរួចផុតពីការទទួលខុសត្រូវសំណងការខូចខាតដែរ បើសិនខ្លួនអាចបញ្ជាក់ថាគ្មានកំហុសក្នុងការជ្រើសតាំង ឬត្រួតពិនិត្យលើអ្នកជំនួយបានត្រឹមត្រូវ ប៉ុន្តែករណីអ្នកជំនួយនៅតែបំពានកិច្ចសន្យា នាំឱ្យកូនបំណុលអាចរួចផុតពីការទទួលខុសត្រូវលើសំណងការខូចខាតបាន។

សរុប លក្ខខណ្ឌទាំងពីរខាងលើនាំឱ្យមានការទទួលខុសត្រូវសំណងការខូចខាត បង្ហាញឱ្យឃើញថា៖

- ការទាមទារសំណង ត្រូវផ្អែកលើកំហុសរបស់កូនបំណុល ឬអ្នកជំនួយ
- គ្មានកំហុស គ្មានការទាមទារសំណងការខូចខាតឡើយ។

### កថាខណ្ឌទី២. លក្ខខណ្ឌពិសេសពាក់ព័ន្ធនឹងកាតព្វកិច្ចជាប្រាក់

ដោយផ្អែកលើលក្ខខណ្ឌនៃការទាមទារសំណងការខូចខាត តាមមាត្រា ៣៩៨ នៃក្រមរដ្ឋប្បវេណី ម្ចាស់បំណុលអាចទាមទារសំណងការខូចខាតនៅពេលមានការបំពានកិច្ចសន្យាពីភាគីកូនបំណុល ហើយការបំពាននោះ គឺជាកំហុសផ្ទាល់របស់កូនបំណុល ឬអ្នកជំនួយ។ ប៉ុន្តែពាក់ព័ន្ធនឹងកាតព្វកិច្ចជាប្រាក់ដែលកូនបំណុលត្រូវប្រគល់ឱ្យម្ចាស់បំណុល បើទោះបីជាមានការបំពានកិច្ចសន្យាកើតឡើង ហើយកូនបំណុលមានកំហុស ឬគ្មានកំហុស ក៏ភាគីកូនបំណុលមិនអាចរួចផុតពីការបង់ការប្រាក់នៅក្នុងកំឡុងពេលយឺតយ៉ាវក្នុងការអនុវត្ត ដែលកើតឡើងដោយប្រធានសក្តិដែរ។

លើសពីនេះទៅទៀត បន្ថែមពីលើការបកស្រាយខាងលើ ករណីដែលសំណងនៃការខូចខាតនោះ លើសពីចំនួននៃការប្រាក់ ឬអាចកំណត់ថា ពាក់ព័ន្ធនឹងកាតព្វកិច្ចជាប្រាក់ ដោយសារតែករណីប្រធានសក្តិ នាំឱ្យមានការយឺតយ៉ាវក្នុងការអនុវត្តរបស់កូនបំណុល ភាគីត្រូវសងការប្រាក់ក្នុងកំឡុងពេលយឺតយ៉ាវនោះ បន្ថែមជាមួយ

[77] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣៩៨ កថាខណ្ឌទី២។

នឹងសំណងនៃការខូចខាតផ្សេងទៀត ដែលការខូចខាតនោះបានកើតឡើង។

## ផ្នែកទី២. អំពីការខូចខាត និងទំហំនៃសំណងការខូចខាត

ត្រង់ផ្នែកនេះនឹងបកស្រាយអំពីទស្សនៈនៃការខូចខាត (កថាខណ្ឌទី១) ឈានដល់ការកំណត់សំណងនៃការខូចខាតអាស្រ័យទំហំដែលបានកើតឡើង (កថាខណ្ឌទី២) និង(កថាខណ្ឌទី៣) បកស្រាយអំពីការគណនា និងអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងខូចខាត។

### កថាខណ្ឌទី១. ទស្សនៈអំពីការខូចខាត

ការខូចខាត គឺជាមូលហេតុដែលនាំឱ្យមានការទាមទារសំណងតាមរយៈម្ចាស់បំណុល ពីកូនបំណុលដែលបំពានកាតព្វកិច្ច។ ការខូចខាតដែលនាំឱ្យមានសំណង មានដូចខាងក្រោម៖

ម្ចាស់បំណុលអាចទាមទារនូវសំណងនៃការខូចខាត គឺអាចទាមទារនូវសំណងនៃ**ផលប្រយោជន៍ពីការអនុវត្តដែលខ្លួនត្រូវទទួលបានដោយកិច្ចសន្យា**[78] នោះ ហើយក្រៅពីនេះអាចទាមទារផងដែរនូវ **ចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្ត**[79] និងចំណាយ ឬបន្ទុកដែលបង្កើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ចក្នុងទំហំដែលមិនជាន់គ្នាជាមួយនឹងសំណងនៃផលប្រយោជន៍ពីការអនុវត្ត។[80]ក្នុងការទាមទារសំណងនៃការខូចខាត ម្ចាស់បំណុលអាចទាមទារសំណងដែលបានមកពីកូនបំណុលអនុវត្តកាតព្វកិច្ច លើសពីនេះករណីកូនបំណុលមិនអនុវត្តកាតព្វកិច្ច ម្ចាស់បំណុលក៏អាចទាមទារសំណងបានផងដែរ។

ក្រៅពីសំណងនៃការខូចខាតខាងលើ ក៏នៅមានសំណងខូចខាតខាងផ្លូវចិត្តដែលភាគីម្ចាស់បំណុលអាចទាមទារពីកូនបំណុលដែលមិនអនុវត្តកាតព្វកិច្ចផងដែរ។ ត្រង់សំណងនៃការខូចខាតផ្នែកនេះ តុលាការក៏អាចបង្គាប់ឱ្យកូនបំណុលសងសំណងនៃការខូចខាតខាងផ្លូវចិត្ត ដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុលបាន

[78] **ផលប្រយោជន៍ពីការអនុវត្តដែលម្ចាស់បំណុលត្រូវទទួលបានដោយកិច្ចសន្យា** គឺជាផលប្រយោជន៍ដែលត្រូវបានទទួល នៅពេលដែលកិច្ចសន្យាត្រូវបានអនុវត្ត។ មួយវិញទៀត គឺជាសំណងដែលមានកម្មវត្ថុជាផលប្រយោជន៍ពីការអនុវត្ត មានន័យថាផលប្រយោជន៍ដែលអាចទទួលបាន ប្រសិនបើកិច្ចសន្យាត្រូវបានអនុវត្ត។ ប៉ុន្តែការខូចខាតដែលកើតឡើងចំពោះម្ចាស់បំណុល ដោយសារការមិនអនុវត្តមិនត្រឹមតែជាផលប្រយោជន៍ពីការអនុវត្តប៉ុណ្ណោះទេ។

[79] **ចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្តកាតព្វកិច្ច** គឺជាសោហ៊ុយចំណាយដើម្បីបង្កើត កិច្ចសន្យាជាអាទិ៍។ នៅក្នុងការចំណាយប្រភេទនេះប្រសិនបើកិច្ចសន្យាត្រូវបានអនុវត្ត ចំណាយទាំងនេះ គឺជាបន្ទុករបស់ភាគីនីមួយៗនៃកិច្ចសន្យាហើយភាគីម្ខាងមិនអាចទាមទារឱ្យភាគីម្ខាងទៀតទទួលបន្ទុក ចំណាយបានឡើយ ប៉ុន្តែក្នុងករណីដែលម្ចាស់បំណុលមិនអាចសម្រេចនូវគោលបំណងក្នុងការបង្កើតកិច្ចសន្យា បានដោយសារអលទ្ធភាពក្នុងការអនុវត្តកិច្ចសន្យានោះមាត្រានេះអនុញ្ញាតឱ្យម្ចាស់បំណុលទាមទារការចំណាយទាំងនេះជាសំណងការខូចខាតចំពោះកូនបំណុល។

[80] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០០ កថាខណ្ឌទី១។

ដែរ។ ចំពោះចំនួនសំណងនៃការខូចខាតផ្លូវចិត្ត តុលាការត្រូវសម្រេចដោយគិតពិចារណាអំពីកាលៈទេសៈជុំវិញផ្សេងៗ។[81] ចំពោះការសងសំណងនៃការខូចខាតផ្លូវចិត្ត មិនមែនជាតួនាទីតុលាការដែលជួយទាមទារសំណងជំងឺផ្លូវចិត្តដល់ម្ចាស់បំណុលពីកូនបំណុលនោះទេ ទាល់តែមានការទាមទារតាមរយៈម្ចាស់បំណុល ទើបតុលាការសម្រេចលើការទាមទារនោះ ប៉ុន្តែពាក់ព័ន្ធនឹងទំហំនៃសំណងនោះ តុលាការត្រូវធ្វើការគិតពិចារណាឱ្យបានច្បាស់លាស់មុនសម្រេច។

ជារួមមក ការខូចខាតដែលកើតឡើងដោយសារកំហុសរបស់កូនបំណុល នាំឱ្យម្ចាស់បំណុលអាចទាមទារនូវសំណងនេះ៖

- ផលប្រយោជន៍ពីការអនុវត្តដែលខ្លួនត្រូវទទួលបានដោយកិច្ចសន្យា
- ចំណាយដែលគ្មានប្រយោជន៍ដោយសារការមិនអនុវត្ត និងចំណាយ ឬបន្ទុកដែលបង្កើនឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច
- និងសំណងនៃការខូចខាតផ្លូវចិត្ត។

**កថាខណ្ឌទី២. ទំហំនៃសំណងការខូចខាត**

ទំហំនៃសំណងការខូចខាត បានដាក់កម្រិតដើម្បីវិនិច្ឆ័យនូវការខូចខាតដែលកើតមានដើម្បីទូទាត់នូវសំណងដែលបណ្តាលមកពីការខូចខាតនោះ។ យោងតាមបញ្ញត្តិមាត្រា ៤០១ នៃក្រមរដ្ឋប្បវេណី បានកំណត់ទំហំនៃសំណងការខូចខាតជាបីប្រភេទមានដូចខាងក្រោម៖

**ការខូចខាតធម្មតា** គឺជាការខូចខាតដែលកើតឡើងជាធម្មតាចំពោះម្ចាស់បំណុល ដែលនឹងកើតឡើងដោយសារកូនបំណុលមិនអនុវត្តកាតព្វកិច្ច។[82] ចំពោះសំណងដែលបណ្តាលមកពីការខូចខាតនេះ គឺកើតចេញពីអំពើដែលមិនបានព្យាករណ៍ទុកជាមុន និងមិនមែនជាអំពើមិនស្មោះត្រង់។ ដូច្នេះ សំណងដែលអាចនឹងកើតឡើងអាចជាតម្លៃនៃវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាជាដើម។

ករណីជាក់ស្តែងមួយ ចំពោះអ្នកលក់ដែលមិនបានអនុវត្តកាតព្វកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញតាមការកំណត់ទៅឱ្យអ្នកទិញដោយមូលហេតុអលទ្ធភាពក្នុងការអនុវត្ត នាំឱ្យការបាត់បង់ផលប្រយោជន៍របស់អ្នកទិញកើតមានឡើង ពីការមិនអនុវត្តកាតព្វកិច្ចរបស់អ្នកលក់ គឺជាការខូចខាតដែលកើតឡើងជាធម្មតា។ ដូច្នេះសំណងនៃការខូចខាតនេះ ភាគីអ្នកទិញអាចទាមទារបានត្រឹមតែជាតម្លៃនៃវត្ថុនោះតែប៉ុណ្ណោះ។

[81] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០០ កថាខណ្ឌទី២។

[82] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០១ កថាខណ្ឌទី១។

**ការខូចខាតដែលកើតឡើងដោយសារកាលៈទេសៈពិសេស** គឺជាការខូចខាតដែលគូភាគីអាចព្យាករណ៍បានថានឹងអាចកើតមានឡើងនៅពេលធ្វើកិច្ចសន្យា[83] ប៉ុន្តែសកម្មភាពបានព្យាបាទ ឬមិនស្មោះត្រង់ នាំឱ្យម្ចាស់បំណុលអាចទាមទារសំណងនៃការខូចខាតបាន។ ផ្ទុយទៅវិញ ក្នុងករណីដែលគូភាគីក្នុងកិច្ចសន្យាមិនបានព្យាករណ៍ទុកជាមុននូវការខូចខាតពិសេសនេះទេ ជាហេតុធ្វើឱ្យម្ចាស់បំណុលក៏មិនអាចទាមទារសំណងការខូចខាតក្នុងកាលៈទេសៈនេះដែរ។ ដូច្នេះ សំណងដែលអាចនឹងកើតឡើងអាចជាសំណងដែលមានបន្ថែមជាមួយនឹងប្រាក់ពិន័យដែលមានក្នុងកិច្ចសន្យា។

ក្នុងការបង្កើតកិច្ចសន្យាមួយមានក្រុមហ៊ុនដឹកជញ្ជូន និងភាគី **ក** ដែលបានធ្វើកិច្ចសន្យាដឹកជញ្ជូន ដែលកម្មវត្ថុនៃកិច្ចសន្យា គឺជាវត្ថុមួយដែលមានតម្លៃខ្ពស់ និងងាយស្រួលធ្វើឱ្យខូចខាត ឬបាត់បង់ ដោយសារតែភាគី **ក** បានដឹងនឹងអាចព្យាករណ៍រួចជាស្រេចនូវព្យសនកម្មដែលនឹងអាចកើតឡើង នាំឱ្យភាគី **ក** បានបង្កើតការសន្យាពិសេសបន្ថែមជាមួយក្រុមហ៊ុនដឹកជញ្ជូន និងបានបន្ថែមតម្លៃដឹកជញ្ជូនពីលើតម្លៃធម្មតា ជាថ្នូរដែលនៅពេលមានការខូចខាតកើតឡើង ក្រុមហ៊ុនដឹកជញ្ជូននោះ ត្រូវទទួលខុសត្រូវខ្ពស់ជាងវត្ថុធម្មតា។ នៅពេលដឹកជញ្ជូនបានធ្វើឱ្យវត្ថុនោះខូចខាត ឬបាត់បង់ដោយសារកំហុសរបស់ក្រុមហ៊ុនដឹកជញ្ជូនពិតមែន នោះភាគី **ក** អាចទាមទារសំណងការខូចខាតខ្ពស់ជាងតម្លៃវត្ថុធម្មតា ដោយអះអាងថាការខូចខាតនេះ ជាការខូចខាតដែលកើតឡើងដោយសារកាលៈទេសៈពិសេស។ ផ្ទុយទៅវិញ ករណីដែលមិនមានការព្យាករណ៍ទុកជាមុននូវការខូចខាតពិសេសទេ ទោះបីជាវត្ថុនោះថ្លៃយ៉ាងណាក៏ដោយ សំណងនៃការខូចខាតត្រូវសងដូចវត្ថុដែលមានក្នុងការកំណត់របស់ក្រុមហ៊ុនដែលមិនមានក្នុងលក្ខខណ្ឌពិសេស។

ផ្ទុយទៅវិញបើក្រឡេកមើលករណីពិសេសមួយចំនួន ភាគីការបង្កើតកិច្ចសន្យាដឹកជញ្ជូនដូចគ្នា ប៉ុន្តែផ្អែកតាមការសម្រុះសម្រួលរបស់គូភាគីយល់ព្រមលើលក្ខខណ្ឌ និងមិនមានការទាមទារសំណងការខូចខាតកើតឡើងនោះទេ។ ជាក់ស្តែងគឺកាលពីចុងឆ្នាំ២០១៩ វិស័យដឹកជញ្ជូនកម្ពុជាហាក់មានតម្រូវឱ្យមានការដឹកជញ្ជូនច្រើនទាំងក្នុងស្រុក និងដឹកជញ្ជូនទៅក្រៅប្រទេស កំពង់ផែក្រុងព្រះសីហនុ និងផ្លូវជាតិលេខ៤ មានការកកស្ទះទំនិញខ្លាំង ព្រោះតែមានការដឹកជញ្ជូនទំនិញទៅឱ្យអ្នកបញ្ជាទិញ។ រហូតមកដល់ខែកុម្ភៈ និងខែមីនា ឆ្នាំ២០២០ ដោយសារមានការឆ្លងរាលដាលនៃវីរុសកូវីដ១៩ ក៏បានធ្វើឱ្យសកម្មភាពដឹកជញ្ជូន នៅក្នុងប្រទេសកម្ពុជា ចាប់ផ្តើមធ្លាក់ចុះ ហើយគិតមកដល់ខែឧសភា ការធ្លាក់ចុះមានអត្រាជិតដល់៦០ភាគរយ ។ ក្នុងអំឡុងពេលនោះផងដែរ ការដឹកជញ្ជូនក៏មិនមានសកម្មភាព តែទោះបីជាយ៉ាងនេះក្តី ក៏មិនទាន់មានក្រុមហ៊ុនដឹកជញ្ជូនណាមួយ បានបិទសកម្មភាពនោះទេ។ ដោយមូលហេតុក្រុមហ៊ុនបានព្រមព្រៀងជាមួយអតិថិជនរួចហើយម្យ៉ាង

[83] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០១ កថាខណ្ឌទី២។

វិញទៀតក៏បានទទួលប្រាក់រួចហើយដែរ ក្នុងករណីនេះក្រុមហ៊ុនដឹកជញ្ជូនបានជ្រើសរើសវិធីសាស្ត្រមួយចំនួន ដូចជា ត្រូវផ្លាស់ប្តូរការដាក់អីវ៉ាន់មកតាមកប៉ាល់វិញ ឬត្រូវកាត់បន្ថយបុគ្គលិក ឬត្រូវធ្វើយ៉ាងណា ខណៈសកម្មភាពដឹកជញ្ជូននៅជាង ៣០ ភាគរយនេះដើម្បីធានាកាតព្វកិច្ចសម្រាប់អតិថិជន។[84] មួយវិញទៀតរាជរដ្ឋាភិបាលបានចូលរួម ស្វែងរកដំណោះស្រាយដើម្បីសម្រួលជីវភាពប្រជាពលរដ្ឋក៏ដូចជាភាគីក្នុងកិច្ចសន្យាដឹកជញ្ជូនដែលវិធីទាំងនោះរួមមានដូចជា៖ ការអនុគ្រោះពន្ធក៏ជាគោលនយោបាយសេដ្ឋកិច្ចដ៏សំខាន់មួយ ដែលបានបង្កើតឡើងដោយរដ្ឋាភិបាលដើម្បីជួយកាត់បន្ថយបន្ទុកពន្ធលើប្រជាជន ហើយរដ្ឋាភិបាលបានផ្តល់អត្ថប្រយោជន៍ដល់អ្នកដែលត្រូវបានផ្អាកបណ្តោះអាសន្នពីការងារចំនួន ៤០ ដុល្លារក្នុងមួយខែ សំដៅទៅដល់កម្មករដែលបាត់បង់ការងារដោយសារជំងឺរាតត្បាត និងអ្នកដែលត្រូវការជាពិសេសផ្សេងទៀតនៅក្នុងអំឡុងពេលវងគ្រោះខ្លាំងនេះ ដូចជាអ្នកធ្វើការលើវិស័យទេសចរណ៍ និងក្រុមហ៊ុនអាកាសចរណ៍ជាដើម។

ដូច្នេះ ក្នុងករណីកិច្ចសន្យាដឹកជញ្ជូនដូចគ្នា មានការខូចខាតកើតឡើងដូចគ្នា ក៏មិនប្រាកដថាមានការទាមទារសំណងកើតឡើងនោះទេ វាអាស្រ័យតាមស្ថានភាពជាក់ស្តែងថាភាគីជ្រើសរើស ការសម្រុះសម្រួលគ្នាទៅវិញទៅមក ឬមិនអាចសម្រុះសម្រួលមិនបានហើយជ្រើសរើសការទាមទារតាមផ្លូវច្បាប់។

**ការខូចខាតអំពើព្យាបាទ ឬមិនស្មោះត្រង់ហួសហេតុ** ការខូចខាតអំពើព្យាបាទ ឬមិនស្មោះត្រង់ហួសហេតុ គឺជាការខូចខាតដែលតុលាការអាចបង្គាប់ឱ្យកូនបំណុលសងផលប្រយោជន៍ដែលកូនបំណុលបានទទួលពីអំពើដែលជាការមិនអនុវត្តកាតព្វកិច្ចដោយផ្អែកលើការទាមទាររបស់ម្ចាស់បំណុល។[85] ការខូចខាតនេះកើតចេញពីអំពើបានព្យាករណ៍ទុកជាមុន ជាអំពើព្យាបាទ ឬអំពើមិនស្មោះត្រង់ នាំឱ្យសំណងដែលកើតឡើងអាចជាសំណងធម្មតា សំណងពិសេស ព្រមទាំងសំណងដែលបានពីការចំណេញមកពីមិនអនុវត្តកាតព្វកិច្ច។

ជាក់ស្តែងភាគីបានព្រមព្រៀងលើកិច្ចសន្យាខ្ចីប្រើមួយមានកម្មវត្ថុខ្ចីជាដីកសិកម្មមួយកន្លែង ដោយភាគីអ្នកឱ្យខ្ចីបានព្រមព្រៀងជាមួយអ្នកខ្ចី ដោយសារតែអាណិតទើបយល់ព្រមថាឱ្យសិទ្ធិអ្នកខ្ចីអាចប្រើប្រាស់និងអាស្រ័យផលដោយខ្លួនឯងលើដីរបស់ខ្លួនដោយមិនយកកម្រៃចំនួន ១ ឆ្នាំ។ ប៉ុន្តែ ក្រោយមកបែរជាភាគីអ្នកខ្ចីបានប្រើដីនោះទៅជាការដ្ឋានកាយដីលក់ដោយពុំរាយការណ៍សុំការអនុញ្ញាតពីភាគីម្ចាស់ដីឡើយ។ អំពើដែលភាគីអ្នកខ្ចីបានធ្វើជាអំពើដែលជាការព្យាបាទ ឬអំពើមិនស្មោះត្រង់យ៉ាងធ្ងន់ធ្ងរ។ ជាហេតុបណ្តាលឱ្យភាគីអ្នកខ្ចីត្រូវតែទទួលខុសត្រូវនូវទំហំការខូចខាតដែលភាគីអ្នកឱ្យខ្ចីមាន និងការទាមទាររបស់អ្នកឱ្យខ្ចី។

---

[84] លោកស៊ិន ចន្ទី ប្រធានសមាគមភស្តុភារកម្មកម្ពុជា តាមសេចក្តីរាយការណ៍ស្តីពី *«វិស័យដឹកជញ្ជូនកម្ពុជាហាក់ងើបឡើងវិញបន្ទាប់ពីបញ្ហាCovid-19អាចគ្រប់គ្រងបាននៅកម្ពុជា»* តំណភ្ជាប់: https://www.propertyarea.asia/archives/48925 ,បានចូលមើលនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២។

[85] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០១ កថាខណ្ឌទី៣។

## កថាខណ្ឌទី៣. ការគណនា និងអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងខូចខាត

### ១. ការកំណត់ទុកជាមុននូវចំនួននៃសំណង

ចំពោះការគណនា ឬកំណត់ចំនួនសំណងនៃការខូចខាត ភាគីក្នុងកិច្ចសន្យាអាចព្រមព្រៀងគ្នាកំណត់លក្ខខណ្ឌ ក៏ដូចជាចំនួននៃសំណងទុកជាមុនបាន។ មានន័យថា ចំនួននៃសំណងនៃការខូចខាត ភាគីបានកំណត់ទុកជាស្រេចមុនពេលភាគីកូនបំណុលបំពានលើកិច្ចសន្យា ដែលនាំឱ្យបាត់បង់ប្រយោជន៍ដល់ម្ចាស់បំណុល។ ការកំណត់ទុកជាមុននូវលក្ខខណ្ឌ និងចំនួននៃសំណងនេះ គឺជាមធ្យោបាយដ៏ល្អមួយ ដែលចំពោះម្ចាស់បំណុលមិនមានការភ័យខ្លាចក្នុងការទាមទារសំណងនៃការខូចខាត ក្រោយពេលមានការបំពានកិច្ចសន្យា និងអាចបង្អាកូនបំណុលមិនហ៊ានបំពានកិច្ចសន្យា ឬម្យ៉ាងទៀតកូនបំណុលបានដឹងពីសំណងនៃការខូចខាត នាំឱ្យកូនបំណុលអាចត្រៀមខ្លួន ឬមានលទ្ធភាពស្វែងរកចំនួនសំណងនៃការខូចខាតទុកជាមុនបាន។

បើក្រឡេកទៅមើលការបកស្រាយខាងលើ ភាគីម្ចាស់បំណុល និងកូនបំណុលបានព្រមព្រៀងគ្នាដោយស្ម័គ្រចិត្ត គ្មានការបង្ខំក្នុងការកំណត់ចំនួននៃសំណងនៃការខូចខាតទុកជាមុន។ ប៉ុន្តែចំពោះភាគីកូនបំណុល គឺបានដឹងអំពីចំនួននៃសំណង ដែលជាដើមហេតុមួយអាចធ្វើឱ្យមានការបំពានកិច្ចសន្យាធ្ងន់ធ្ងរកើតឡើងទៅវិញ ដែលអាចលើសពីចំនួននៃសំណងដែលបានកំណត់ទុកមុន។ ចំពោះករណីនេះប្រសិនបើរកឃើញថា នេះជាកំហុសចេតនារបស់កូនបំណុល នាំឱ្យសំណងនៃការខូចខាតដែលបានកំណត់ទុកជាមុននេះ មិនមានអានុភាពឡើយ។

ការទាមទារសំណងនៃការខូចខាតដែលបានកំណត់ទុកមុននេះ អាចធ្វើឡើងរវាងភាគីក្នុងកិច្ចសន្យាក្នុងករណីដែលមានភាពឯកភាពគ្នា យល់ព្រមលើសំណងនៃការខូចខាតដែលកំណត់ទុកជាមុននោះ។ ផ្ទុយទៅវិញ បើភាគីកូនបំណុល ឬម្ចាស់បំណុលមិនឯកភាពលើសំណងនៃការខូចខាតដែលបានកំណត់ជាមុននោះ ដំណោះស្រាយ គឺតាមផ្លូវតុលាការ។ បើទោះបីជាតុលាការជាអ្នកមានសិទ្ធិអំណាចសម្រេចពាក់ព័ន្ធនឹងសំណងនៃការខូចខាតនេះក៏ដោយ ក៏តុលាការមិនអាចបន្ថែម ឬបន្ថយចំនួននៃសំណងនៃការខូចខាតដែលបានកំណត់បានឡើយ។ ដោយឡែក ពាក់ព័ន្ធនឹងចំនួននៃសំណង ដែលអាចជាប្រាក់នោះច្រើនហួស ឬតិចពេក ដែលមិនសមស្របនឹងការបំពានកិច្ចសន្យានោះតុលាការអាចបន្ថែម ឬបន្ថយចំនួននៃសំណងនៃការខូចខាតបាន។

ក្នុងករណីដែលមានការបំពានកិច្ចសន្យាកើតឡើងដែលប្រព្រឹត្តដោយកូនបំណុល ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តកាតព្វកិច្ច ឬក៏អាចរំលាយកិច្ចសន្យាតែម្តង រីឯពាក់ព័ន្ធនឹងសំណងនៃការខូចខាតដែលបានកំណត់ទុកជាមុននោះ មិនអាចរារាំងម្ចាស់បំណុលបានទេ។ ផ្ទុយទៅវិញ កូនបំណុលបានបំពានកិច្ចសន្យា ជាហេតុនាំឱ្យម្ចាស់បំណុលមានសិទ្ធិរំលាយកិច្ចសន្យា ហើយទាមទារសំណងនៃការខូចខាត ដែលសំណងនៃការខូចខាតនេះមានតម្លៃស្មើនឹងកម្មវត្ថុនៃកិច្ចសន្យា នាំឱ្យចំនួននៃសំណងនៃការខូចខាតដែលបានកំណត់ទុកមុន

ក្នុងកិច្ចសន្យានោះមិនអាចយកមកអនុវត្តបានឡើយ ដែលការខូចខាតនោះបណ្តាលមកពីកូនបំណុលមានការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច។

ប្រាក់ធានាសំណងក្នុងករណីបំពានកិច្ចសន្យា ត្រូវសន្មតទុកថាជាការកំណត់ទុកជាមុននូវចំនួននៃការខូចខាត។[86]

**២. មូលហេតុបន្ថយសំណងនៃការខូចខាត**

ពាក់ព័ន្ធនឹងសំណងនៃការខូចខាត ភាគីម្ចាស់បំណុលអាចទាមទារដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល និងផ្អែកទៅលើកំហុសរបស់កូនបំណុល ឬអ្នកជំនួយរបស់កូនបំណុលផ្ទាល់។ ផ្ទុយទៅវិញ ប្រសិនបើកូនបំណុលអាចរកឃើញ ឬបញ្ជាក់ថាក្នុងការដែលខ្លួនមិនអនុវត្តកាតព្វកិច្ច មានផ្នែកខ្លះបង្កឡើងដោយកំហុសម្ចាស់បំណុល កូនបំណុលត្រូវប្រគល់តួនាទីដល់តុលាការជាអ្នកមានសិទ្ធិក្នុងការសម្រេចលើការបន្ថយនូវចំនួននៃសំណងការខូចខាត ចំពោះផ្នែកដែលបង្កឡើងដោយកំហុសរបស់ម្ចាស់បំណុល។ លើសពីនេះ លក្ខខណ្ឌនៃការបន្ថយសំណងការខូចខាត ក៏បានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី ដែលបានកំណត់ថា កាលបើមិនបានអនុវត្តកាតព្វកិច្ច ឬការខូចខាតកើតឡើង ផ្នែកខ្លះត្រូវបានបង្កឡើងដោយកំហុសរបស់ម្ចាស់បំណុល តុលាការអាចបន្ថយនូវចំនួននៃសំណងការខូចខាតដែលកូនបំណុលត្រូវសងបាន តាមកម្រិតនៃការបង្កនោះ។[87]

**៣. គោលការណ៍នៃការសងសំណងជាប្រាក់**

នៅក្នុងផ្នែកខាងលើ គឺបានបកស្រាយចំពោះលក្ខខណ្ឌនៃការទទួលខុសត្រូវសំណងនៃការខូចខាត ក៏ដូចជាទំហំនៃសំណងជាដើម។ ប៉ុន្តែក្នុងចំណុចនេះ នឹងបកស្រាយអំពី ការសងសំណង តើការសងសំណងនៃការខូចខាត ភាគីកូនបំណុលគួរសងដោយវិធីដូចម្តេច? ជាប្រាក់? ឬជាវត្ថុមានតម្លៃផ្សេងទៀត?

ជាគោលការណ៍ដែលច្បាប់បានកំណត់ គឺតម្រូវឱ្យកូនបំណុលត្រូវសងសំណងនៃការខូចខាតជាប្រាក់ប៉ុណ្ណោះ។ ដូចក្នុងករណីកូនបំណុលបានធ្វើឱ្យខូចខាតវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា នោះម្ចាស់បំណុលអាចទាមទារសំណងបានដែលជាសំណងខូចខាតធម្មតា ជំនួសឱ្យវត្ថុនោះជាប្រាក់បាន។ ប៉ុន្តែ បើក្នុងករណីដែលមានការសន្យាពិសេសផ្សេងទៀតដែលបញ្ញត្តិច្បាប់ក្នុងមាត្រា ៤០៤[88] នៃក្រមរដ្ឋប្បវេណីមិនបានកំណត់ ភាគីត្រូវអនុវត្តវិធីសងតាមការសន្យាពិសេសនោះ។

[86] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០៣ កថាខណ្ឌទី៥។

[87] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០២ កថាខណ្ឌទី១។

[88] ចំពោះសំណងនៃការខូចខាតដែលកើតឡើងដោយការមិនអនុវត្តកាតព្វកិច្ច កូនបំណុលត្រូវសងជាប្រាក់។ (ដកស្រង់ចេញពីក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០៤)

ជាក់ស្តែង កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ បុរសជនជាតិជប៉ុនបានឱ្យប្រាក់ទៅបុរសជនជាតិខ្មែរខ្ចី ដោយបានបង្កើតកិច្ចសន្យាខ្ចីបរិភោគចំនួនទឹកប្រាក់ ៥៣,៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លារអាមេរិកក្នុងគោលបំណងជាទុនធ្វើកសិកម្ម ព្រមទាំងបានសន្យាថានឹងសងប្រាក់ដែលបានខ្ចីមកដើមចោទវិញត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។ ប៉ុន្តែតាមរយៈការអនុវត្តកិច្ចសន្យានាពេលកន្លងមក ភតិបតី មានក្តីបារម្ភយ៉ាងខ្លាំងចំពោះលទ្ធភាពនៃការអនុវត្តសិទ្ធិលើបំណុលរបស់ភតិកៈ ដែលស្តែងឡើងតាមរយៈភាពមិនដំណើរការជាមួយព័ត៌មានអំពីបច្ចុប្បន្នភាពក្នុងការធ្វើកសិកម្មដូចជា ការធ្លាក់ចុះនូវស្ថានភាពហិរញ្ញវត្ថុជាដើម។ ក្រោយមកភតិបតី បានព្យាយាមជូនដំណឹងជាច្រើនសារទៀតអំពីរំលាយកិច្ចសន្យា និងបង្គាប់ឱ្យមានការបំពេញតាវការលិកតាមកិច្ចសន្យាទៅភតិកៈ ហើយភតិកៈ បដិសេធមិនទទួលយកការជូនដំណឹងទាំងនោះហើយក៏មិនព្រមសងទឹកប្រាក់កម្ចីតាមកិច្ចសន្យាខ្ចីប្រាក់ដដែល។ ក្រោយមក ភតិបតីបានដាក់បណ្តឹងទៅសាលាដំបូងដើម្បីឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយ សងប្រាក់កម្ចី ៥៣,៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លារអាមេរិក បង់ការប្រាក់៥ (ប្រាំ) ភាគរយក្នុងមួយឆ្នាំ និងបង់ថ្លៃការខូចខាត សេវាកម្មច្បាប់ចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគប្រាក់ដូចបានរៀបរាប់ខាងលើនេះ។ ក្នុងនីតិវិធីត្រៀមទាញហេតុផលផ្ទាល់មាត់ និងនីតិវិធីទាញហេតុផលផ្ទាល់មាត់ ព្រមទាំងការបង្ហាញឆន្ទៈជាមួយភស្តុតាងពាក់ព័ន្ធ និងអង្គច្បាប់តុលាការបានចេញបានចេញសេចក្តីសម្រេច បង្គាប់អោយចុងចម្លើយសងប្រាក់កម្ចី ៥៣,៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិកឱ្យដើមចោទ និងបង់ការប្រាក់៥ (ប្រាំ) ភាគរយក្នុងមួយឆ្នាំរបស់ដើមចោទ សងថ្លៃការខូចខាត ២ ០០០ ០០០ (ពីរលាន) រៀល ការទាមទារលើសពីនេះត្រូវបានច្រានចោល។ មូលដ្ឋាននៃការពិចារណានេះក្រោយតុលាការបានទូទាត់ទៅលើលំដាប់នៃបទប្បញ្ញត្តិ មាត្រា ៥៧៨ មាត្រា ៥៩១ នៃក្រមរដ្ឋប្បវេណីដែលនិយាយអំពីអង្គហេតុនៃការខ្ចីប្រាក់ដែលមិនទាន់ដល់កំណត់សង និងទម្រង់លិខិតសិទ្ធិរំលាយកិច្ចសន្យា ទាមទារប្រាក់កម្ចី ឆន្ទៈរបស់ភាគីសម្រេចតាមអង្គច្បាប់។[89]

**៤. អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារ**

ការទាមទារសំណងការខូចខាតដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ជាសិទ្ធិរបស់ម្ចាស់បំណុល។ បើទោះបីជាម្ចាស់បំណុលមានសិទ្ធិទាមទារលើសំណងនៃការខូចខាតក៏ដោយ ក៏រយៈពេលនៃការអនុវត្តសិទ្ធិនោះត្រូវបានកំណត់ដូចគ្នា។ ចំពោះរយៈពេលនៃការអនុវត្តសិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់បំណុល អាចទាមទារបានក្នុងអំឡុងពេល ៥(ប្រាំ) ឆ្នាំ បន្ទាប់ពីមានការខូចខាតកើតឡើង។[90]

[89] សាលក្រមរដ្ឋប្បវេណីសាលាដំបូងរាជធានីភ្នំពេញ, លេខ៨២៩ «ម» ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨។ (សូមមើលឧបសម្ព័ន្ធទី៣)

[90] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០៦។

# ជំពូកទី៤

# ការសម្រុះសម្រួលដោយ
ការរំលាយកិច្ចសន្យា

# ជំពូកទី៤

# ការសង្គ្រោះដោយការរំលាយកិច្ចសន្យា

ចំពោះការរំលាយកិច្ចសន្យាត្រូវបានកំណត់ជា ៣ប្រភេទមានអត្ថន័យ និងខ្លឹមសារខុសៗគ្នា ដែលក្នុងនោះរួមមានៈ

- ការរំលាយកិច្ចសន្យាតាមការព្រមព្រៀងរវាងភាគី។[91]
- ការរំលាយកិច្ចសន្យាដែលបានកំណត់ក្នុងកិច្ចសន្យា។ [92]
- ការរំលាយកិច្ចសន្យាតាមច្បាប់ (ដោយសារការមិនអនុវត្តកាតព្វកិច្ច) ។

***អំពីការរំលាយកិច្ចសន្យាតាមច្បាប់ (ដោយសារការមិនអនុវត្តកាតព្វកិច្ច) តើត្រូវសិក្សាលើអ្វីខ្លះ ?***

មុនឈានដល់ការរំលាយកិច្ចសន្យា ត្រូវយល់ពីមូលហេតុដែលនាំឱ្យមានការរំលាយកិច្ចសន្យា ដែលជាដំបូងភាគីបានព្រមព្រៀងបង្កើតកិច្ចសន្យាដែលកំណត់ខ្លឹមសារត្រឹមត្រូវស្របតាមគោលបំណងទាំងអស់ដែលខ្លួនចង់បាន ប៉ុន្តែក្នុងពេលអនុវត្តភាគីម្ខាងនៃកិច្ចសន្យានោះ មិនអាចធ្វើឱ្យគោលបំណងនៃកិច្ចសន្យាបានសម្រេចដូចដែលបានព្រមព្រៀង ឬជាន័យសាមញ្ញ គឺភាគីនោះបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរដែលជាហេតុនាំឱ្យភាគីនៃកិច្ចសន្យាម្ខាងទៀតទទួលរងព្យសនកម្មដោយសារការបំពាននោះ អាចទាមទារឱ្យមាននីតិវិធីសង្គ្រោះកិច្ចសន្យាកើតឡើង ហើយក្នុងការសង្គ្រោះកិច្ចសន្យាឃើញមាន**ការរំលាយកិច្ចសន្យា**ផងដែរ។

## ផ្នែកទី១. ការរំលាយកិច្ចសន្យាដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច

ការរំលាយកិច្ចសន្យាដោយសារមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច គឺជាប្រព័ន្ធមួយដែលភាគីនៃកិច្ចសន្យាអញ្ញមញ្ញអាចរួចផុតពីកាតព្វកិច្ចរបស់ខ្លួនដោយយកការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងទៀតមកធ្វើជាមូលហេតុ។[93]

ស្រដៀងគ្នាទៅនឹងអត្ថន័យខាងលើដែរ ការរំលាយកិច្ចសន្យា គឺជាការរំលត់កាតព្វកិច្ចរវាងភាគីនៃកិច្ចសន្យាទៅវិញទៅមក ហើយការរំលាយកិច្ចសន្យានេះទៀតសោត អាចធ្វើបានតែចំពោះកិច្ចសន្យាអញ្ញមញ្ញ

---

[91] **ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង** សំដៅដល់ ការរំលាយផ្អែកលើការបង្ហាញឆន្ទៈត្រូវគ្នារបស់ភាគីនៃកិច្ចសន្យា ដែលពុំមានបំណងបន្តកិច្ចសន្យាដោយមិនពិចារណាអំពីមូលហេតុនៃការរំលាយ។ (ដកស្រង់ចេញពី អត្ថបទរៀបរៀងដោយ លោកស្រីមេធាវី ទេព បូផល, *ស្តីពីការរំលាយកិច្ចសន្យា,* ទំព័រ ១២, យោងតាមមាត្រា ៤១៤ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

[92] **ការរំលាយកិច្ចសន្យាដែលមានកំណត់នៅក្នុងកិច្ចសន្យា** សំដៅដល់ការរំលាយកិច្ចសន្យាដោយផ្អែកលើមូលហេតុដែលមានកំណត់ក្នុងកិច្ចសន្យា។ (ដកស្រង់ចេញពី អត្ថបទរៀបរៀងដោយ លោកស្រីមេធាវី ទេព បូផល, ស្តី*ពីការរំលាយកិច្ចសន្យា* , ទំព័រ ១៤, យោងតាមមាត្រា ៤១៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី)

[93] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២ គន្ថីទី ៤ ស្តីពី «កាតព្វកិច្ច»*, ឆ្នាំ២០១០, ទំព័រ ១២២។

(ជាកិច្ចសន្យាដែលភាគី មានកាតព្វកិច្ចបំពេញចំពោះគ្នាទៅវិញទៅមក ដូចជាភតិសន្យា កិច្ចសន្យាលក់ទិញ ជាអាទិ៍) តែប៉ុណ្ណោះ។[94]

ភាគីនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀត បំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។[95]

ដោយឡែកចំពោះ**កិច្ចសន្យាឯកតោភាគី**[96] មួយចំនួន ក៏អាចធ្វើការរំលាយកិច្ចសន្យាបានផងដែរ ដូចជាកិច្ចសន្យាខ្ចីបរិភោគដែលមានចែងក្នុងមាត្រា ៥៧៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ពីព្រោះកិច្ចសន្យាខ្ចីបរិភោគ ភាគីអ្នកឱ្យខ្ចី គឺជាអ្នកអនុវត្តកាតព្វកិច្ចតែម្នាក់ឯង រហូតដល់ពេលកំណត់សងទើបភាគីម្ខាងទៀតអនុវត្តកាតព្វកិច្ចសងនូវវត្ថុ ជាហេតុនាំឱ្យមានការរំលត់កាតព្វកិច្ច។[97]

ក្នុងការបកស្រាយអត្ថន័យនៃការរំលាយកិច្ចសន្យាខាងលើ ឃើញមានលក្ខខណ្ឌពីរ គួរឱ្យកត់សម្គាល់ដែលបង្កើតឱ្យមានការសង្គ្រោះដោយការរំលាយកិច្ចសន្យានោះគឺៈ

**កថាខណ្ឌទី១. កិច្ចសន្យាអញ្ញមញ្ញ**

កិច្ចសន្យាអញ្ញមញ្ញ គឺជាប្រភេទនៃកិច្ចសន្យាមួយក្នុងចំណោមប្រភេទកិច្ចសន្យាផ្សេងៗទៀត ជាកិច្ចសន្យាដែលភាគីមានបន្ទុកបំពេញកាតព្វកិច្ចទៅវិញទៅមក ដូចជាកិច្ចសន្យាម៉ៅការ ភតិសន្យា កិច្ចសន្យាលក់ទិញ...។ លក្ខណៈនៃកិច្ចសន្យាប្រភេទនេះ ភាគីនៃកិច្ចសន្យាត្រូវអនុវត្តកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមក មិនអាចជាកិច្ចសន្យាដែលភាគីតែម្ខាងត្រូវបំពេញកាតព្វកិច្ចដោយឯកឯងនោះទេ។

ដោយសារជាកិច្ចសន្យាអញ្ញមញ្ញ ភាគីនៃកិច្ចសន្យាត្រូវមានបន្ទុកនៃការបំពេញកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមក។ ជាក់ស្តែងដូចជាកិច្ចសន្យាខ្ចីបរិភោគមានការប្រាក់ ដែលមានភាគីម្ខាងត្រូវបានកំណត់ថាជាម្ចាស់បំណុល មានកាតព្វកិច្ចប្រគល់ប្រាក់ឱ្យភាគីម្ខាងទៀតដែលជាកូនបំណុលនោះបានខ្ចីស្របតាមខ្លឹមសារនៃកិច្ចសន្យា រីឯភាគីកូនបំណុលមានកាតព្វកិច្ចសងនូវប្រាក់ដែលខ្លួនបានខ្ចី ដោយបន្ថែមជាមួយនូវការប្រាក់ដូចដែល

---

[94] ស្ថាប័នសារព័ត៌មាន Fresh News សហការជាមួយ ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, *ស្តីពីការរំលាយកិច្ចសន្យា*, បានផ្សព្វផ្សាយ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០, តំណភ្ជាប់: https://ciclg.com/kh/article/193 , បានចូលមើលថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២។

[95] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០៧។

[96] **កិច្ចសន្យាឯកតោភាគី** គឺជាកិច្ចសន្យាដែលភាគីតែម្ខាងត្រូវទទួលបន្ទុកកាតព្វកិច្ច។

[97] ក្នុងករណីធ្លាក់ចុះនូវទំនុកចិត្តចំពោះអ្នកខ្ចី អ្នកឱ្យខ្ចីអាចធ្វើការរំលាយកិច្ចសន្យាបាន ទោះបីជានេះគឺជាកិច្ចសន្យាឯកតោភាគី ដែលផ្ទុយពីបញ្ញត្តិមាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ចែងថា «ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ»។ (ដកស្រង់ចេញពីក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៥៨១ កថាខណ្ឌទី១)

មានចែងក្នុងកិច្ចសន្យា។ មួយវិញទៀតចំពោះកិច្ចសន្យាលក់ទិញ ដែលមានភាគីមួយកំណត់ថាជាអ្នកលក់និង ម្ខាងទៀតកំណត់ថាជាអ្នកទិញ ក្នុងនោះអ្នកលក់មានបន្ទុកកាតព្វកិច្ចមួយ គឺប្រគល់វត្ថុដែលអ្នកទិញបានកំណត់ តាមពេលវេលា ទីកន្លែងដូចមានចែងក្នុងកិច្ចសន្យា ឬតាមរយៈបញ្ញត្តិច្បាប់កំណត់ក្នុងករណីដែលភាគីមិនបាន ព្រមព្រៀង និងភាគីអ្នកទិញមានបន្ទុកកាតព្វកិច្ចមួយដែរ គឺប្រគល់ប្រាក់ជាតម្លៃតបនៃវត្ថុដែលខ្លួនបានទិញ។

សរុបជារួមមក ការរំលាយកិច្ចសន្យាជានីតិវិធីសង្គ្រោះលើការបំពានកិច្ចសន្យាមួយក្នុងចំណោមនីតិវិធី ផ្សេងៗទៀត ដោយសារមានការបំពានកិច្ចសន្យាពីភាគីម្ខាងយ៉ាងធ្ងន់ធ្ងរ និងធ្វើឱ្យភាគីនៃកិច្ចសន្យាអញ្ញមញ្ញ រលត់កាតព្វកិច្ចរបស់ខ្លួន[98] លើសពីនេះការរំលាយកិច្ចសន្យាអាចធ្វើបានដូចគ្នាលើទម្រង់នៃកិច្ចសន្យាឯកតោ ភាគីមួយចំនួន ដូចជាកិច្ចសន្យាខ្ចីបរិភោគ[99]ជាដើម។

**កថាខណ្ឌទី២. ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ**

ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ច សន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត។[100] ត្រូវចាត់ទុកថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដូចខាងក្រោមនេះ៖

**១. ការមិនអនុវត្តកាតព្វកិច្ចក្នុងរយៈពេលសមរម្យ**

ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ដោយកំណត់ កំឡុងពេលសមរម្យដើម្បីអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងពេលនោះ[101] ក្នុងករណីនេះ ជាការបំពានកិច្ចសន្យាដែលបានកំណត់អំឡុងពេល បន្ទាប់មកភាគីដែលទទួលរងគ្រោះដោយសារការបំពានបាន កំណត់រយៈពេលសមរម្យមួយ ឱ្យភាគីដែលបំពានកិច្ចសន្យាអនុវត្តម្តងទៀត ប៉ុន្តែភាគីនោះនៅតែមិនអនុវត្តដដែល។

ជាក់ស្តែងដូចជាភតិសន្យា ជាប្រភេទកិច្ចសន្យាអញ្ញមញ្ញមួយ ដែលមានភាគីម្ខាងហៅថាភតិកៈ ជាអ្នក ប្រើប្រាស់ និងអាស្រ័យផលលើអចលនវត្ថុ ឬចលវត្ថុដែលជាកម្មវត្ថុនៃភតិសន្យា រីឯភាគីម្ខាងទៀត ហៅថាភតិបតី ជាកម្មសិទ្ធិករលើអចលនវត្ថុ ឬចលនវត្ថុនោះ។ ចំពោះការបង្កើតភតិសន្យានេះ ទោះបីជាធ្វើឡើងដោយលាយ-លក្ខណ៍អក្សរ ឬផ្ទាល់មាត់ក្តីក៏មានសុពលភាពដូចគ្នា ប៉ុន្តែចំពោះកម្មវត្ថុនៃកិច្ចសន្យាដែលជាអចលនវត្ថុ ក្នុង ករណីដែលមិនបានធ្វើជាលាយលក្ខណ៍អក្សរ នោះចាត់ទុកថាជា ភតិសន្យាមិនបានកំណត់កំឡុងពេល។[102] ដូចនេះ ក្នុងករណីភតិសន្យាបានធ្វើឡើងដោយលាយលក្ខណ៍អក្សរ និងដល់ពេលកំណត់ដែលភតិកៈត្រូវអនុវត្ត

---

[98] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០៧។

[99] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៥៨១។

[100] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០៨ កថាខណ្ឌទី១។

[101] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច ក។

[102] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៥៩៩ កថាខណ្ឌទី២។

កាតព្វកិច្ចតាមកិច្ចព្រមព្រៀង ដោយសារមូលហេតុណាមួយធ្វើឱ្យភតិកៈមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ ហើយភតិបតីបានដាស់តឿនដោយកំណត់អំឡុងពេលសមរម្យមួយឱ្យភតិកៈអនុវត្តកាតព្វកិច្ចដដែល ប៉ុន្តែនៅតែមិនអនុវត្ត នាំឱ្យភតិបតីយកមូលហេតុនេះដើម្បីរំលាយកិច្ចសន្យា។

ចំពោះការរំលាយភតិសន្យាដែលមិនមានកំណត់អំឡុងពេលវិញ នៅពេលដែលភាគីម្ខាង មានឆន្ទៈចង់រំលាយ នោះភតិកៈ ឬជាភតិបតីអាចស្នើសុំរំលាយភតិសន្យានៅពេលណាក៏បានដែរ ហើយភតិសន្យានោះនឹងត្រូវបញ្ចប់នៅពេល១ថ្ងៃបានកន្លងផុតទៅចំពោះចលនវត្ថុ រយៈពេល៣ខែកន្លងផុតទៅចំពោះអគារ និងរយៈពេល១ឆ្នាំកន្លងផុតទៅចំពោះដីធ្លី។[103] ម្យ៉ាងទៀតការកំណត់កំឡុងពេលសមរម្យមានរយៈពេលប៉ុន្មាន? ក្នុងការដាស់តឿនដោយមិនបានកំណត់រយៈពេលសមរម្យ តើត្រូវធ្វើដូចម្តេច?

ការកំណត់អំឡុងពេលសមរម្យ គឺជាការទុកពេលមួយរយៈដែលភាគីសងខាង អាចទទួលយកបាន ដើម្បីឱ្យភាគីកូនបំណុលអាចមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ច ដែលបានព្រមព្រៀងជាមួយភាគីម្ចាស់បំណុលបាន។ ក្នុងករណីជូនដំណឹងដោយមិនបានកំណត់អំឡុងពេលសមរម្យ ទោះបីជាមានការដាស់តឿនដោយមិនបានកំណត់អំឡុងពេលសមរម្យ ឬមិនបានកំណត់អំឡុងពេលក៏ដោយ ការរំលាយកិច្ចសន្យាអាចធ្វើបានដែរ នៅពេលដែលអំឡុងពេលសមរម្យបានកន្លងផុតចាប់ពីពេលបានដាស់តឿននោះ។ទោះបីជាគ្មានការដាស់តឿនក៏ដោយ ក៏កូនបំណុលត្រូវអនុវត្តនៅពេលកំណត់អនុវត្តមកដល់ដែរ។ទោះបីជា ក្នុងករណីការអនុវត្តយឺតយ៉ាវក៏ដោយជាទូទៅកូនបំណុលគួរតែរៀបចំ ដើម្បីអនុវត្តហើយមួយភាគធំដែរ ហេតុនេះគឺគ្រាន់តែផ្តល់អំឡុងពេលសមរម្យ ក្រោយពេលដាស់តឿនជាការគ្រប់គ្រាន់។[104]

### ២. ការអនុវត្តកាតព្វកិច្ចក្រោយពេលកំណត់

ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ[105] ដែលជាលក្ខខណ្ឌមួយកំណត់ថា ជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរផង និងមានខ្លឹមសារដូចតទៅៈ

---

103 គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៣ គន្ថីទី ៥ ស្តីពី «កិច្ចសន្យាសំខាន់ៗ និងអំពើអនីត្យានុកូល»*, ឆ្នាំ២០១០, ទំព័រ ៧១។

104 សាស្ត្រាចារ្យ UMEMOTO Yumi, អត្ថបទជា Slide របស់ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់ នាយកដ្ឋានសហការអន្តរជាតិ, *ស្តីពី ការរំលាយកិច្ចសន្យា*, ទំព័រ ១៣។

105 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច ខ។

ម្ចាស់បំណុលមិនទទួលបានអត្ថប្រយោជន៍ទាល់តែសោះ ទោះបីមានការអនុវត្តកាតព្វកិច្ចក្រោយការកំណត់ពេល ម៉្យាងទៀតម្ចាស់បំណុលមិនចាំបាច់ធ្វើការដាស់តឿនទៅកូនបំណុលឡើយ។[106] មួយវិញទៀតករណីខាងលើនេះអាចកំណត់ជា **សកម្មភាពកំណត់ពេលវេលាពិសេស។**

ចំពោះករណីភាគីម្ខាង សុំឱ្យជាងកាត់ដេរកាត់សម្លៀកបំពាក់សម្រាប់ចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍ ប៉ុន្តែជាងកាត់ដេរសម្លៀកបំពាក់ខកខានមិនបានធ្វើតាមពេលវេលាកំណត់ នោះភាគីមានសិទ្ធិរំលាយកិច្ចសន្យានេះនៅពេលដែលភាគីនោះរកឃើញថា ជាងកាត់ដេរមិនអាចកាត់សម្លៀកបំពាក់ឱ្យទាន់ពេលកំណត់ដោយហេតុថា ភាគីនោះគ្មានអត្ថប្រយោជន៍ ក្នុងការទទួលការអនុវត្តកាតព្វកិច្ចនៅក្រោយពេលពិធីរៀបអាពាហ៍ពិពាហ៍។ ប្រភេទនៃការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរអាចត្រូវបានហៅម្យ៉ាងទៀតថា **អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចចំពោះពេលវេលា។**[107] សរុបមកទោះបីជាភាគីម្ខាងនោះបានអនុវត្តកាតព្វកិច្ចក៏ដោយប៉ុន្តែមិនទាន់ពេលវេលាកំណត់ ធ្វើឱ្យគោលបំណងនៃកិច្ចសន្យាមួយនេះមិនបានសម្រេចសោះតែម្តង។

### ៣. ការមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បង

ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវការលិកចម្បងរបស់ខ្លួនបានទេ[108] ត្រង់ករណីការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ដោយមូលហេតុអលទ្ធភាពក្នុងការផ្តល់តាវកាលិកចម្បង គឺចង់បង្ហាញពីការកំណត់តាវកាលិកក្នុងកិច្ចសន្យាមួយ ប៉ុន្តែភាគីដែលត្រូវអនុវត្តកាតព្វកិច្ចមិនបានបំពេញតាវកាលិកដូចមានចែងក្នុងកិច្ចសន្យានោះដោយមូលហេតុផ្សេងៗ។ ក្នុងកិច្ចសន្យានេះ ការផ្តល់តាវកាលិក គឺជាចំណុចសំខាន់នៃកិច្ចសន្យា ដោយភាគីដែលជាអ្នកអនុវត្តកាតព្វកិច្ចមិនអាចសម្រេចគោលដៅនៃកិច្ចសន្យាបានទេ នោះភាគីម្ខាងទៀតអាចប្រើហេតុផលនេះ ឬករណីផ្សេងទៀតទោះបីជាចេតនា ឬអចេតនាក្តីឱ្យតែមិនអាចផ្តល់តាវកាលិកចម្បងបាន នោះភាគីម្ខាងទៀតអាចស្នើសុំធ្វើការរំលាយកិច្ចសន្យាបាន។

ចំពោះសិទ្ធិស្នាក់នៅ គឺជាសិទ្ធិមួយត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣។ ការស្នាក់នៅ គឺជាបន្ទុក សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដ៏ធ្ងន់ធ្ងរ សម្រាប់គ្រួសារដែលមានប្រាក់ចំណូលទាបជាពិសេស គឺកម្មករ សិស្ស និងនិស្សិតដែលមកសិក្សានៅភ្នំពេញ។[109] នៅក្នុងច្បាប់ស្តីពីភតិសន្យាពិសេស ឆ្នាំ ២០១៥ បានកំណត់អំពីកម្មវត្ថុនៃភតិសន្យានេះ គឺជាអចលនវត្ថុដែលជាបន្ទប់ជួលស្នាក់នៅ និងរយៈពេលនៃការ

---

[106] សាស្ត្រាចារ្យ គង់ សុភ័ក្ត្រ, *អត្ថបទស្លាយស្តីពី ការសង្គ្រោះកិច្ចសន្យា*, ឆ្នាំ២០១៨-២០១៩, ទំព័រ ១៧។

[107] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២ គន្ថីទី៤ ស្តីពី «កាតព្វកិច្ច»*, ឆ្នាំ២០១០, ទំព័រ ១២៤ និងទំព័រ ១២៥។

[108] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០៨ កថាខណ្ឌទី៤ ចំណុច គ។

[109] លោកស្រី ប៉ូលី បញ្ញា និងលោក ព្រុំ វិទ្ធី, *អំពីនីតិកិច្ចសន្យាពិសេស ភាគ១*, បោះពុម្ពលើកទី១ ឆ្នាំ២០២១, ទំព័រ ១៧៣។

ជួលនេះគឺមានអត្ថិភាពមិនតិចជាង២ឆ្នាំ ឬមិនបានកំណត់រយៈពេល ត្រូវមានអត្ថិភាព២ឆ្នាំ។[110] បន្ទាប់ពីភតិសន្យាពិសេសនេះមានអានុភាពហើយ ភាគីនៃកិច្ចសន្យាត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដោយភតិបតីត្រូវផ្តល់បន្ទប់ជួលទៅឱ្យភតិកៈរស់នៅ ចំណែកភតិកៈត្រូវបង់ថ្លៃឈ្នួលដែលបានកំណត់ដូចក្នុងកិច្ចសន្យា។ ចំពោះករណីភតិកៈ មិនបានបង់ថ្លៃឈ្នួលរយៈពេល២ដងបន្តបន្ទាប់ ដោយគ្មានមូលហេតុសមស្រប (ឧទាហរណ៍ ការព្រមព្រៀងកំណត់បង់ថ្លៃឈ្នួលជាខែ នោះបើភតិកៈមិនបានបង់ថ្លៃឈ្នួល២ដង) ភតិបតីអាចធ្វើការរំលាយភតិសន្យាពិសេសបាន។[111]

បើក្រឡេកមើលទៅស្ថានភាពមុនការរីករាលដាលវីរុសកូវីដ១៩ចូលមកដល់កម្ពុជា ការអនុវត្តកិច្ចសន្យារបស់គូភាគី មិនសូវមានការបំពានណាមួយកើតឡើងគួរឱ្យកត់សម្គាល់ទេ ប៉ុន្តែដោយសារស្ថានភាពកូវីដ១៩បន្ទាប់ពីមានព្រឹត្តិការណ៍ថ្ងៃ២០ កុម្ភៈ បានធ្វើឱ្យស្ថានភាពការរីករាលដាលជំងឺកូវីដ១៩ កាន់តែធ្ងន់ធ្ងរទៅៗ កម្មករដែលបំពេញការងារនៅតាមសហគ្រាស ឬរោងចក្រកាត់ដេរផ្សេងៗបាត់បង់ការងារ ដោយសាររោងចក្រ ឬសហគ្រាសត្រូវបានបិទបណ្តោះអាសន្ន ឬលែងដំណើរការតែម្តង ជាហេតុផលនាំឱ្យភតិកៈគ្មានប្រាក់គ្រប់គ្រាន់ដើម្បីបង់ថ្លៃឈ្នួលដល់ភតិបតី។ លើសពីនេះក្នុងបរិបទកូវីដ១៩ កម្មករគ្មានការងារធ្វើ ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅតើមានប្រាក់ឯណាដើម្បីបង់ថ្លៃឈ្នួលបន្ទប់ជួល? នេះជាបញ្ហាចោទមួយ បើអនុវត្តតាមទិដ្ឋភាពច្បាប់ មិនបង់ថ្លៃឈ្នួល២ដង នោះភតិបតីអាចអនុវត្តសិទ្ធិលើការរំលាយកិច្ចសន្យា ប៉ុន្តែស្របនឹងបញ្ហាសង្គមជាក់ស្តែងតើគួរមាននីតិវិធី ឬដំណោះស្រាយណាមួយ ដែលល្អ សមស្របសម្រាប់ភាគីទាំងសងខាងដែរឬទេ?

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច។[112] ដូចនេះ បើទោះបីជាភាគីបានសន្យាគ្នាថា បង់ថ្លៃឈ្នួលក្នុងពេលកំណត់ណាមួយ ឬចំនួនទឹកប្រាក់ប៉ុន្មានក៏ដោយ ក៏ភាគីអាចធ្វើការកែប្រែខ្លឹមសារនោះឡើងវិញបាន ឱ្យតែភាគីមានឆន្ទៈត្រូវគ្នា។ បើក្រឡេកមើលសង្គមក្នុងបរិបទកូវីដ១៩ អ្នកទទួលរងផលប៉ះពាល់ក្នុងភតិសន្យាពិសេសនេះ គឺភតិបតីដោយសារតែភតិកៈមិនបង់ថ្លៃឈ្នួល ត្រង់ចំណុចនេះអាចសន្និតបានថា ដំណោះស្រាយអាចនឹងស្ថិតលើភតិបតី តើគួរមានការលើកលែងការបង់ថ្លៃឈ្នួល ឬមានការបញ្ចុះតម្លៃ ឬមានការពន្យាពេលឱ្យភតិកៈបានដែរឬទេ? មានន័យថាទោះបីជាភតិកៈមិនអនុវត្តកាតព្វកិច្ច តើក្រៅពីនីតិវិធីនៃការសង្គ្រោះកិច្ចសន្យាដូចជាសំណងការខូចខាត ការរំលាយកិច្ចសន្យាជាដើម ភាគីនៃកិច្ចសន្យាអាចជ្រើសរើសមធ្យោបាយផ្សេងឬទេ?

---

[110] ច្បាប់ស្តីពីភតិសន្យាពិសេស, លេខ នស/រកម/០៧១៥/០០៩, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៥, មាត្រា ៣ និងមាត្រា ៦។

[111] ច្បាប់ស្តីពីភតិសន្យាពិសេស, លេខ នស/រកម/០៧១៥/០០៩, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៥, មាត្រា ៧។

[112] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣១១។

ជាក់ស្តែងម្ចាស់បន្ទប់ជួលមួយចំនួនបានសម្រេចផ្អាកយកថ្លៃឈ្នួលបន្ទប់មួយរយៈពេល ខណៈពេលម្ចាស់ផ្ទះខ្លះបញ្ចុះតម្លៃពី ៤០ ទៅ ៥០ ភាគរយ ដើម្បីជួយសម្រាលបន្ទុកដល់អ្នកជួល បន្ទាប់ពីបានមើលឃើញពីការលំបាកក្នុងការរកប្រាក់ចំណូលមកផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ដោយសារការរីករាលដាលនៃវីរុសកូវីដ១៩ ពិសេសការចម្លងក្នុងព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ។ ចំពោះ ម្ចាស់អាជីវកម្មផ្ទះជួល ដែលស្ថិតក្នុងសង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល លោក ឈឿន ប៊ុនឆន បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា លោកបានសម្រេចផ្អាកយកថ្លៃឈ្នួលបន្ទប់ពីអ្នកជួលទាំងអស់ដែលមានទាំងកម្មកររោងចក្រ និងបុគ្គលិកឯកជនរយៈពេល ៣ ខែ គឺចាប់ពីខែមីនា មេសា និងខែឧសភា។ លោកបានប្រាប់ថា *«ខ្ញុំមានបន្ទប់ជួល ៦៩ បន្ទប់ ដែលភាគច្រើនជាកម្មកររោងចក្រជួលស្នាក់នៅ ហើយថ្ងៃនេះខ្ញុំសម្រេចមិនយកថ្លៃឈ្នួល ៣ ខែ ប៉ុន្តែថ្លៃទឹក និងភ្លើងពួកគាត់ជាអ្នកចេញដោយខ្លួនឯង»*។ លោកបានបន្ថែមថា *«គ្រប់អាជីវកម្មសុទ្ធតែជួបការលំបាកទាំងអស់នៅទូទាំងប្រទេស ប៉ុន្តែមានអ្នកខ្លះយល់ថា រោងចក្រមិនទាន់បិទទ្វារទេ ដូចនេះកម្មកររោងចក្រមិនទាន់ពិបាកទេ តែសម្រាប់រូបលោកបែរជាគិតខុសពីនោះទៅវិញ»*។ ម្យ៉ាងវិញទៀត *«រោងចក្រនៅតំបន់របស់លោកនោះមានកម្មករមួយចំនួនបានចាប់ផ្តើមបាត់បង់ការងារថែមម៉ោង និងគ្មានអីវ៉ាន់សម្រាប់ធ្វើច្រើនដូចមុនទៀតទេ»*។[113]

មួយវិញទៀតដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល រដ្ឋបាលរាជធានីភ្នំពេញក្នុងការគិតគូរ និងជួយទ្រទ្រង់ជីវភាពរបស់បងប្អូនប្រជាពលរដ្ឋដែលកំពុងស្នាក់នៅផ្ទះជួល ឬបន្ទប់ជួលនោះ រដ្ឋបាលរាជធានីភ្នំពេញបានធ្វើការអំពាវនាវ អោយម្ចាស់ផ្ទះជួល ឬបន្ទប់ជួលទាំងអស់ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ពិនិត្យលទ្ធភាពបញ្ចុះតម្លៃ ឬលើកលែងការបង់ថ្លៃឈ្នួលផ្ទះ ឬឈ្នួលបន្ទប់ ក្នុងអំឡុងពេលនៃការផ្ទុះ ព្រឹត្តិការណ៍ «សហគមន៍ ២០កុម្ភៈ»នេះ ដោយបន្តអោយពួកគាត់ស្នាក់នៅ មិនគួរបណ្តេញពួកគាត់ចេញឡើយ។ នេះបើយោងទៅតាមសេចក្តីអំពាវនាវរបស់រដ្ឋបាលរាជធានីភ្នំពេញដែលសារព័ត៌មានកម្ពុជាថ្មីប្រចាំថ្ងៃទទួលបាន នៅល្ងាចថ្ងៃទី២៦ មីនានេះ ដែលក្នុងសេចក្តីអំពាវនាវនេះមានន័យថា ការផ្ទុះរីករាលដាលនៃមេរោគកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ «សហគមន៍ ២០ កុម្ភៈ» នៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ រហូតមកទល់បច្ចុប្បន្ននេះបានធ្វើឱ្យបងប្អូនប្រជាពលរដ្ឋមួយចំនួនបានទទួលរងផល ប៉ះពាល់ខ្លាំង ក្នុងនោះអ្នកជួលផ្ទះ ឬជួលបន្ទប់ កំពុងជួបការលំបាកក្នុងការបង់ថ្លៃឈ្នួលផ្ទះ ឬឈ្នួលបន្ទប់ផងដែរ។[114]

---

[113] គេហទំព័រផ្លូវការ: ភ្នំពេញប៉ុស្តិ៍, បានផ្សព្វផ្សាយថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១, តំណភ្ជាប់: ម្ចាស់ផ្ទះ ឬបន្ទប់ជួលផ្អាក និងបញ្ចុះថ្លៃឈ្នួលដើម្បីសម្រាលបន្ទុកដល់អ្នកជួល | ភ្នំពេញ ប៉ុស្តិ៍ (postkhmer.com), Youtube: https://youtu.be/Qp3Q562okvI , បានចូលមើលថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២២។

[114] កម្ពុជាថ្មីប្រចាំថ្ងៃ KAMPUCHEA TMEY DAILY,បានផ្សព្វផ្សាយថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១, តំណភ្ជាប់: រដ្ឋបាលរាជធានី អំពាវនាវឲ្យម្ចាស់ផ្ទះជួលបន្ទប់ជួល បញ្ចុះតម្លៃ ឬលើកលែងការបង់ថ្លៃឈ្នួលក្នុងអំឡុងពេលនៃការផ្ទុះព្រឹត្តិការណ៍ «សហគមន៍២០កុម្ភៈ» (kampucheathmey.com) ,បានចូលមើលថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២២។

ក្នុងសេចក្តីអំពាវនាវរបស់រដ្ឋបាលរាជធានីភ្នំពេញ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ មានខ្លឹមសារដូចជា៖

- ពិនិត្យលទ្ធភាពបញ្ចុះតម្លៃ ឬលើកលែងការបង់ថ្លៃឈ្នួលផ្ទះ ឬឈ្នួលបន្ទប់ ក្នុងអំឡុងពេលនៃការផ្ទុះព្រឹត្តិការណ៍ «សហគមន៍ ២០ កុម្ភៈ» រហូតដល់ស្ថានភាពធូរស្រាលជាងមុនឡើងវិញ។
- យោគយល់អធ្យាស្រ័យចំពោះការយឺតយ៉ាវក្នុងការបង់ថ្លៃឈ្នួលផ្ទះ ឬបន្ទប់ជួល ពីសំណាក់អ្នកជួលទាំងឡាយ ដោយគួរលើកលែងការពិន័យឱ្យបង់ប្រាក់បន្ថែម ឬដកយកប្រាក់កក់ចំពោះការយឺតយ៉ាវក្នុងការបង់ថ្លៃឈ្នួល និងបន្តអនុញ្ញាតឱ្យអ្នកជួលស្នាក់នៅបន្តទៀត ដោយមិនគួរបណ្តេញចេញឡើយ។[115]

### ៤. ការបំពានកិច្ចសន្យានាំឱ្យបាត់បង់ទំនុកចិត្ត

ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាពេលអនាគតបាន។[116]

ការបំពានកិច្ចសន្យាដែលមានភាពហួសហេតុ ធ្វើឱ្យបាត់បង់ទំនុកចិត្តរវាងភាគី មិនមែនសំដៅតែករណីដែលភាគីម្ខាងបានធ្វើការបំពានលើកិច្ចសន្យាលក្ខណៈធ្ងន់ធ្ងរខ្លាំង ដែលភាគីម្ខាងទៀតមិនអាចទទួលយកបានឡើយ ប៉ុន្តែការបំពានកិច្ចសន្យាមានភាពហួសហេតុ ត្រង់ចំណុចនេះមានលក្ខណៈសំដៅលើ ដំណើរការនៃកិច្ចសន្យាមួយ ភាគីដែលជាអ្នកត្រូវអនុវត្តកាតព្វកិច្ច បានធ្វើការបំពានកិច្ចសន្យាមានលក្ខណៈស្រាលៗបែបសាមញ្ញ ប៉ុន្តែការបំពាននេះមានលក្ខណៈច្រើនលើកច្រើនសា ម្តងហើយម្តងទៀត ជាហេតុធ្វើឱ្យភាគីម្ខាងទៀតបាត់បង់ជំនឿចិត្តតែម្តង។ នៅក្នុងកិច្ចសន្យាមួយ ការគោរពគ្នា ការបំពេញកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមកពិតជាផ្នែកមួយដ៏សំខាន់ ប៉ុន្តែការបំពេញកាតព្វកិច្ចមិនមែនឱ្យតែបានបំពេញរួចរាល់ទើបទទួលបានលទ្ធផលល្អទេ ក្នុងករណីដែលអ្នកអនុវត្តកាតព្វកិច្ចមានភាពយឺតយ៉ាវនៅអំឡុងពេលអនុវត្ត ម្តងហើយម្តងទៀត ជាលើកទី១ មានលើកទី ២ និងលើកក្រោយៗទៀត ទោះជាកាតព្វកិច្ចត្រូវបំពេញក៏ដោយ ក៏អាចធ្វើឱ្យភាគីម្ខាងទៀតបាត់បង់ទំនុកចិត្តអាចបង្ហាញឆន្ទៈរំលាយកិច្ចសន្យាបាន។

ជាក់ស្តែងនៅក្នុងកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ដែលក្នុងនោះមានភាគីម្ខាងជាម្ចាស់បំណុល និងភាគីម្ខាងទៀតជាកូនបំណុល បានព្រមព្រៀងក្នុងការខ្ចីប្រាក់ដែលភ្ជាប់ **ការប្រាក់** [117] ក្នុងនោះកូនបំណុលបានខ្ចីប្រាក់ចំនួន USD ៥៨០០០ (ប្រាំមុឺនប្រាំបីពាន់ដុល្លារ) ដោយយល់ព្រមលើលក្ខខណ្ឌអត្រាការប្រាក់ ១៦%

---

[115] សេចក្តីអំពាវនាវរបស់រដ្ឋបាលរាជធានីភ្នំពេញ, គ្មានលេខ, *ស្តីពីការផ្ទុះរីករាលដាលនៃមេរោគកូវីដ១៩ ក្នុងព្រឹត្តិការណ៍ «សហគមន៍ ២០ កុម្ភៈ» នៅរាជធានីភ្នំពេញ,* ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១។ (សូមមើលឧបសម្ព័ន្ធទី៤)

[116] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច ឃ។

[117] **ការប្រាក់** សំដៅទៅលើចំនួនទឹកប្រាក់ ឬវត្ថុផ្សេងទៀត ដែលត្រូវបានផ្តល់ទៅឱ្យតាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ក្នុងនាមជាតម្លៃតមចំពោះការប្រើប្រាស់ប្រាក់ ឬ វត្ថុ ដែលត្រូវបានប្រគល់ឱ្យអ្នកខ្ចី ហើយដែលត្រូវបានគណនាដោយយកចំនួនទឹកប្រាក់ ឬវត្ថុដែលបានខ្ចីមកគុណជាមួយនឹងអត្រាដែលបានកំណត់។

(ដប់ប្រាំមួយភាគរយ) ក្នុងមួយឆ្នាំ និងរយៈពេលបង់ចំនួន ៦០ខែចាប់ពីថ្ងៃចុះកិច្ចសន្យា។ បន្ទាប់ពីមានការព្រមព្រៀងចំពោះកិច្ចសន្យារួចហើយភាគីកូនបំណុលបានអនុវត្តកាតព្វកិច្ច ប៉ុន្តែមានលក្ខណៈយឺតយ៉ាវ ម្តងហើយម្តងទៀតអំឡុងពេលអនុវត្តបង់ប្រាក់ ទោះបីជាភាគីម្ចាស់បំណុលបានដាស់តឿន ជូនដំណឹងដោយផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរឱ្យបង់ប្រាក់ឱ្យទៀងពេលវេលាក៏ដោយ ប៉ុន្តែកូនបំណុលនៅតែមិនអនុវត្តតាម។ ជាមូលហេតុធ្វើឱ្យភាគីម្ចាស់បំណុលមិនបានដឹងអំពីស្ថានភាពរបស់កូនបំណុលថាមានលទ្ធភាពបង់ ឬមិនមានលទ្ធភាពបង់ប្រាក់បន្តឬអត់? នាំឱ្យម្ចាស់បំណុលលែងមានទំនុកចិត្ត និងភាពជឿជាក់។ ក្នុងករណីនេះម្ចាស់បំណុលមានសិទ្ធិគ្រប់គ្រាន់ក្នុងការស្នើរំលាយកិច្ចសន្យាព្រមទាំងទាមទារសំណងការខូចខាតដែលកើតមាន។

រីឯការបំពានកិច្ចសន្យាមានភាពហួសហេតុ ធ្វើឱ្យភាគីម្ខាងលែងជឿជាក់ថា ភាគីម្ខាងទៀតមិនអាចអនុវត្តកាតព្វកិច្ចនាពេលអនាគត ជាការបំពានកិច្ចសន្យាមួយប្រភេទ អាចថាភាគីដែលជាអ្នកអនុវត្តកាតព្វកិច្ចមិនបានអនុវត្តទៅតាមខ្លឹមសារនៃកិច្ចសន្យាដែលបានព្រមព្រៀងគ្នា ដែលខ្លឹមសារត្រង់ចំណុចនេះ ជាផ្នែកសំខាន់ដែលឱ្យភាគីម្ខាងទៀតជឿជាក់ ព្រមបង្កើតកិច្ចសន្យា។ ភាគីនៃកិច្ចសន្យាបានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាដោយបានកំណត់ខ្លឹមសារមួយចំនួនដើម្បីភាគីម្ខាងត្រូវបំពេញ និងអនុវត្តតាមនាពេលអនាគតទើបភាគីម្ខាងទៀតព្រមបង្កើតកិច្ចសន្យា ប៉ុន្តែបន្ទាប់ពីបង្កើតកិច្ចសន្យា ភាគីម្ខាងដែលទទួលបានអត្ថប្រយោជន៍នៃកិច្ចសន្យា មិនបានអនុវត្តលក្ខខណ្ឌមួយចំនួននៃកិច្ចសន្យា ដែលការមិនអនុវត្តតាមលក្ខខណ្ឌនោះធ្វើអាចឱ្យភាគីម្ខាងទៀត បាត់បង់ជំនឿចិត្តលែងជឿជាក់ថា ភាគីនោះមិនអាចអនុវត្តកាតព្វកិច្ចនាពេលអនាគតទោះបីជាពេលវេលាកំណត់នៃការអនុវត្តកាតព្វកិច្ចមិនទាន់ដល់ក៏ដោយ។

ឧទាហរណ៍ កិច្ចសន្យាខ្ចីបរិភោគជាប្រាក់ ដែលមានភាគីម្ខាងបានសន្យាថាខ្ចីលុយដើម្បីបង្កើតកសិដ្ឋានចិញ្ចឹមសត្វគោ បន្ទាប់ពីទទួលបានផល ទើបខ្លួនសងប្រាក់ មូលហេតុនេះហើយធ្វើឱ្យភាគីម្ខាងទៀតព្រមព្រៀងបង្កើតកិច្ចសន្យានោះ ប៉ុន្តែភាគីកូនបំណុលនៅពេលបានទទួលប្រាក់រួចរាល់ ខ្លួនមិនបានយកប្រាក់ទៅធ្វើកសិដ្ឋានចិញ្ចឹមសត្វគោទេ ជាហេតុផលភាគីម្ចាស់បំណុលលែងជឿជាក់ថាកូនបំណុលអាចអនុវត្តកាតព្វកិច្ចនាពេលអនាគត នាំឱ្យភាគីម្ចាស់បំណុលលែងជឿជាក់អាចអាចរំលាយមុនពេលកំណត់។

ការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីកូនបំណុល គឺអាចមានករណីដែលកូនបំណុលមានកំហុស ឬចេតនាផ្ទាល់របស់កូនបំណុល មួយវិញទៀតការបំពានកាតព្វកិច្ចរបស់កូនបំណុលក៏អាចកើតឡើងដោយសារករណីផ្សេងៗទៀតដែលមិនមែនដោយសារជាកំហុសរបស់កូនបំណុលនោះដែរ។ បើទោះបីជាយ៉ាងណាក៏ដោយ ករណីដែលការមិនអនុវត្តកាតព្វកិច្ចមិនមែនជាកំហុសរបស់កូនបំណុល ក៏ភាគីកូនបំណុលមិនអាចរារាំងការរំលាយកិច្ចសន្យាបានទេ។

## ផ្នែកទី២. វិធីសាស្ត្ររំលាយកិច្ចសន្យា

### កថាខណ្ឌទី១. សិទ្ធិរបស់ភាគីក្នុងការរំលាយកិច្ចសន្យា

សម្រាប់ការរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច ក្នុងករណីដែលភាគីម្ខាងចង់ធ្វើការរំលាយកិច្ចសន្យានោះ ទាល់តែក្នុងដំណើរការអនុវត្តកិច្ចសន្យា ភាគីម្ខាងទៀតបានបំពានកិច្ចសន្យា ដែលស្របតាមមាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី (កិច្ចសន្យាដែលចង់រំលាយជាកិច្ចសន្យាអញ្ញមញ្ញ) និងមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី (មានការបំពានកិច្ចសន្យាធ្ងន់ធ្ងរ) ទើបភាគីម្ខាងដែលចង់រំលាយកិច្ចសន្យាអាចប្រើសិទ្ធិរំលាយបាន។

### កថាខណ្ឌទី២. ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា

ក្នុងការរំលាយកិច្ចសន្យាដោយមូលហេតុមិនអនុវត្តកាតព្វកិច្ច ភាគីដែលមានសិទ្ធិរំលាយកិច្ចសន្យាអាចធ្វើការបង្ហាញឆន្ទៈរបស់ខ្លួនដល់ភាគីដែលម្ខាងទៀតដែលបានបំពានកិច្ចសន្យាធ្ងន់ធ្ងរនោះ។ ការបង្ហាញឆន្ទៈរបស់ភាគី ដែលមានបំណងចង់បង្កើតអានុភាពគតិយុត្ត ហើយការបង្ហាញឆន្ទៈ ត្រូវមានអានុភាព ចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈបានទៅដល់ភាគីម្ខាងទៀត។[118]

ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា អាចធ្វើឡើងក្រៅប្រព័ន្ធតុលាការបាន[119] មានន័យថា ភាគីចង់រំលាយកិច្ចសន្យាគ្រាន់តែបង្ហាញឆន្ទៈថា ខ្លួនចង់រំលាយកិច្ចសន្យានោះ ទៅភាគីម្ខាងទៀតជាការស្រេចមិនចាំបាច់ធ្វើការដាក់ពាក្យបណ្ដឹងទៅតុលាការដើម្បស្នើសុំចេញសេចក្ដីសម្រេចអំពីការរំលាយកិច្ចសន្យានោះទេ។ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យានេះ អាចធ្វើទៅបានសម្រេច បើភាគីដែលជាអ្នកបំពានកិច្ចសន្យានោះ យល់ព្រមទទួលសំណើរំលាយកិច្ចសន្យា ប៉ុន្តែបើក្នុងករណីភាគីនោះមិនព្រមរំលាយតាមកិច្ចសន្យាទេ ភាគីដែលបានបង្ហាញឆន្ទៈចង់រំលាយកិច្ចសន្យា អាចដាក់ពាក្យសុំទៅតុលាការដើម្បីធ្វើការដោះស្រាយ និងចេញសេចក្ដីសម្រេច។

ការរំលាយកិច្ចសន្យានេះ មិនអាចដកវិញបានទេ ត្រង់ចំណុចនេះ ទាក់ទងនឹងការរំលាយកិច្ចសន្យា ភាគីត្រូវធ្វើការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាទៅកាន់ភាគីម្ខាងទៀត បន្ទាប់ពីការបង្ហាញឆន្ទៈនោះបានទៅដល់ភាគីដែលមិនបានអនុវត្តកាតព្វកិច្ច ការរំលាយនឹងមានអានុភាព។ ផ្ទុយទៅវិញបន្ទាប់ពីការរំលាយកិច្ចសន្យាមានអានុភាព ភាគីដែលជាអ្នកស្នើសុំរំលាយកិច្ចសន្យានោះ បញ្ឈប់ការចង់រំលាយកិច្ចសន្យាវិញ ករណីនេះមិនអាចធ្វើបានទេ។

ប៉ុន្តែបើភាគីដែលចង់រំលាយកិច្ចសន្យា បានដកការរំលាយកិច្ចសន្យានោះវិញ តើនឹងមានអ្វីកើតឡើង? ចំពោះការបង្ហាញឆន្ទៈរំលាយដែលមានអានុភាពហើយ ក្នុងករណីដែលភាគីនោះលែងចង់រំលាយវិញ គឺនឹងអាច

---

[118] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣១០។

[119] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤០៩ កថាខណ្ឌទី១។

មានរឿងជាច្រើនដែលមិនអាចស្មានដឹង អាចធ្វើឱ្យមានភាពច្របូកច្របល់ រញ៉េរញ៉ៃ និងអាចធ្វើឱ្យកិច្ចសន្យានោះប្រែទៅជាមានអានុភាពវិញផងដែរ។ នោះជាហេតុផលដែលធ្វើឱ្យក្នុងកថាខណ្ឌទី៣ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណីចែងមិនអាចដកវិញបាន។ ប៉ុន្តែគោលការណ៍ទូទៅនៃការបង្ហាញឆន្ទៈ ដែលមានបំណងចង់រំលាយកិច្ចសន្យាដែលធ្វើឡើងដោយជនដែលត្រូវបានគេកម្រិតសមត្ថភាព ដូចជាអនីតិជន ជនស្ថិតក្រោមអាណាព្យាបាលទូទៅ ជនស្ថិតក្រោមហិតូបត្ថម្ភ ឬករណីដែលការបង្ហាញឆន្ទៈរំលាយកិច្ចសន្យានោះមានវិការៈដូចជា ដោយការភាន់ច្រឡំ ដោយការឆបោក ឬការគម្រាមកំហែង និងការបង្ហាញឆន្ទៈដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ សុទ្ធតែអាចលុបចោល ឬដកចេញបាន។ ឧទាហរណ៍ ភតិសន្យាមួយបង្កើតឡើងដោយមានកម្មវត្ថុជាការជួលអគារ ភតិកៈមានបំណងយកអគារដែលជួលនោះមកធ្វើជាសាលារៀនសម្រាប់កុមារជប៉ុន។ ភតិកៈបានយល់ព្រមធ្វើកិច្ចព្រមព្រៀងជាមួយភតិបតីដោយកំណត់ថ្លៃឈ្នួល USD ១000 (មួយពាន់ដុល្លារអាមេរិក) ក្នុងមួយខែ និងមានរយៈពេលជួលចំនួន ៦ (ប្រាំមួយ) ឆ្នាំ។ ប៉ុន្តែ ក្រោយឆ្នាំទី ៣ នៃរយៈពេលជួល ភតិកៈបានបំពានកិច្ចសន្យាធ្ងន់ធ្ងរ នាំឱ្យភតិបតីបានបង្ហាញឆន្ទៈរំលាយកិច្ចសន្យាទៅកាន់ភតិកៈ បន្ទាប់មកទៀត ភតិកៈបានផ្ញើស្ទីការយល់ព្រម។ ដូច្នេះ ការរំលាយកិច្ចសន្យាដែលមានអានុភាពរួចហើយបែបនេះ នាំឱ្យកិច្ចសន្យានេះពុំមានអានុភាពទៀតឡើយ ទោះជាមានការស្នើសុំដកការរំលាយពីភតិកៈ ឬភតិបតីក៏ដោយ។

ការបង្ហាញឆន្ទៈរំលាយ អាចដាក់ល័ក្ខខ័ណ្ឌបង្អង់បាន[120] ដោយសារការធ្វើបែបនេះមានលក្ខណៈងាយស្រួល ដូចជាករណីការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីកូនបំណុល ហើយភាគីម្ចាស់បំណុលបានដាស់តឿនឱ្យអនុវត្តកាតព្វកិច្ចក្នុងកំឡុងពេលជាក់លាក់ណាមួយ ដោយភាគីម្ចាស់បំណុលភ្ជាប់លក្ខខណ្ឌពេលបង្ហាញឆន្ទៈថា «នឹងរំលាយកិច្ចសន្យា បើសិនភាគីកូនបំណុលមិនអនុវត្តកាតព្វកិច្ចក្នុងអំឡុងពេលកំណត់នោះ»។ ឧទាហរណ៍នេះ គឺជាករណីភ្ជាប់ល័ក្ខខ័ណ្ឌបង្អង់ចំពោះការបង្កើតអានុភាពនៃការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា។[121]

ជាក់ស្តែងទាក់ទងនឹង ការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងក្នុងភតិសន្យា ដែលកម្មវត្ថុនៃកិច្ចសន្យាគឺការជួលអចលនវត្ថុ ក្នុងនោះភតិកៈបានបំពានកិច្ចសន្យាធ្ងន់ធ្ងរដោយមិនបានបង់ប្រាក់ជួលលើអចលនវត្ថុឱ្យទៅភតិបតី ដោយមូលហេតុអលទ្ធភាពក្នុងការអនុវត្ត ភតិបតីអាចរំលាយកិច្ចសន្យាបាន ដោយសំអាងលើចំណុច **ក** មាត្រា ៤០៨នៃក្រមរដ្ឋប្បវេណី ប៉ុន្តែមុនពេលបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ភតិបតីបានដាក់លក្ខខណ្ឌមួយ គឺកំណត់កំឡុងពេលច្បាស់លាស់ម្តងទៀតឱ្យភតិកៈអនុវត្តកាតព្វកិច្ចបង់ថ្លៃជួលលើអចលវត្ថុ ប៉ុន្តែបើនៅតែមិនបង់

[120] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៣០៩ កថាខណ្ឌទី៣។

[121] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២ គន្ថីទី ៤ «ភាតព្វកិច្ច»*, ឆ្នាំ២០១០, ទំព័រ ១២៦។

ថ្លៃឈ្នួលនោះ ភតិបតីនឹងរំលាយកិច្ចសន្យាភ្លាមៗ ត្រង់ចំណុចនេះសន្និដ្ឋានថាជាការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាភ្ជាប់ជាមួយលក្ខខណ្ឌបង្អង់។

**ផ្នែកទី៣. អានុភាពនៃការរំលាយកិច្ចសន្យា**

ការរំលាយកិច្ចសន្យាមានអានុភាពទៅលើ៖

**កថាខណ្ឌទី១. អានុភាពចំពោះគូភាគីនៃកិច្ចសន្យា**

ការរំលាយកិច្ចសន្យា នាំឱ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យាលើកលែងតែករណីយកិច្ចសងការខូចខាត។[122] បន្ទាប់ពីភាគីម្ខាងបានបង្ហាញឆន្ទៈចង់រំលាយកិច្ចសន្យា ហើយភាគីដែលជាអ្នកមិនអនុវត្តកាតព្វកិច្ចបានយល់ព្រមរំលាយកិច្ចសន្យាតាមសំណើរបស់ភាគីម្ខាង នាំឱ្យករណីយកិច្ចផ្សេងៗដែលមានចែងក្នុងកិច្ចសន្យារបស់ភាគីត្រូវបញ្ចប់ការអនុវត្តតែម្តង និយាយឱ្យខ្លីគឺភាគីគ្មានការបំពេញកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមកដូចពេលដំណើរការអនុវត្តកិច្ចសន្យាទេ ប៉ុន្តែក៏មានករណីមួយចំនួនត្រូវបានលើកលែង ដែលទោះបីជាបន្ទាប់ពីរំលាយកិច្ចសន្យាក៏ដោយ ក៏ភាគីម្ខាងត្រូវមានករណីយកិច្ចដែលត្រូវអនុវត្តដដែល នោះគឺអ្នកបំពានកិច្ចសន្យាត្រូវសងសំណងការខូចខាតផ្សេងៗជាថ្នូរនឹងការរំលោភបំពានកិច្ចសន្យារបស់ខ្លួន ក្នុងករណីដែលការរំលាយកិច្ចសន្យានោះភ្ជាប់ជាមួយការសងសំណងការខូចខាត។

ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬទាំងអស់ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីនោះទទួល**បដិទាន**[123] ឡើងវិញដោយការរំលាយ។ ក្នុងករណីដែលភាគីទាំងសងខាងមានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។[124] ត្រង់ផ្នែកនេះ តាវកាលិកដែលជាកម្មវត្ថុនៃកិច្ចសន្យា ត្រូវបានភាគីម្ខាង ឬទាំងសងខាងបានអនុវត្ត ឬបានបំពេញឱ្យគ្នាទៅវិញទៅមក នោះភាគីម្ខាង ឬទាំងសងខាងនោះត្រូវប្រគល់ត្រឡប់នូវតាវកាលិកនោះឱ្យម្ចាស់ដើមវិញ លើសពីនេះបញ្ញត្តិច្បាប់បានកំណត់ ក្នុងករណីដែលភាគីសងខាងបានបំពេញតាកាលិកឱ្យគ្នាទៅវិញទៅមក នោះភាគីត្រូវប្រគល់ត្រឡប់មកវិញស្របពេលជាមួយគ្នា បន្ទាប់ពីមានការរំលាយកិច្ចសន្យា។

ភាគីដែលមានករណីយកិច្ចសងជាប្រាក់ដោយការរំលាយកិច្ចសន្យា ត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានទទួលប្រាក់ដើមនោះ។ ភាគីដែលមានករណីយកិច្ចបង្វិលជាវត្ថុ ឬជាតាវកាលិកផ្សេង

---

[122] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤១១ កថាខណ្ឌទី១។

[123] **បដិទាន** គឺជាការស្តារឡើងវិញនូវស្ថានភាពដើម ឬការប្រគល់ត្រឡប់វិញ។ (ដកស្រង់ចេញពីសទ្ទានុក្រមផ្នែករដ្ឋប្បវេណី)

[124] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤១១ កថាខណ្ឌទី២។

ដែលខ្លួនបានទទួល ទៅភាគីម្ខាងទៀតដោយសារការរំលាយ ត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬ តាវកាលិកនោះផងដែរ។ [125]

ត្រង់ចំណុចអានុភាពនៃការរំលាយកិច្ចសន្យានេះ មានលក្ខណៈសាមញ្ញ គេកំណត់លើករណីយកិច្ចសង ជាប្រាក់ បើកម្មវត្ថុជាប្រាក់ នោះបន្ទាប់ពីរំលាយកិច្ចសន្យា ភាគីនោះត្រូវប្រគល់ទាំងប្រាក់ដើម បូកបន្ថែមជាមួយ ការប្រាក់ផងដែរ។ ចំពោះការប្រាក់នេះ អាចសម្គាល់ឃើញថា បើភាគីបានព្រមព្រៀងគ្នាក្នុងកិច្ចសន្យាពាក់ព័ន្ធ នឹងការប្រាក់ នោះត្រូវអនុវត្តតាមកិច្ចសន្យា ប៉ុន្តែបើមិនមានការព្រមព្រៀង នោះការប្រាក់ត្រូវកំណត់ដូចបញ្ញត្តិ ច្បាប់។

### កថាខណ្ឌទី២. អានុភាពចំពោះតតិយជន

ការរំលាយកិច្ចសន្យាមិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ[126] ក្នុងករណី នេះមានន័យថាការរំលាយកិច្ចសន្យាដែលពាក់ព័ន្ធនឹងតតិយជនមានទំនាក់ទំនងផលប្រយោជន៍ និងតតិយជន នោះជាជនសុចរិត នោះអានុភាពនៃការរំលាយមិនអាចប៉ះពាល់ដល់ផលប្រយោជន៍ជននោះបានទេ។

## ផ្នែកទី៤. ការរំលត់នៃសិទ្ធិរំលាយកិច្ចសន្យា

ក្នុងការរំលត់សិទ្ធិរំលាយកិច្ចសន្យា បញ្ញត្តិទូទៅនៃក្រមរដ្ឋប្បវេណីបានកំណត់ដូចជា ការរំលត់សិទ្ធិ រំលាយកិច្ចសន្យាដោយអាជ្ញាយុកាល (កថាខណ្ឌទី១) និងការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយសារកម្មវត្ថុនៃ កិច្ចសន្យាបានខូចខាត ឬ បាត់បង់ (កថាខណ្ឌទី២)។

### កថាខណ្ឌទី១. ការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយអាជ្ញាយុកាល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និងសិទ្ធិ ទាមទារបដិទានមានអំឡុងពេល៥ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច។[127]

ពាក់ព័ន្ធនឹងការរំលាយកិច្ចសន្យាដោយមូលហេតុមិនអនុវត្តកាតព្វកិច្ចត្រូវបំពេញលក្ខខណ្ឌសំខាន់ៗពីរៈ

- កិច្ចសន្យាដែលចង់រំលាយជាប្រភេទកិច្ចសន្យាអញ្ញមញ្ញ
- ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ។

បន្ទាប់ពីលក្ខខណ្ឌទាំងពីរត្រូវបានបំពេញ ភាគីម្ចាស់បំណុលអាចបង្ហាញឆន្ទៈរំលាយកិច្ចសន្យាបានទៅ កាន់ភាគីកូនបំណុល។ សំណួរបានចោទសួរថា តើការរំលាយកិច្ចសន្យាបន្ទាប់ពីមានការបំពានកិច្ចសន្យាកើត ឡើង អាចធ្វើឡើងនៅពេលណា? វាមិនដូចនឹងការទាមទារឱ្យសងសំណងការខូចខាតទេ អាជ្ញាយុកាលនៃសិទ្ធិ

[125] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤១១ កថាខណ្ឌទី៣។
[126] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤១១ កថាខណ្ឌទី៥។
[127] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៤១៣។

រំលាយ គិតចាប់ពីពេលដែលមានការមិនអនុវត្តកាតព្វកិច្ច។ ការរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និងសិទ្ធិទាមទារបដិទាន ភាគីម្ចាស់បំណុលអាចធ្វើបានក្នុងកំឡុងពេល ៥ឆ្នាំប៉ុណ្ណោះ បន្ទាប់ពីមានការបំពានកិច្ចសន្យាកើតឡើង។ ក្នុងករណីកន្លងផុតទៅ ៥ឆ្នាំបន្ទាប់ពីមានការបំពានកិច្ចសន្យាកើតឡើងហើយ ភាគីម្ចាស់បំណុលមិនអាចធ្វើការរំលាយកិច្ចសន្យា ឬទាមទារបដិទាននូវវត្ថុណាមួយដែលជាកម្មវត្ថុនៃកិច្ចសន្យាបានទេ មានន័យថា **អាជ្ញាយុការនៃសិទ្ធិរំលាយ និងសិទ្ធិទាមទារបដិទានត្រូវបានរំលត់។**

ប៉ុន្តែចំពោះបញ្ញត្តិពិសេសនៃកិច្ចសន្យាលក់ទិញ ក្នុងករណីដែលអ្នកលក់បានប្រគល់វត្ថុដែលមានវិការៈ[128] ឱ្យអ្នកទិញ ភាគីអ្នកទិញអាចប្រើសិទ្ធិរំលាយកិច្ចសន្យារបស់ខ្លួនបាន[129] ប៉ុន្តែអំឡុងពេលនៃការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាមួយនេះ គឺមានអាជ្ញាយុកាលរយៈពេល១ (មួយ) ឆ្នាំ។[130]

### កថាខណ្ឌទី២. ការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយសារកម្មវត្ថុនៃកិច្ចសន្យាបានខូចខាត ឬបាត់បង់

ជាទូទៅ ប្រសិនបើកិច្ចសន្យាមួយត្រូវបានរំលាយ ភាគីនៃកិច្ចសន្យានោះមានករណីយកិច្ចធ្វើបដិទាន មានន័យថាត្រូវប្រគល់មកវិញនូវវត្ថុដែលខ្លួនបានទទួលនោះឱ្យទៅភាគីម្ខាងទៀត បញ្ហាចោទមានឡើងត្រង់សិទ្ធិរំលាយកិច្ចសន្យាអាចអនុវត្តបានដែរឬទេ នៅពេលភាគីនោះមិនអាចប្រគល់វិញនូវវត្ថុនោះបាន ដោយសារវត្ថុដែលត្រូវប្រគល់វិញនោះបានបាត់បង់ ឬទទួលការខូចខាត?[131]

សិទ្ធិរំលាយកិច្ចសន្យារបស់ភាគី ដែលបានធ្វើឱ្យបាត់បង់នូវវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ត្រូវរលត់។ ឧទាហរណ៍ ក្នុងការរំលាយកិច្ចសន្យាលក់ទិញដោយមូលហេតុ រថយន្តជាកម្មវត្ថុនៃកិច្ចសន្យាមានវិការៈ ដែល

---

[128] វត្ថុដែលបានប្រគល់ឱ្យទៅអ្នកទិញត្រូវបានចាត់ទុកថា មានវិការៈមានលក្ខណៈដូចជា
- វត្ថុនោះមានភាពមិនស្របនឹងចំនួន គុណភាព និងលក្ខណៈដែលបានកំណត់ក្នុងកិច្ចសន្យា។
- វត្ថុនោះមានភាពផ្សេងពីគំរូដែអ្នកលក់បានបង្ហាញឱ្យអ្នកទិញមើលចំពោះ ចំនួន គុណភាព និងលក្ខណៈ។
- វត្ថុនោះមិនស្របនឹងវិធីប្រើដែលអ្នកលក់ត្រូវបានបង្ហាញ ដោយជាក់លាក់ ឬដោយតុណ្ហីភាព នៅពេលធ្វើកិច្ចសន្យា។
- វត្ថុនោះមិនស្របនឹងវិធីប្រើធម្មតានៃវត្ថុប្រភេទដូចគ្នា។
- វត្ថុនោះមិនត្រូវបានខ្ចប់តាមវិធីធម្មតានៃការខ្ចប់វត្ថុប្រភេទដូចគ្នា ឬតាមវិធីសមរម្យដើម្បីការពារវត្ថុនោះ។ (ដកស្រង់ចេញពី មាត្រា ៥៣៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

[129] **សិទ្ធិរំលាយកិច្ចសន្យារបស់អ្នកទិញ** ក្នុងករណីដែលអ្នកទិញមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាលក់ទិញបានដោយសារវត្ថុដែលត្រូវបានប្រគល់មានវិការៈ អ្នកទិញនោះអាចរំលាយកិច្ចសន្យានោះបាន។ (ដកស្រង់ចេញពី ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៥៤៣)

[130] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៥៤៧ កថាខណ្ឌទី១។

[131] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ២ គន្ថីទី ៤ «កាតព្វកិច្ច»*, ឆ្នាំ២០១០, ទំព័រ ១៣១។

អំឡុងពេលអនុវត្តកិច្ចសន្យា ភាគីអ្នកទិញមិនបានដឹងនោះទេថា រថយន្តនោះមានវិការៈ ប៉ុន្តែភាគីអ្នកទិញបានធ្វើឱ្យខូចខាតដោយចេតនាបន្ថែមទៀតដល់រថយន្តដែលខ្លួនត្រូវប្រគល់វិញ អ្នកទិញនោះត្រូវបាត់បង់សិទ្ធិរំលាយ។

ចំពោះ កម្មវត្ថុនៃកិច្ចសន្យា លក់ទិញ ដែលវត្ថុនោះត្រូវបានរកឃើញថា មានការខូចខាតតាំងពីមុនពេលមកដល់ដៃអ្នកទិញ ក្រោយមកអ្នកទិញបានដឹងច្បាស់ថាវត្ថុនោះមានការខូចខាតនៅត្រង់ណាមួយ បើទោះបីជាកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាតក៏ពិតមែន ប៉ុន្តែវាមិនមែនជាកំហុសរបស់អ្នកទិញនោះទេ។ នាំឱ្យការរំលត់សិទ្ធិរំលាយកិច្ចសន្យាមិនអាចធ្វើបានឡើយ មានន័យថាអ្នកទិញនៅតែមានសិទ្ធិរំលាយកិច្ចសន្យាបាន។ [132]

[132] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧, មាត្រា ៥៤០ កថាខណ្ឌទី១។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ជារួមមក ក្នុងយន្តការណាមួយនៃការសង្គ្រោះកិច្ចសន្យា សុទ្ធតែជាដំណោះស្រាយមួយយ៉ាងល្អប្រសើរ និងពិតជាមានសារៈប្រយោជន៍ជាច្រើនពាក់ព័ន្ធ នឹងទំនាក់ទំនងមួយដែលផ្សារភ្ជាប់នឹងការអនុវត្តកាតព្វកិច្ច។ ដោយហេតុថា កាលណាភាគីកូនបំណុលបានបំពានកិច្ចសន្យា ម្ចាស់បំណុលអាចជ្រើសរើសការសង្គ្រោះកិច្ចសន្យាណាមួយតាមរយៈ ការរំលាយកិច្ចសន្យា ឬការទាមទារសំណងនៃការខូចខាត ឬការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំជាដើម។ យន្តការទាំងអស់នេះសុទ្ធតែត្រូវបានកំណត់ក្នុងច្បាប់ ដើម្បីជួសជុលព្យសនកម្មដែលកើតឡើងលើម្ចាស់បំណុល ដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល។

ចំពោះការដោះស្រាយតាមនីតិវិធីឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ គឺជាការសង្គ្រោះមួយដែលមានលក្ខណៈចាប់បង្ខំដល់ភាគីកូនបំណុលឱ្យអនុវត្តកាតព្វកិច្ចតាមផ្លូវតុលាការ ហើយនីតិវិធីនេះមានលក្ខណៈល្អប្រសើរដល់ភាគីម្ចាស់បំណុលដែលអាចទាមទារតាវកាលិកដែលបានបាត់បង់ និងមានប្រសិទ្ធិភាពខ្ពស់។ រីឯការទាមទារសំណងការខូចខាត ជានីតិវិធីសង្គ្រោះដែលមានសារសំខាន់ដល់ភាគីម្ចាស់បំណុល អាចទាមទារសំណងតាមរយៈព្យសនកម្មដែលបានកើតឡើងមកលើខ្លួន ដោយសារមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល។ ចុងក្រោយ ការរំលាយកិច្ចសន្យាដែលជាការសង្គ្រោះកិច្ចសន្យាមួយ បានផ្តល់ផលប្រយោជន៍ជាច្រើនដល់ម្ចាស់បំណុល បន្ទាប់ពីការរំលាយកិច្ចសន្យានោះមានអានុភាព មានន័យថានៅពេលកូនបំណុលបានបំពេញលក្ខខណ្ឌនៃការបំពានកិច្ចសន្យាធ្ងន់ធ្ងរ នោះម្ចាស់បំណុលអាចបង្ហាញឆន្ទៈរំលាយកិច្ចសន្យារបស់ខ្លួនដល់កូនបំណុលបានភ្លាមៗ ដោយមិនចាំបាច់ឡើងទៅដល់តុលាការឡើយ ប៉ុន្តែក្នុងករណីដែលកូនបំណុលមិនផ្តល់ស្ទីការឆ្លើយតប សំណើនៃការរំលាយកិច្ចសន្យានោះទេ ភាគីម្ចាស់បំណុលអាចដាក់ពាក្យស្នើសុំទៅតុលាការបានដដែរ។

បើក្រឡេកមើលមធ្យោបាយមួយចំនួនផ្សេងទៀត ពាក់ព័ន្ធនឹងការសម្របសម្រួលរវាងភាគី ក៏ជានីតិវិធីមួយដែលអាចជួយដល់ការបំពានកិច្ចសន្យាផងដែរ ព្រោះថាមធ្យោបាយសម្របសម្រួលនេះគឺមិនបានធ្វើឱ្យបញ្ចប់ដំណើរការនៃការអនុវត្តកាព្វកិច្ចរបស់ភាគីនោះទេ។ លើសពីនេះ មធ្យោបាយសម្របសម្រួល គឺជាយុទ្ធ-សាស្ត្រមួយដែលឱ្យគូភាគីឈ្នះទាំងសងខាង មានន័យថាភាគីម្ចាស់បំណុលនៅតែទទួលបានអត្ថប្រយោជន៍របស់ខ្លួនពីកូនបំណុល រីឯកូនបំណុលនៅតែអាចបន្តអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានដដែល។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការបកស្រាយ និងសិក្សាយ៉ាងលម្អិតអំពី «**ការសង្គ្រោះចំពោះការបំពានកិច្ចសន្យា**» រួចមក ការប្រើប្រាស់វិធីសាស្ត្រណាមួយមិនថាតាមវិធីសម្របសម្រួល ឬតាមនីតិវិធីច្បាប់ សុទ្ធតែជាវិធានដែលអាចអនុវត្តយ៉ាងមានប្រសិទ្ធភាពក្នុងករណីដែលមានវិវាទកិច្ចសន្យាកើតឡើង។ ជាអនុសាសន៍ដើម្បីឆ្លើយតបនឹងស្ថានភាពជាក់ស្តែងដែលបានកើតឡើងនៅក្នុងប្រធានបទនេះ និងផ្តល់ជាចំណេះដឹងពាក់ព័ន្ធការសង្គ្រោះកិច្ចសន្យាដើម្បីជៀសវាងកើតមានវិវាទនាពេលក្រោយ៖

- ភាគីគួរតែចែងខសន្យាបន្ថែមនៅក្នុងកិច្ចសន្យា ដោយមានការព្រមព្រៀងកំណត់ទុកជាមុននូវមូលហេតុនៃការរំលាយកិច្ចសន្យា ព្រមទាំងកំណត់ទំហំសំណងនៃការខូចខាតក្នុងករណីមានការបំពានកើតឡើង ដើម្បីចងជាកាតព្វកិច្ចដល់គូភាគីឱ្យអនុវត្តកិច្ចសន្យា
- មួយវិញទៀត ដោយសារតែទំហំ និងរូបមន្តវាស់នូវព្យសនកម្មដែលបានកើតឡើងក្រោយការបំពានកិច្ចសន្យាមិនមានចែងលម្អិតក្នុងច្បាប់ ចំពោះភាគីគួរមានការបង្ហាញឆន្ទៈដោយខ្លួនឯងបង្កើតខ្លឹមសារនៃកិច្ចសន្យាបន្ថែមស្តីពីចំណុចមួយចំនួនបន្ទាប់ពីមានការបំពានអំពីដំណោះស្រាយ និងវិធីសាស្ត្រផ្សេងៗដែល ជាលក្ខខណ្ឌដ៏ល្អមួយជំនួសវិធីសាស្ត្រការសង្គ្រោះកិច្ចសន្យាដែលកំណត់តាមច្បាប់មានលក្ខណៈចាប់បង្ខំ
- ក្រសួង និងស្ថាប័នពាក់ព័ន្ធនានា គួរតែមានការធ្វើបច្ចុប្បន្នភាពផ្នែកច្បាប់បន្ថែមដែលបញ្ញត្តិអំពីការផ្តល់សិទ្ធិដល់គូភាគីក្នុងការដាក់លក្ខខណ្ឌមួយចំនួនទាក់ទង ការអនុវត្តករណីដែលកូនបំណុលបានបំពានកិច្ចសន្យា ដើម្បីឱ្យគាត់អាចជ្រើសរើស នីតិវិធីសម្របសម្រួលណាមួយលើការបំពាន ឬការសម្របសម្រួលណាដែលជួយដោះស្រាយវិវាទកិច្ចសន្យាបានល្អប្រសើរ។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីភតិសន្យាពិសេស, លេខ នស/រកម/០៧១៥/០០៩, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១។
- ច្បាប់ស្តីពីការដាក់ឱ្យអនុវត្តក្រមរដ្ឋប្បវេណី, លេខ/នស/រកម/០៥១១/០០៧, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។
- ក្រមរដ្ឋប្បវេណី, លេខ នស/រមក/១២០៧/០៣០, ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦។
- ប្រកាសអន្តរក្រសួង, ស្តីពី «ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី» លេខ៥៩ ប្រក.ជ.នស/ ១១, ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១១។
- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល, លេខ ៤៩សសរ, *ស្តីពី «ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩»*, ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១។
- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៥០សសរ, *ស្តីពី «ការកែសម្រួលវិធានការដែលត្រូវអនុវត្តក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩»*, ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១។
- សាលក្រមរដ្ឋប្បវេណីសាលាដំបូងរាជធានីភ្នំពេញ, លេខ៨២៩ «ម» ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨។
- សេចក្តីអំពាវនាវរបស់រដ្ឋបាលរាជធានីភ្នំពេញ, គ្មានលេខ, *ស្តីពី «ការផ្ទុះរីករាលដាលនៃមេរោគកូវីដ១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ» នៅរាជធានីភ្នំពេញ*, ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១។
- ក្រឹត្យច្បាប់លេខ៣៨ ក្រ.ច, *ស្តីពី «កិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា»*, ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨។ (និរាករណ៍)

## ២. សៀវភៅ និងឯកសារ

- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើ សេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *ភាគ២ ស្តីពី «ការអនុវត្តដោយបង្ខំ និងកាចាត់ចែងរក្សាការពារ»*, ឆ្នាំ២០០៩។
- ក្រុមប្រឹក្សាអ្នកច្បាប់ និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីព្រាងលើកទី៣ *ច្បាប់ស្តីពីអាជ្ញាសាលា*។

– គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណីរបស់ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ២ គន្ថីទី ៤ ស្តីពី «ភាគព្វកិច្ច»*, ឆ្នាំ២០១០។

– គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណីរបស់ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៣ គន្ថីទី ៥, ស្តីពី «កិច្ចសន្យាសំខាន់ៗ និងអំពើអនីត្យានុកូល»* ឆ្នាំ២០១០។

– គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រី, *«សទ្ទានុក្រមច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី»*, ឆ្នាំ២០០៧។

– គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ *«សទ្ទានុក្រមពាក្យច្បាប់»*, បោះពុម្ពឆ្នាំ ២០០៧។

– គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ នៃក្រសួងយុត្តិធម៌ រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, *ស្តីពី «ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១»*។

– សាស្ត្រាចារ្យ គង់ សុភ័ក្រ្ត, អត្ថបទស្លាយ, *ស្តីពី «ការសង្គ្រោះកិច្ចសន្យា»*, ឆ្នាំ២០១៨ ដល់ឆ្នាំ ២០១៩។

– មេធាវី ទេព បូផល, អត្ថបទរៀបរៀង, *ស្តីពី «ការរំលាយកិច្ចសន្យា»*។

– លោកស្រី ប៉ូលី បញ្ញា និងលោក ព្រុំ រិទ្ធី, អត្ថបទរៀបរៀង, *ស្តីពី «នីតិកិច្ចសន្យាពិសេស ភាគ១»*, បោះពុម្ពលើកទី១ ឆ្នាំ២០២១។

– លោក ស៊ុម សុខម្ភ, អត្ថបទរៀបរៀង, *ស្តីពី «បច្ចេកទេស និងវិធីសាស្ត្របទស្រាយគតិយុត្តនានា» (រាជបណ្ឌិតសភាវិជ្ជាជីវតុលាការ)*។

– សាស្ត្រាចារ្យ HIGASHIO Kazuyuki និង សាស្ត្រាចារ្យ YUKAWA Ryo, អត្ថបទស្លាយ *ស្តីពី «ការអនុវត្តដោយបង្ខំ (ការលក់ដោយបង្ខំនូវអចលនវត្ថុ)»*។

– សាស្ត្រាចារ្យ ហេង បូរ៉ា, អត្ថបទរៀបរៀង, *ស្តីពី «នីតិកាតព្វកិច្ច»*។

– សាស្ត្រាចារ្យ UMEMOTO Yumi, អត្ថបទជាស្លាយ របស់ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅ, *ស្តីពី «កិច្ចការច្បាប់ នាយកដ្ឋានសហការអន្តរជាតិ»*។

– មេធាវី អ៊ីវ ប៉ូលី, អត្ថបទជាស្លាយ, *ស្តីពី «ការរំលាយកិច្ចសន្យា»*, ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧។

### ៣. គេហទំព័រ

- កម្ពុជាថ្មីប្រចាំថ្ងៃ KAMPUCHEA TMEY DAILY, *ស្តីពី «រដ្ឋបាលរាជធានី អំពាវនាវឲ្យម្ចាស់ផ្ទះជួល បន្ទប់ជួល បញ្ចុះតម្លៃ ឬលើកលែងការបង់ថ្លៃឈ្នួលក្នុងអំឡុងពេលនៃការផ្ទុះព្រឹត្តិការណ៍សហគមន៍២០ កុម្ភៈ»*, បានផ្សព្វផ្សាយថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១, តំណភ្ជាប់: (kampucheathmey.com), បានចូលមើលនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២២។
- ភ្នំពេញប៉ុស្តិ៍, *ស្តីពី «ម្ចាស់ផ្ទះ ឬបន្ទប់ជួលផ្អាក និងបញ្ចុះថ្លៃឈ្នួល ដើម្បីសម្រាលបន្ទុកដល់អ្នកជួល ၊ ភ្នំពេញ ប៉ុស្តិ៍»*, បានផ្សព្វផ្សាយថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១, តំណភ្ជាប់: https://youtu.be/Qp3Q562okvI, បានចូលមើលថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២។
- ស្ថាប័នសារព័ត៌មាន Fresh News, *ស្តីពី «សម្តេច ហ៊ុន សែន អំពាវនាវឱ្យម្ចាស់ទីតាំងជួលឱ្យអ្នកដទៃរកស៊ី ត្រូវពន្យាពេលបង់លុយ ឬទម្លាក់តម្លៃក្នុងវិបត្តិCovid-19»*, បានផ្សព្វផ្សាយថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០, តំណភ្ជាប់: https://youtu.be/JsC1aCTE-WM, បានចូលមើលនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០២២។
- ស្ថាប័នសារព័ត៌មាន Fresh News សហការជាមួយ ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, *ស្តីពី «ការរំលាយកិច្ចសន្យា»*, បានផ្សព្វផ្សាយ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០, តំណភ្ជាប់: https://ciclg.com/kh/article/193, បានចូលមើលនៅ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២២។
- ស៊ិន ចន្ទី ប្រធានសមាគមភស្តុភារកម្មកម្ពុជា, *ស្តីពី «វិស័យដឹកជញ្ជូនកម្ពុជាហាក់ងើបឡើងវិញបន្ទាប់ពីបញ្ហា Covid-19 អាចគ្រប់គ្រងបាននៅកម្ពុជា»* តំណភ្ជាប់: https://www.propertyarea.asia/archives/48925, បានចូលមើលនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០២២។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| ល.រ | ឈ្មោះ | លេខឧបសម្ព័ន្ធ |
|---|---|---|
| **១** | សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល, លេខ ៤៩សសរ, ស្តីពីការបិទខ្ទប់ភូមិសាស្រ្ត រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃ ជំងឺកូវីដ១៩, ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ | **ឧបសម្ព័ន្ធទី១** |
| **២** | សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៥០សសរ, ស្តីពីការកែសម្រួលវិធានការ ដែលត្រូវអនុវត្តក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្រ្តរាជធានីភ្នំពេញនិងក្រុងតាខ្មៅនៃ ខេត្ត កណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩, ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ | **ឧបសម្ព័ន្ធទី២** |
| **៣** | សាលក្រមរដ្ឋប្បវេណីសាលាដំបូងរាជធានីភ្នំពេញ, លេខ៨២៩ «ម», ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ | **ឧបសម្ព័ន្ធទី៣** |
| **៤** | សេចក្តីអំពាវនាវរបស់រដ្ឋបាលរាជធានីភ្នំពេញ,គ្មានលេខ,ស្តីពីការផ្ទុះរីករាលដាល នៃមេរោគកូវីដ១៩ ក្នុងព្រឹត្តិការណ៍«សហគមន៍២០កុម្ភៈ»នៅរាជធានីភ្នំពេញ, ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ | **ឧបសម្ព័ន្ធទី៤** |

# ឧបសម្ព័ន្ធទី១

## សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល, លេខ៤៩សសរ, ស្តីពីការបិទខ្ទប់ភូមិសាស្ត្រ រាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩, ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៤៩ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល**
**ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- យោងតាមតម្រូវការចាំបាច់ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## សម្រេច

**ប្រការ១.-**

ត្រូវបានបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ជាបណ្តោះអាសន្នសម្រាប់រយៈពេល ១៤ថ្ងៃ គិតចាប់ពីវេលាម៉ោងសូន្យនាថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ក្នុងគោលបំណងធានាដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល និងទប់ស្កាត់ជំងឺនេះមិនឱ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត។

ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ត្រូវចាត់ទុកជាភូមិសាស្ត្រតែមួយដែលត្រូវបានបិទខ្ទប់។

**ប្រការ២.-**

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់នេះ បុគ្គលគ្រប់រូបត្រូវបានហាមឃាត់មិនឱ្យធ្វើដំណើរចេញពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្នរបស់ខ្លួន ប្រសិនបើគ្មានការចាំបាច់។

ប៉ុន្តែ ការធ្វើដំណើរចេញក្រៅពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្ន អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការធ្វើដំណើរទៅបំពេញការងារ ឬប្រកបមុខរបរ ឬអាជីវកម្មក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ដែលមិនមានការហាមឃាត់ដូចបានកំណត់ក្នុងប្រការ៣ និងដោយមានភ្ជាប់ឯកសារបញ្ជាក់អំពីការងារ មុខរបរ ឬអាជីវកម្ម ដែលចេញដោយទីកន្លែងអាជីវកម្មពាក់ព័ន្ធ ឬអាជ្ញាធរដែនដីដែលមានទីតាំងនៅជិតបំផុត
- ការធ្វើដំណើរទៅកាន់ទីកន្លែងលក់ម្ហូបអាហារ ឬគ្រឿងឧបភោគបរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃដែលអនុញ្ញាតឱ្យបើកដំណើរការដោយអាជ្ញាធរមានសមត្ថកិច្ច។ ការធ្វើដំណើរក្នុងគោលបំណងនេះ អាចធ្វើឡើងដោយសមាជិកយ៉ាងច្រើន ២ (ពីរ) នាក់ ក្នុងមួយលំនៅឋានឬទីសំណាក់ មិនឱ្យលើសពី ៣(បី) ដង ក្នុងមួយសប្តាហ៍ និងនៅទីតាំងដែលជិតបំផុតក្នុងរង្វង់ភូមិសាស្ត្រក្រុង ឬខណ្ឌដែលខ្លួនរស់នៅ ដោយត្រូវយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬប័ណ្ណសម្គាល់ខ្លួន
- ការធ្វើដំណើរទៅមន្ទីរពេទ្យ មណ្ឌលសុខភាព សម្ភព ទីកន្លែងព្យាបាល ឬឱសថស្ថាន ដោយមូលហេតុសុខភាពបន្ទាន់ នៅក្នុងរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់។ ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់នេះ ចេញក្រៅឬចូលក្នុងរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ អាចធ្វើទៅបានដោយមានការអនុញ្ញាតពីអាជ្ញាធរដែលអនុវត្តវិធានការបិទខ្ទប់ ដោយកំណត់ចំនួនមនុស្សមិនឱ្យលើសពី ៤ (បួន) នាក់សម្រាប់ករណីនីមួយៗ ប៉ុន្តែត្រូវអនុវត្តដាច់ខាតនូវកាតព្វកិច្ចទាក់ទងនឹងវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេសការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព
- ការធ្វើដំណើរដើម្បីទៅបង្ហាញខ្លួនឱ្យមន្ត្រីសុខាភិបាលធ្វើការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងដើម្បីទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ តាមកាលកំណត់ និងនៅក្នុង ឬចេញក្រៅរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់
- ការធ្វើដំណើរដើម្បីចូលរួមក្នុងសកម្មភាពដែលបម្រើប្រយោជន៍សាធារណៈ ឬគោលបំណងចាំបាច់ផ្សេងទៀត តាមការស្នើសុំ ឬតាមការកំណត់របស់អាជ្ញាធរសាធារណៈ

- ការធ្វើសកម្មភាពកីឡាជាលក្ខណៈបុគ្គលក្នុងរង្វង់ភូមិសាស្ត្រភូមិដែលខ្លួនរស់នៅ ដោយចៀសវាងការជួបជុំមនុស្សលើសពី ២ (ពីរ) នាក់
- ការធ្វើដំណើររបស់មន្ត្រីការទូត មន្ត្រីបុគ្គលិកនៃស្ថានតំណាងបរទេស ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការហិរញ្ញវត្ថុអន្តរជាតិ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលបរទេស ដោយមានភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងការងារ
- ការធ្វើដំណើររបស់អ្នកសារព័ត៌មាន ដោយមានភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងការងារ
- ការធ្វើដំណើរចេញ-ចូលតំបន់បិទខ្ទប់តាមផ្លូវអាកាស ដោយត្រូវគោរពតាមបទប្បញ្ញត្តិ និងវិធានការសុវត្ថិភាពផ្នែកសុខាភិបាលជាធរមាន និង
- ការធ្វើដំណើរដោយមូលហេតុចាំបាច់និងបន្ទាន់ផ្សេងទៀត ដោយមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់។

រាល់ការលើកលែងខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាល រួមមាន ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្ដៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**ប្រការ៣ ..**

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ ត្រូវបានហាមឃាត់រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្មទាំងអស់ ដែលមិនមែនជាតម្រូវការចាំបាច់ប្រចាំថ្ងៃ។

ប៉ុន្តែ សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- សកម្មភាពការងាររបស់ស្ថាប័នសាធារណៈ និងកងកម្លាំងប្រដាប់អាវុធ ប៉ុន្តែប្រធានស្ថាប័នសាមីត្រូវកាត់បន្ថយចំនួនអ្នកធ្វើការឱ្យមកនៅត្រឹមកម្រិតអប្បបរមា ដើម្បីធានានិរន្តរភាពការងាររបស់ស្ថាប័ន។ ប្រធានស្ថាប័នអាចសម្រេចផ្អាកការងារដែលមិនចាំបាច់ជាបណ្ដោះអាសន្ន តាមការជាក់ស្ដែង
- រោងចក្រ សហគ្រាស សិប្បកម្ម ឬទីកន្លែងផលិតម្ហូបអាហារ និងគ្រឿងឧបភោគបរិភោគ ដោយរួមទាំងទីសត្តឃាត ដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ
- សកម្មភាពការងារដែលពាក់ព័ន្ធនឹងការផ្ដល់សេវាសាធារណៈ តាមការកំណត់របស់ស្ថាប័ននីមួយៗ ជាអាទិ៍ សេវាពន្លត់អគ្គិភ័យ, សេវាផ្គត់ផ្គង់អគ្គិសនី, ទឹកស្អាត, សេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង ជាដើម
- រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលដំណើរការតាមរយៈប្រព័ន្ធអនឡាញ
- ការផ្គត់ផ្គង់ទំនិញដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ ហាងលក់ទំនិញ ផ្សារលក់ដុំ ផ្សារឬទីតាំងលក់ដូរគ្រឿងឧបភោគបរិភោគដែលមានសណ្ដាប់ធ្នាប់ ផ្សារម៉ាត និងភោជនីយដ្ឋាន-អាហារដ្ឋានដែលលក់ជាអាហារវេចខ្ចប់, ស្ថានីយ៍ប្រេងឥន្ធនៈ-ហ្គាស ឬទីតាំងផ្គត់ផ្គង់ទំនិញដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច
- ការផ្គត់ផ្គង់សេវាដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ សេវាសង្គ្រោះបន្ទាន់, សេវាសុខាភិបាល និងឱសថស្ថាន, សេវាប្រៃសណីយ៍-ទូរគមនាគមន៍, សេវាធនាគារ និងហិរញ្ញវត្ថុ និងសេវាដែលជា

តម្រូវការចាំបាច់ប្រចាំថ្ងៃផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ប៉ុន្តែ ត្រូវកាត់បន្ថយចំនួនបុគ្គលិកបម្រើការឱ្យមកនៅត្រឹមកម្រិតអប្បបរមា
- សេវាកម្មសណ្ឋាគារ និងផ្ទះសំណាក់
- សេវាកម្មដឹកជញ្ជូនទំនិញចាំបាច់ដើម្បីបម្រើឱ្យភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់
- សេវាកម្មដឹកជញ្ជូនទំនិញទូទៅចេញ-ចូល ឬឆ្លងកាត់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ដើម្បីបម្រើឱ្យវិស័យសង្គម-សេដ្ឋកិច្ចនៃប្រទេស និង
- សកម្មភាពការងារ មុខរបរ ឬអាជីវកម្មចាំបាច់ផ្សេងទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្មដែលត្រូវបានអនុញ្ញាតដូចបានរៀបរាប់ខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាល រួមមានការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្តៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**ប្រការ៤ ..**

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ ត្រូវហាមឃាត់រាល់ការជួបជុំ ឬការប្រមូលផ្តុំមនុស្ស។ ប៉ុន្តែ ការជួបជុំ ឬការប្រមូលផ្តុំមនុស្ស អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖
- ការជួបជុំក្នុងចំណោមសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅឋានឬទីសំណាក់ជាមួយគ្នា
- ការរៀបចំពិធីបុណ្យសព ដោយគោរពតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច
- ការប្រមូលផ្តុំមនុស្ស និងការជួបជុំរបស់បុគ្គលិកសុខាភិបាល ដើម្បីអនុវត្តវិធានការសុខាភិបាល ជាអាទិ៍ ការយកវត្ថុសំណាកមកវិភាគរកមេរោគកូវីដ-១៩ និងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងការជួបជុំរបស់បុគ្គលិកសុខាភិបាលដែលបំពេញការងារសង្គ្រោះបន្ទាន់ផ្សេងទៀត និង
- ការជួបជុំរបស់អាជ្ញាធរមានសមត្ថកិច្ច កម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ក្នុងការបំពេញការងារថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។

រាល់ការជួបជុំ ឬការប្រមូលផ្តុំមនុស្សដែលត្រូវបានអនុញ្ញាតដូចបានរៀបរាប់ខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចកិច្ចត្រូវអនុវត្តនូវវិធានការសុខាភិបាល ជាពិសេសការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្តៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ លើកលែងតែចំពោះការជួបជុំក្នុងចំណោមសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅឋានឬទីសំណាក់ជាមួយគ្នា។

**ប្រការ៥ ..**

រាល់ការធ្វើដំណើរដែលត្រូវបានអនុញ្ញាតដូចមានចែងក្នុងប្រការ២ នៃសេចក្តីសម្រេចនេះ មិនត្រូវធ្វើឡើងនៅចន្លោះពីម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) លើកលែងចំពោះការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់ មូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ, ការដឹកជញ្ជូនទំនិញ, ការបំពេញកាតព្វកិច្ចដែលបម្រើផលប្រយោជន៍សាធារណៈ, ការធ្វើដំណើរទៅនិងមកពីទីកន្លែងបំពេញការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន ឬទីតាំងអាជីវកម្មដែលត្រូវបានលើកលែងឱ្យបើកដំណើរការដូចមានចែងក្នុងកថាខណ្ឌខាងក្រោមនេះ និងករណីចាំបាច់ផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

រាល់គ្រឹះស្ថានសាធារណៈ សហគ្រាសឬគ្រឹះស្ថានឯកជន ឬទីតាំងអាជីវកម្មដែលត្រូវបានអនុញ្ញាតឱ្យនៅបើកដំណើរការស្របតាមប្រការ៣ នៃសេចក្តីសម្រេចនេះ ត្រូវផ្អាកប្រតិបត្តិការរបស់ខ្លួនចាប់ពីម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៥ (ប្រាំ) សម្រាប់ទទួលអតិថិជនដោយផ្ទាល់ លើកលែងចំពោះសេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល ឱសថស្ថាន ស្ថានីយ៍ប្រេងឥន្ធនៈ សេវាសណ្ឋាគារ និងផ្ទះសំណាក់ និងសេវាសាធារណៈចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរ មានសមត្ថកិច្ច។

ការធ្វើដំណើរចេញ-ចូលឆ្លងកាត់ព្រំប្រទល់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ត្រូវបានហាមឃាត់ លើកលែងតែការធ្វើដំណើរដើម្បីបំពេញមុខងារក្នុងការផ្តល់សេវាសង្គ្រោះបន្ទាន់ សេវាសាធារណៈចាំបាច់និងបន្ទាន់ សេវាពាក់ព័ន្ធនឹងការងារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ឬសេវាដឹកជញ្ជូនទំនិញ និងករណីចាំបាច់ផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ៦** ..

ត្រូវបានបង្កើតគណៈកម្មការជាតិគ្រប់គ្រងនិងដឹកនាំការអនុវត្តវិធានការបិទខ្ទប់ សរសេរជាអក្សរកាត់ថា "**គ.ប.ខ.**" ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** | រដ្ឋមន្ត្រីក្រសួងសុខាភិបាល | អនុប្រធាន |
| ៣-ឯកឧត្តម **កើត រិទ្ធ** | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤-ឯកឧត្តមនាយឧត្តមសេនីយ៍ **នាង ផាត** | រដ្ឋលេខាធិការប្រចាំការក្រសួងការពារជាតិ | អនុប្រធាន |
| ៥-ឯកឧត្តម **សក់ សេដ្ឋា** | រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៦-ឯកឧត្តម **ឃួង ស្រេង** | អភិបាលនៃគណៈអភិបាល រាជធានីភ្នំពេញ | អនុប្រធានអចិន្ត្រៃយ៍ |
| ៧-ឯកឧត្តម **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨-ឯកឧត្តម **វង សូត** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩-ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១០-ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១១-ឯកឧត្តម **អ៊ុំ ច បូររិទ្ធ** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១២-ឯកឧត្តម **ស្វាយ ស៊ីថា** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣-ឯកឧត្តម **អ៊ុក ប្រាជ្ញា** | រដ្ឋលេខាធិការប្រចាំការក្រសួងព័ត៌មាន | សមាជិក |

| | | |
|---|---|---|
| ១៤-ឯកឧត្តមនាយឧត្តមសេនីយ៍ **ខឹម្យ ពិសេន** | អគ្គមេបញ្ជាការនៃកងយោធពល ខេមរភូមិន្ទ | សមាជិក |
| ១៥-ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១៦-ឯកឧត្តមនាយឧត្តមសេនីយ៍ **ឥត សារ៉ាត់** | អគ្គមេបញ្ជាការរង និងជានាយសេនាធិការ ចម្រុះ នៃកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១៧-ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** | អគ្គមេបញ្ជាការរងនៃកងយោធពលខេមរ ភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក | សមាជិក |
| ១៨-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | អគ្គមេបញ្ជាការរងនៃកងយោធពល ខេមរភូមិន្ទ និងជាមេបញ្ជាការកង រាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៩-ឯកឧត្តម **គង់ សោភ័ណ្ឌ** | អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល | សមាជិក |

ក្នុងករណីចាំបាច់ ប្រធាន **គ.ប.ខ.** មានសិទ្ធិអញ្ជើញឥស្សរជនជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមប្រជុំ ឬផ្ដល់យោបល់តាមការចាំបាច់។

**គ.ប.ខ.** អាចមានអនុគណៈកម្មការមួយចំនួនតាមការចាំបាច់ ដែលត្រូវបង្កើតឡើងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធាន **គ.ប.ខ.**។

**គ.ប.ខ.** មានគណៈកម្មការប្រតិបត្តិមួយជាសេនាធិការទទួលបន្ទុកក្នុងការអនុវត្តវិធានការបិទខ្ទប់។

**ប្រការ៧** ..

គណៈកម្មការជាតិគ្រប់គ្រង និងដឹកនាំការអនុវត្តវិធានការបិទខ្ទប់ មានភារកិច្ច ដូចខាងក្រោម៖

- ដាក់ចេញនូវវិធានការលម្អិត ឬការណែនាំលម្អិតនានា សំដៅធានាដល់ប្រសិទ្ធភាពនៃការអនុវត្តវិធានការបិទខ្ទប់ និងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដែនដីដែលត្រូវបានបិទខ្ទប់ ក៏ដូចជាទប់ស្កាត់ជំងឺនេះមិនឱ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត
- ដាក់ចេញនូវគោលនយោបាយ និងវិធានការដើម្បីគាំពារ និងជួយសង្គ្រោះដល់ជនក្រីក្រ និងជនងាយរងគ្រោះក្នុងអំឡុងពេលបិទខ្ទប់
- ជួយគាំទ្រដល់គណៈកម្មការប្រតិបត្តិរបស់ **គ.ប.ខ.** ក្នុងការសម្របសម្រួលជាមួយក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធសំដៅធានាការអនុវត្តវិធានការបិទខ្ទប់ឱ្យបានរលូន និងមានប្រសិទ្ធភាព
- អនុវត្តនូវវិធានការចាំបាច់ផ្សេងទៀតតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល
- រាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាលអំពីលទ្ធផល និងបញ្ហាប្រឈមនានាក្នុងការអនុវត្តវិធានការបិទខ្ទប់។

**ប្រការ៨** ..

ត្រូវបានប្រគល់ភារកិច្ចជូនគណៈអភិបាលរាជធានីភ្នំពេញ និងគណៈអភិបាលខេត្តកណ្ដាល ដើម្បីធ្វើជាគណៈកម្មការប្រតិបត្តិដែលជាសេនាធិការឱ្យ **គ.ប.ខ.** ក្នុងការទទួលបន្ទុកអនុវត្តវិធានការបិទខ្ទប់ស្របតាមសេចក្ដីសម្រេចនេះ។ គណៈកម្មការប្រតិបត្តិនេះ ដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញទទួលបន្ទុករួម និងមានអភិបាលនៃគណៈអភិបាលខេត្តកណ្ដាលជាអនុប្រធានទទួលបន្ទុកការងារបិទខ្ទប់សម្រាប់ភូមិសាស្ត្រក្រុងតាខ្មៅ។

គណៈកម្មការប្រតិបត្តិនៃ **គ.ប.ខ.** មានសិទ្ធិបង្កើតក្រុមការងារមួយចំនួនតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តវិធានការបិទខ្ទប់ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន។ ក្រសួង ស្ថាប័ននានា ត្រូវចាត់បញ្ជូនតំណាងរបស់ខ្លួនដើម្បីដឹកនាំ និង/ឬចូលរួមក្នុងក្រុមការងារតាមការស្នើសុំរបស់ប្រធានគណៈកម្មការប្រតិបត្តិនៃ **គ.ប.ខ.** ក្នុងក្របខណ្ឌនៃសមត្ថកិច្ចជំនាញ និងការទទួលខុសត្រូវរបស់ខ្លួន ដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តវិធានការបិទខ្ទប់ និងការគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងដែនដីដែលត្រូវបានបិទខ្ទប់ ក៏ដូចជាទប់ស្កាត់ជំងឺនេះមិនឱ្យឆ្លងរាលដាលទៅតំបន់ផ្សេងទៀត។

គណៈកម្មការប្រតិបត្តិនៃ **គ.ប.ខ.** មានសិទ្ធិប្រើប្រាស់ត្រារបស់រដ្ឋបាលរាជធានីភ្នំពេញ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

**ប្រការ៩** ..

រាល់លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិធានការរដ្ឋបាលនានា ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលមានមុនពេលសេចក្តីសម្រេចនេះចូលជាធរមាន ហើយដែលមិនផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

**ប្រការ១០** ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១** ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២

## សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៥០សសរ, ស្តីពីការកែសម្រួលវិធានការ ដែលត្រូវអនុវត្តក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅ នៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩, ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥០ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការកែសម្រួលវិធានការដែលត្រូវអនុវត្តក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

- បានឃើញសេចក្តីសម្រេចលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩

## សម្រេច

**ប្រការមួយ .-**

វិធានការដែលត្រូវអនុវត្តក្នុងអំឡុងពេលបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ដូចមានចែងក្នុងប្រការ២ និងប្រការ៣ នៃសេចក្តីសម្រេចលេខ ៤៩ សសរ ចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ ២០២១ ស្តីពីការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ត្រូវបានកែសម្រួលដូចតទៅ៖

**ប្រការ២ .- ថ្មី**

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់នេះ បុគ្គលគ្រប់រូបត្រូវបានហាមឃាត់មិនឱ្យធ្វើដំណើរចេញពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្នរបស់ខ្លួន។ ក្នុងករណីមានការបំពានវិធានការហាមឃាត់ការធ្វើដំណើរនេះ អាជ្ញាធរអនុវត្តវិធានការបិទខ្ទប់ត្រូវអនុវត្តវិធានការច្បាប់យ៉ាងម៉ឺងម៉ាត់ ដោយរួមទាំងការឃាត់ទុកជាបណ្តោះអាសន្ននូវមធ្យោបាយធ្វើដំណើរ ដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីជាធរមាន។

ប៉ុន្តែ ការធ្វើដំណើរចេញក្រៅពីលំនៅឋាន ឬទីសំណាក់បច្ចុប្បន្ន អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- ការធ្វើដំណើរទៅប្រកបមុខរបរឬអាជីវកម្ម ឬបំពេញការងារក្នុងវិស័យឯកជន ដែលត្រូវបានអនុញ្ញាតដោយប្រការ៣ថ្មី នៃសេចក្តីសម្រេចនេះ នៅក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ដោយត្រូវមានលិខិតអនុញ្ញាតធ្វើដំណើរពីគណៈកម្មការប្រតិបត្តិនៃ **គ.ម.ខ.** អមដោយឯកសារសម្គាល់អត្តសញ្ញាណ និងលិខិតបញ្ជាក់ការងារដែលមានកំណត់ច្បាស់លាស់ពីឈ្មោះ មុខងារ និងប្រភេទអាជីវកម្មចេញដោយទីកន្លែងអាជីវកម្មពាក់ព័ន្ធ។ គណៈកម្មការប្រតិបត្តិនៃ **គ.ម.ខ.** ត្រូវចេញសេចក្តីណែនាំលម្អិតអំពីបែបបទនិងនីតិវិធីនៃការស្នើសុំ និងការផ្តល់លិខិតអនុញ្ញាតធ្វើដំណើរនេះ។
- ការធ្វើដំណើរទៅបំពេញការងារក្នុងក្រសួងស្ថាប័ន នៅក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ និងដោយមានភ្ជាប់ឯកសារសម្គាល់អត្តសញ្ញាណ និងលិខិតបញ្ជាបេសកកម្មរបស់ក្រសួងស្ថាប័នសាមី។
- ការធ្វើដំណើរទៅកាន់ទីកន្លែងលក់ម្ហូបអាហារ ឬគ្រឿងឧបភោគបរិភោគ ឱសថស្ថាន និងទីកន្លែងលក់សម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃដែលអនុញ្ញាតឱ្យបើកដំណើរការដោយអាជ្ញាធរមានសមត្ថកិច្ច។ ការធ្វើដំណើរក្នុងគោលបំណងនេះ អាចធ្វើឡើងដោយសមាជិកយ៉ាងច្រើន ២ (ពីរ) នាក់ ក្នុងមួយ

លំនៅឋានឬទីសំណាក់ ដោយមិនឱ្យលើសពី ៣(បី) ដង ក្នុងមួយសប្តាហ៍ និងនៅទីតាំងដែលជិតបំផុតក្នុងរង្វង់ភូមិសាស្ត្រក្រុង ឬខណ្ឌដែលខ្លួនរស់នៅ ដោយត្រូវយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬប័ណ្ណសម្គាល់ខ្លួន។

- ការធ្វើដំណើរទៅមន្ទីរពេទ្យ មណ្ឌលសុខភាព សម្ភព ឬទីកន្លែងព្យាបាល ដោយមូលហេតុសុខភាពបន្ទាន់ នៅក្នុងរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់។ ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់នេះ ចេញក្រៅឬចូលក្នុងរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ អាចធ្វើទៅបានដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់ ដោយកំណត់ចំនួនមនុស្សមិនឱ្យលើសពី ៤ (បួន) នាក់សម្រាប់ករណីនីមួយៗ ប៉ុន្តែត្រូវអនុវត្តដាច់ខាតនូវកាតព្វកិច្ចទាក់ទងនឹងវិធានការសុវត្ថិភាពផ្នែកសុខាភិបាល ជាពិសេសការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព។
- ការធ្វើដំណើរដើម្បីទៅបង្ហាញខ្លួនឱ្យមន្ត្រីសុខាភិបាលធ្វើការយកវត្ថុសំណាកទៅវិភាគរកមេរោគកូវីដ-១៩ នៅតាមទីតាំងតាមការកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។
- ការធ្វើដំណើរដើម្បីទៅទទួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី២ តាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច។ ចំពោះការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី១ នៅក្នុងភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ត្រូវបានផ្អាកជាបណ្ដោះអាសន្ននៅក្នុងអំឡុងពេលបិទខ្ទប់។
- ការធ្វើដំណើរដើម្បីចូលរួមក្នុងសកម្មភាពដែលបម្រើប្រយោជន៍សាធារណៈ ឬគោលបំណងចាំបាច់ផ្សេងទៀត តាមការស្នើសុំ ឬតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់។
- ការធ្វើសកម្មភាពកីឡាជាលក្ខណៈបុគ្គលនៅក្នុងលំនៅឋាន ឬទីសំណាក់របស់ខ្លួន ដោយមិនអនុញ្ញាតឱ្យធ្វើសកម្មភាពកីឡានេះនៅខាងក្រៅលំនៅឋាន ឬទីសំណាក់របស់ខ្លួនឡើយ។
- ការធ្វើដំណើររបស់ជនបរទេសដែលជាមន្ត្រីការទូត, មន្ត្រីបុគ្គលិកនៃស្ថានតំណាងបរទេស, ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដែលជាមន្ត្រីរបស់អង្គការហិរញ្ញវត្ថុអន្តរជាតិ ដោយមានភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងការងារ និងអាចអមដោយអ្នកបើកបររថយន្តជាជនជាតិខ្មែរ។
- ការធ្វើដំណើររបស់អ្នកសារព័ត៌មាន ដោយមានភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងការងារ ព្រមទាំងមានលិខិតអនុញ្ញាតសម្រាប់ការធ្វើដំណើរពីក្រសួងព័ត៌មាន។ ចំនួនបុគ្គលិករបស់អង្គភាពព័ត៌មាននីមួយៗ ត្រូវកាត់បន្ថយមកនៅត្រឹមកម្រិតអប្បបរមា សម្រាប់ទទួលការអនុញ្ញាតឱ្យធ្វើដំណើរដោយក្រសួងព័ត៌មាន។
- ការធ្វើដំណើរតាមផ្លូវអាកាស និងការធ្វើដំណើរទៅនិងមកពីអាកាសយានដ្ឋានក្នុងតំបន់បិទខ្ទប់ ដោយត្រូវគោរពតាមបទប្បញ្ញត្តិ និងវិធានការសុវត្ថិភាពផ្នែកសុខាភិបាលជាធរមាន និងត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណ ព្រមទាំងឯកសារពាក់ព័ន្ធនឹងការធ្វើដំណើរ និង
- ការធ្វើដំណើរដោយមូលហេតុចាំបាច់និងបន្ទាន់ផ្សេងទៀត ដោយមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់។

រាល់ការលើកលែងខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាល រួមមាន ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងប្រកាន់ខ្ជាប់នូវការផ្ញើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្ដៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

## **ប្រការ៣.-ថ្មី**

ក្នុងអំឡុងពេលនៃការអនុវត្តវិធានការបិទខ្ទប់ ត្រូវបានហាមឃាត់រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្មទាំងអស់ ដែលមិនមែនជាតម្រូវការចាំបាច់ប្រចាំថ្ងៃ។

ប៉ុន្តែ សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម អាចត្រូវបានអនុញ្ញាត ក្នុងករណីចាំបាច់ ដូចខាងក្រោម៖

- សកម្មភាពការងាររបស់ស្ថាប័នសាធារណៈ ប៉ុន្តែ ប្រធានស្ថាប័នសាមីត្រូវកាត់បន្ថយចំនួនអ្នកធ្វើការឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី ២% និងត្រូវអនុវត្តគោលការណ៍អាហារថ្ងៃត្រង់នៅហ្នឹងកន្លែងបំពេញការងារ ដើម្បីធានានិរន្តរភាពការងាររបស់ស្ថាប័ន។ ការធ្វើដំណើររបស់មន្ត្រីនៃស្ថាប័នសាធារណៈសម្រាប់គោលបំណងនេះ ត្រូវភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណ និងលិខិតបញ្ជាបេសកកម្មដែលចេញដោយស្ថាប័នសាមី។ ប្រធានស្ថាប័នសាមី ត្រូវសម្រេចផ្អាកការងារដែលមិនចាំបាច់ជាបណ្ដោះអាសន្នក្នុងអំឡុងពេលបិទខ្ទប់ និងត្រូវណែនាំតាមការជាក់ស្ដែង ដើម្បីអាចឱ្យមន្ត្រីបំពេញការងារពីចម្ងាយ ឬតាមរយៈប្រព័ន្ធអនឡាញ។
- សកម្មភាពការងាររបស់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងមន្ត្រីនិងបុគ្គលិកសុខាភិបាល ត្រូវដំណើរការស្របតាមការចាំបាច់ និងតាមការកំណត់របស់ប្រធានស្ថាប័ននីមួយៗ។
- រោងចក្រ សហគ្រាស សិប្បកម្ម ឬទីកន្លែងផលិតឱសថ និងសម្ភារៈបរិក្ខាពេទ្យ រួមទាំងម៉ាសអាកុល និងអុកស៊ីសែន។
- រោងចក្រ សហគ្រាស សិប្បកម្ម ឬទីកន្លែងផលិតម្ហូបអាហារនិងគ្រឿងឧបភោគបរិភោគ ដោយរួមទាំងទីសត្តឃាត ដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ។
- សកម្មភាពការងារដែលពាក់ព័ន្ធនឹងការផ្ដល់សេវាសាធារណៈ តាមការកំណត់របស់ស្ថាប័ននីមួយៗ ជាអាទិ៍ សេវាពន្លត់អគ្គិភ័យ, សេវាផ្គត់ផ្គង់អគ្គិសនី, សេវាទឹកស្អាត, សេវាកំពង់ផែ, សេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង ជាដើម។ ចំពោះសេវាផ្គត់ផ្គង់អគ្គិសនី, សេវាទឹកស្អាត និងសេវាកំពង់ផែ ប្រធានស្ថាប័នសាមីត្រូវកាត់បន្ថយចំនួនអ្នកធ្វើការនៅការិយាល័យឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី ២% និងត្រូវអនុវត្តគោលការណ៍អាហារថ្ងៃត្រង់នៅហ្នឹងកន្លែងបំពេញការងារ លើកលែងតែបុគ្គលិកឬមន្ត្រីទទួលបន្ទុកខាងផ្នែកប្រតិបត្តិការ និងសង្វាក់ផលិតកម្ម ដែលត្រូវបំពេញការងារជាប្រក្រតីធម្មតា។ ការធ្វើដំណើររបស់មន្ត្រី ឬបុគ្គលិកដើម្បីបម្រើឱ្យសេវាទាំងនេះ ត្រូវភ្ជាប់ជាមួយឯកសារបញ្ជាក់អត្តសញ្ញាណ និងលិខិតបញ្ជាបេសកកម្មដែលចេញដោយស្ថាប័នសាមី។

- រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្ម ដែលដំណើរការតាមរយៈប្រព័ន្ធអនឡាញ ដោយត្រូវកាត់បន្ថយចំនួនអ្នកធ្វើការឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី ២% និងត្រូវអនុវត្តគោលការណ៍អាហារថ្ងៃត្រង់នៅហ្នឹងកន្លែងបំពេញការងារ។
- ការផ្គត់ផ្គង់ទំនិញដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ ផ្សារលក់ដុំ ផ្សារឬទីតាំងលក់ដូរគ្រឿងឧបភោគបរិភោគដែលមានសណ្តាប់ធ្នាប់ ផ្សារម៉ាត និងភោជនីយដ្ឋាន-អាហារដ្ឋានដែលលក់ជាអាហារវេចខ្ចប់, ស្ថានីយ៍ប្រេងឥន្ធនៈ-ហ្គាស, ទីតាំងលក់ហ្គាស, ឬទីតាំងផ្គត់ផ្គង់ទំនិញដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។ ចំពោះផ្សារ ឬទីតាំងលក់ដូរគ្រឿងឧបភោគបរិភោគ ភោជនីយដ្ឋាន-អាហារដ្ឋាន អាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់ត្រូវធ្វើការត្រួតពិនិត្យ និងសម្រេចអនុញ្ញាត ទៅតាមការជាក់ស្តែងដោយផ្អែកទៅលើតម្រូវការចាំបាច់នៅក្នុងភូមិសាស្ត្ររបស់ខ្លួន។
- ការផ្គត់ផ្គង់សេវាដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ សេវាសង្គ្រោះបន្ទាន់ និងសេវាសុខាភិបាលទាំងរដ្ឋ និងឯកជន, ឱសថស្ថាន, សេវាប្រៃសណីយ៍-ទូរគមនាគមន៍, សេវាធនាគារ និងហិរញ្ញវត្ថុ និងសេវាដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ប៉ុន្តែ ត្រូវកាត់បន្ថយចំនួនបុគ្គលិកបម្រើការឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី ២% និងត្រូវអនុវត្តគោលការណ៍អាហារថ្ងៃត្រង់នៅហ្នឹងកន្លែងបំពេញការងារ លើកលែងតែសេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល និងឱសថស្ថាន ដែលត្រូវដំណើរការជាប្រក្រតីធម្មតា។
- សេវាកម្មសណ្ឋាគារ និងផ្ទះសំណាក់ ប៉ុន្តែ ត្រូវកាត់បន្ថយចំនួនបុគ្គលិកបម្រើការឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី ២% និងត្រូវអនុវត្តគោលការណ៍អាហារ និងការស្នាក់នៅនៅហ្នឹងកន្លែងបំពេញការងារ លើកលែងតែសណ្ឋាគារដែលបម្រើឱ្យការធ្វើចត្តាឡីស័ក ដែលចំនួនបុគ្គលិកអប្បបរមា និងពេលម៉ោងធ្វើការរបស់បុគ្គលិក ត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់។
- សេវាកម្មដឹកជញ្ជូនម្ហូបអាហារឬគ្រឿងឧបភោគបរិភោគ ដើម្បីបម្រើឱ្យភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់។ សកម្មភាពនៃការដឹកជញ្ជូននេះ មិនត្រូវបានអនុញ្ញាតឱ្យមានការដឹកជញ្ជូនមនុស្សឡើយ។
- សេវាកម្មដឹកជញ្ជូនទំនិញទូទៅចេញ-ចូល ឬឆ្លងកាត់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ដើម្បីបម្រើឱ្យវិស័យសង្គម-សេដ្ឋកិច្ចនៃប្រទេស។ សកម្មភាពនៃការដឹកជញ្ជូននេះ មិនត្រូវបានអនុញ្ញាតឱ្យមានការដឹកជញ្ជូនមនុស្សឡើយ។
- ចំពោះការគ្រប់គ្រង និងថែរក្សាឃ្លាំងស្តុកទំនិញ ឬគ្រឿងឧបភោគបរិភោគ ត្រូវបានអនុញ្ញាតឱ្យមានបុគ្គលិកប្រចាំការក្នុងចំនួនអប្បបរមា និងត្រូវអនុវត្តគោលការណ៍អាហារ និងការស្នាក់នៅនៅហ្នឹងកន្លែងបំពេញការងារ។
- ការដឹកជញ្ជូនបុគ្គលដែលបានបញ្ចប់ការធ្វើចត្តាឡីស័ក និងអ្នកជំងឺចេញពីមន្ទីរពេទ្យ ឬកន្លែងសម្រាកព្យាបាល ដោយមានការអនុញ្ញាត និងការសម្របសម្រួលរបស់អាជ្ញាធរមានសមត្ថកិច្ច និង

- សកម្មភាពការងារ មុខរបរ ឬអាជីវកម្មចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

រាល់សកម្មភាពការងារ មុខរបរ ឬអាជីវកម្មដែលត្រូវបានអនុញ្ញាតដូចបានរៀបរាប់ខាងលើ បុគ្គលគ្រប់រូបមានកាតព្វកិច្ចត្រូវអនុវត្តវិធានការសុខាភិបាល រួមមានការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្តៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសៅរ៍ ៤កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣

## សាលក្រមរដ្ឋប្បវេណីសាលាដំបូងរាជធានីភ្នំពេញ, លេខ៨២៩ «ម»

## ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ ៨២៩ "ម"
ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩។
-សំណុំរឿងរដ្ឋប្បវេណីលេខ១១៧៤
ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨។

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ៣០ នាទី រសៀល នៅសាលសវនាការទី៥។

**ចៅក្រមជំនុំជម្រះ**

លោក **ភួយ សៅ** ចៅក្រម និងជាអនុប្រធានសាលាដំបូង

**ក្រឡាបញ្ជី**

លោក **ផល សុភ័ក្ត្រ** ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ** ៖ ឈ្មោះ **ជ** ភេទប្រុស ជនជាតិជប៉ុន កាន់លិខិតឆ្លងដែនលេខ មានអាសយ ដ្ឋានបច្ចុប្បន្ននៅ Kyoto Japan។ មេធាវីតំណាងដោយអាណត្តិលោកមេធាវី **រស់ មុនិន្ទ** និងលោកស្រីមេធាវី **អម្រិត** មានការិយាល័យក្រុមមេធាវី ខេមឡ មានអាសយដ្ឋានអាគារស្កាស្ទ័រលេខ២៧២ ជាន់ទី២ មហាវិថីព្រះសីហនុ កែងនឹងផ្លូវលេខ១៤៣ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ចុងចម្លើយ** ៖ ឈ្មោះ **ច** ភេទប្រុស សញ្ជាតិខ្មែរ កាន់លិខិតឆ្លងដែនលេខ មានអាសយដ្ឋាន រាជធានីភ្នំពេញ។ មេធាវីតំណាងដោយអាណត្តិលោកមេធាវី **អ៊ីវ ប៉ូលី** មានការិយាល័យក្រុមមេធាវី ជេស៊ី ដែលមានអាសយដ្ឋាននៅអាគារផ្សារទំនើបបាយ័នជិតទីស្តីការគណៈរដ្ឋមន្ត្រី អាគារលេខ ៣៣-៣៤ ជាន់ទី៤ បន្ទប់ ៤០២A ផ្លូវ លេខ១១៤ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

### អង្គហេតុ និងចំណុចវិវាទ

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖

១. បង្គាប់ឲ្យចុងចម្លើយសងប្រាក់កម្ចីចំនួន ៥៣.៧៨២ ( ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបប្រាំពីរ) ដុល្លារអាមេរិក។

២. បង្គាប់ឲ្យចុងចម្លើយបង់ការប្រាក់ ៥ (ប្រាំ) ភាគរយ ក្នុងមួយឆ្នាំ តាមការកំណត់របស់ច្បាប់ ដោយគិតចាប់ពីថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១៨ រហូតដល់ពេលសងរួច។

៣. បង្គាប់ឲ្យចុងចម្លើយបង់ថ្លៃការខូចខាត សេវាកម្មច្បាប់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក។

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

## ខ. ដំណើររឿងក្តីដោយសង្ខេប ៖

កាលពីថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ចុងចម្លើយឈ្មោះ [redacted] បានចុះកិច្ចសន្យាខ្ចីប្រាក់ជាមួយដើមចោទចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក។ តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដដែលឈ្មោះ [redacted] បានសន្យាថានឹងសងប្រាក់ដែលបានខ្ចីមកដើមចោទវិញ ត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។ ការខ្ចីប្រាក់នេះធ្វើឡើងក្នុងគោលបំណងដើម្បីទទួលបានប្រាក់ជាទុនក្នុងការធ្វើកសិកម្ម ដែលនេះគឺជាអ្វីតែមួយគត់ដែលធ្វើឱ្យដើមចោទគិតថាឈ្មោះ [redacted] នឹងមានលទ្ធភាពសងប្រាក់កម្ចីខាងលើមកដើមចោទវិញ។ ប៉ុន្តែតាមរយៈការអនុវត្តកិច្ចសន្យានាពេលកន្លងមក ដើមចោទមានក្តីបារម្ភយ៉ាងខ្លាំង ចំពោះលទ្ធភាពនៃការអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនដែលក្តីបារម្ភនោះកើតឡើងដោយសារការមិនសហការល្អរបស់ឈ្មោះ [redacted] ដែលស្តែងឡើងតាមរយៈភាពមិនដំណើការក្នុងការធ្វើកសិកម្ម ព្រមទាំងភាពលំបាកក្នុងការទំនាក់ទំនងផ្តល់ និងទទួលព័ត៌មានអំពីបច្ចុប្បន្នភាពនៃគម្រោងធ្វើកសិកម្ម ក៏ដូចជាការធ្លាក់ចុះនូវស្ថានភាពហិរញ្ញវត្ថុរបស់ចុងចម្លើយ។ ជាមួយនឹងក្តីបារម្ភនេះដែរ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ ដើមចោទបានធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឈ្មោះ [redacted] អំពីការជូនដំណឹងអំពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ខាងលើ នោះ ក្នុងគោលបំណងទទួលបានមកវិញនូវការធ្វើបដិទានលើប្រាក់កម្ចីចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ប៉ុន្តែមិនត្រូវបានឈ្មោះ [redacted] អនុវត្តតាមឡើយ។ ក្រោយមក ដើមចោទបានព្យាយាមជូនដំណឹងជាច្រើនសារទៀតទៅឈ្មោះ [redacted] ប៉ុន្តែឈ្មោះ [redacted] បដិសេធមិនទទួលយកការជូនដំណឹងទាំងនោះ ហើយក៏មិនព្រមសងទឹកប្រាក់កម្ចីទាំងនោះទោះបីជាកិច្ចសន្យាខ្ចីប្រាក់ខាងលើត្រូវបានរំលាយហើយក៏ដោយ។

## គ. ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ ៖

១. តាមរយៈកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ឈ្មោះ [redacted] បានខ្ចីប្រាក់ចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ពីឈ្មោះ [redacted] ។ តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដដែលឈ្មោះ [redacted] បានសន្យាថានឹងសងប្រាក់ដែលបានខ្ចី មកកូនក្តីរបស់យើងខ្ញុំវិញត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។ សូមបញ្ជាក់ផងដែរថាការខ្ចីប្រាក់ របស់ឈ្មោះ [redacted] ធ្វើឡើងក្នុងគោលបំណងដើម្បីទទួលបានប្រាក់ជាទុនក្នុងការធ្វើកសិកម្ម ដែលនេះគឺជាអ្វីតែមួយគត់ដែលធ្វើឱ្យកូនក្តីយើងខ្ញុំជឿជាក់ថាឈ្មោះ [redacted] នឹងមានលទ្ធភាពសងប្រាក់កម្ចីខាងលើមកវិញ។

២. ប៉ុន្តែតាមរយៈការអនុវត្តកិច្ចសន្យានាពេលកន្លងមក កូនក្តីយើងខ្ញុំមានក្តីបារម្ភយ៉ាងខ្លាំង ចំពោះលទ្ធភាពនៃការអនុវត្តសិទ្ធិលើបំណុលរបស់គាត់ ដែលក្តីបារម្ភនោះកើតឡើងដោយសារការមិនសហការល្អរបស់លោក [redacted] ដែលស្តែងឡើងតាមរយៈភាពមិនដំណើការក្នុងការធ្វើកសិកម្ម ព្រមទាំងភាពលំបាកក្នុងការទំនាក់ទំនងផ្តល់ និងទទួលព័ត៌មានអំពីបច្ចុប្បន្នភាពនៃគម្រោងធ្វើកសិកម្ម ក៏ដូចជាការធ្លាក់ចុះនូវស្ថានភាពហិរញ្ញវត្ថុរបស់ចុងចម្លើយរូបនេះផងដែរ។

៣. ជាមួយនឹងក្តីបារម្ភនេះកាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ យើងខ្ញុំបានធ្វើការជូនដំណឹងជាលាយ លក្ខណ៍អក្សរទៅលោក [redacted] អំពីការជូនដំណឹងអំពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ខាងលើ នោះ ក្នុងគោលបំណងទទួលបានមកវិញនូវការធ្វើបដិទានលើប្រាក់កម្ចីចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបី ពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ប៉ុន្តែមិនត្រូវបានលោក [redacted] អនុវត្តតាមឡើយ។

៤. ក្រោយមក យើងបានព្យាយាមជូនដំណឹងជាច្រើនសារទៀតទៅលោក ច ប៉ុន្តែលោក ច បដិសេធមិនទទួលយកការជូនដំណឹងទាំងនោះ ហើយក៏មិនព្រមសងទឹកប្រាក់កម្ចីទាំងនោះ ទោះបីជាកិច្ចសន្យាខ្ចីប្រាក់ខាងលើត្រូវបានរំលាយហើយក៏ដោយ។

## ឃ. ការអះអាងរបស់មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ ៖

១. ចំពោះចំណុចទី១ សូមធ្វើការច្រានចោលការទាមទាររបស់ដើមចោទ និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

២. កាទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុដែលអះអាងដោយដើមចោទ

ទី១. អង្គហេតុស្តីពីការចុះកិច្ចសន្យាខ្ចីប្រាក់ ត្រង់ចំណុចវ៉ូម៉ាំង ២.១ នៃពាក្យបណ្តឹងរបស់ដើមចោទ ចុងចម្លើយមិនទទួលស្គាល់។

ទី២. អង្គហេតុស្តីពីការអនុវត្តសិទ្ធិលើបំណុល ត្រង់វ៉ូម៉ាំង ២.២ នៃពាក្យបណ្តឹងរបស់ដើមចោទ ចុងចម្លើយមិនទទួលស្គាល់។

ទី៣. អង្គហេតុស្តីពីការជូនដំណឹងអំពីការរំលាយកិច្ចសន្យា ចុងចម្លើយមិនបានដឹងនោះទេ។

ទី៤. ការជូនដំណឹងជាបន្តន្ទាប់ត្រង់វ៉ូម៉ាំង ២.៤ ចុងចម្លើយមិនបានដឹងនោះទេ។

៣. ការពន្យល់អំពីទំនាក់ទំនងនៃអង្គហេតុ ដើមចោទបានអះអាងថា ចុងចម្លើយបានខ្ចីប្រាក់ចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ដោយកំណត់ពេលសងនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយគ្មានការប្រាក់ ការទាមទារនេះមិនទាន់មានមូលដ្ឋានតាមផ្លូវច្បាប់នោះទេ ដោយហេតុថា ប្រសិនបើអង្គហេតុនេះ ជាអង្គហេតុខ្ចីប្រាក់ គប្បីតាក់តែងជាលិខិតខ្ចីប្រាក់ ដោយកំណត់អំពីការប្រាក់ គោលបំណងនៃការខ្ចី រយៈពេលនៃការខ្ចី ហើយមានលិខិតប្រាគល់ទទួលប្រាក់កម្ចីនោះផងដែរ។ មួយវិញទៀតប្រសិនបើអង្គហេតុនោះ ជាអង្គហេតុខ្ចីប្រាក់មែន ក៏ប្រាក់កម្ចីនោះមិនទាន់ដល់ការកំណត់សងផងដែរ ផ្អែកតាមមាត្រា ៥៧៨ និងមាត្រា ៥៩១ នៃក្រមរដ្ឋប្បវេណី

សំណូមពរ ចុងចម្លើយស្នើសុំបញ្ចូលសំណុំរឿងរដ្ឋប្បវេណីលេខ ១១៧៣ និងលេខ ១១៧៤ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ ជាសំណុំរឿងតែមួយ ដោយហេតុថា សំណុំរឿងទាំងពីរខាងលើនេះ គឺមានអង្គហេតុនៃការទាមទារតែមួយ ហើយក៏កើតឡើងនូវការបរិច្ឆេតតែមួយផងដែរ។ មួយវិញទៀតខ្លឹមសារនៃការទាមទារ គឺជាការទាមទារប្រាក់ដូចគ្នា ដោយមានចុងចម្លើយតែម្នាក់គត់។ លើសពីនេះទៅទៀត សំណុំរឿងទាំងពីរខាងលើនេះ មានអង្គហេតុ ភាគីពាក់ព័ន្ធ និងខ្លឹមសារនៃការទាមទារ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ផ្អែកតាមមាត្រា ៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ង. សេចក្តីថ្លែងការណ៍តបរបស់មេធាវីតំណាងឲ្យអាណត្តិរបស់ដើមចោទ ៖

១. ទាក់ទងទៅនឹងខ្លឹមសារនៃសាលក្រម នាងខ្ញុំសូមធ្វើការបដិសេធ នូវការលើកឡើងរបស់មេធាវី តំណាងឲ្យចុងចម្លើយ និងសូមរក្សានូវខ្លឹមសារនៃសាលក្រម ដែលបានទាមដូចមានក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ ដដែល។

២. ទាក់ទងទៅនឹងអង្គហេតុ ដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុដែលបញ្ជាក់នៃការទាមទារ

២.១. ពាក់ព័ន្ធទៅនិងការលើកទើរងរបស់មេធាវីចុងចម៉េយ មិនទទូលស្គាល់កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ រវាងលោក ច ពីលោក ង ជាការលើកឡើងដែលផ្ទុយពីការពិត ដោយហេតុថា ពិតជាមានការខ្ចីប្រាក់ចំនន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ដោយឈ្មោះ ច ពីលោក ង ពិតប្រាកដមែន។ ទោះបីជាទំរង់នៃកិច្ចសន្យាខ្ចីប្រាក់នេះ ធ្វើឡើងជាភាសាបរទេស និងពុំមានចែងលំអិតអំពីចំណុចផ្សេងៗ ដូចកិច្ចសន្យាខ្ចីប្រាក់ទូទៅក្តី ក៏ប៉ុន្តែគូភាគីទាំងពីរបានបង្ហាញឆន្ទៈច្បាស់លាស់ក្នុងការចុះកិច្ចសន្យាខ្ចីប្រាក់ជាមួយគ្នា។ នៅក្នុងកិច្ចសន្យា

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគំរូទេ

ប្រាក់នេះ បានកំណត់អំពីប្រាក់ដើមដែលបានខ្ចី និងរយៈពេលនៃការសងប្រាក់ ការបរិច្ឆេតនៃការចុះកិច្ចសន្យា អត្តសញ្ញាណរបស់ភូភាគី ហើយនិងមានការផ្តិតស្នាមមេដៃ និងចុះហត្ថលេខា ដោយគូភាគីផងដែរ យោង តាមមាត្រា៣១១ កិច្ចសន្យា គឺកើតចេញពីឆន្ទៈព្រមគ្នារបស់គូភាគី ក្នុងការបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច។ ហេតុដូច្នេះកិច្ចសន្យាខ្ចីប្រាក់ I OWE YOU NOTE ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ គឺពិតជាកិច្ចសន្យាដែលកើត ចេញពីឆន្ទៈភូភាគី និងគ្មានការក្លែងបន្លំឡើយ។

២.២. ពាក់ព័ន្ធទៅនិងការអនុវត្តសិទ្ធិលើបំណុល នាងខ្ញុំសូមធ្វើការបដិសេធ ចំពោះកាលើកឡើងរបស់មេធាវី តំណាងឱ្យចុងចម្លើយ ពីព្រោះការមិនទទួលស្គាល់អំពីសិទ្ធិលើបំណុល គឺជាការគេចវេះពីការអនុវត្តកាតព្វ កិច្ចរបស់កូនបំណុលតែប៉ុណ្ណោះ។

២.៣. ពាក់ព័ន្ធទៅនិងការមិនបានទទួលការជូនដំណឹង នាងខ្ញុំសូមធ្វើការបដិសេធ ចំពោះកាលើកឡើងរបស់មេធាវី តំណាងឱ្យចុងចម្លើយ ដោយហេតុថា លិខិតជូនដំណឹងថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ អំពីការរំលាយកិច្ចសន្យា ខ្ចីប្រាក់ទាំងពីរ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ជាមួយលោក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ ២០១៥ ជាមួយលោក គឺបានផ្ញើជូនទៅចុងចម្លើយហើយ ចុងចម្លើយបានចុះហត្ថ លេខាទទួល នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨ ម្យ៉ាងទៀត ទាក់ទងទៅនឹងការជូនដំណឹងជាបន្តបន្ទាប់ទៀត ចុងចម្លើយសុទ្ធតែបានដឹង ហើយចុងចម្លើយបានព្យាយាមទាក់ទងតាមទូរស័ព្ទមក មេធាវីតំណាងដើមបណ្តឹង ផងដែរ នេះជាហេតុមួយដែលសបញ្ជាក់ឱ្យឃើញថា ចុងចម្លើយបានដឹងអំពីការជូនដំណឹងស្តីពីការរំលាយ កិច្ចសន្យាខ្ចីប្រាក់ ហើយអនុភាពនៃការរំលាយកិច្ចសន្យា ក៏បានកើតឡើងតាំងពីពេលនោះរួចមកហើយដែរ។ យើងអាចសន្និដ្ឋានបានថា ចុងចម្លើយមានចេតនាគេចវេះក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ទោះជាខ្លួនធ្លាប់ ទទួលស្គាល់ថា ខ្លួនបានទទួលប្រាក់គ្រប់ចំនួន ដែលខ្លួនបានខ្ចីពីដើមបណ្តឹងពិតមែនក៏ដោយ។

ពាក់ព័ន្ធទៅនឹងការសំណើរសុំបញ្ចូលសំណុំរឿងរដ្ឋប្បវេណីលេខ ១១៧៣ និងលេខ ១១៧៤ ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៨ ជាសំណុំរឿងតែមួយនោះ នាងខ្ញុំមិនមានការជំទាស់នោះទេ។ សំណូមពរស្នើសុំឱ្យ តុលាការចេញសាលក្រមដូចការទាមទារ។

## ច. ចំណុចវិវាទៈ

១. តើកិច្ចសន្យាខ្ចីប្រាក់នេះ មានអត្ថិភាព និងសុពលភាពដែរឬទេ?

២. តើមានការជូនដំណឹង និងទំនាក់ទំនងជាបន្តបន្ទាប់ ពីលិខិតជូនដំណឹងស្តីពីការរំលាយកិច្ចសន្យាដែរឬទេ?

## សំអាងហេតុ

១. តុលាការពិនិត្យឃើញថា សំណុំរឿងរដ្ឋប្បវេណីលេខ ១១៧៤ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៨ មានលក្ខណៈត្រឹមត្រូវ តាមទម្រង់ និងគតិច្បាប់។ ដូច្នេះតុលាការអាចលើកយករឿងនេះមកចាត់ការតាមនីតិវិធីបាន ស្របតាមមាត្រា៧ មាត្រា ៨ មាត្រា៩ និងមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២. ឃើញថាអ្នកតំណាងដោយអាណត្តិរបស់ដើមចោទ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញ ហេតុផលដោយផ្ទាល់មាត់ បានអះអាង និងស្នើសុំឱ្យតុលាការចេញសាលក្រមដូចមានក្នុងខ្លឹមសារនៃពាក្យបណ្តឹងដូច ខាងក្រោម ៖

១. បង្គាប់ឲ្យចុងចម្លើយសងប្រាក់កម្ចីចំនួន ៥៣.៧៨២ ( ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបប្រាំពីរ) ដុល្លារអាមេរិក។

២. បង្គាប់ឲ្យចុងចម្លើយបង់ការប្រាក់ ៥ (ប្រាំ) ភាគរយ ក្នុងមួយឆ្នាំ តាមការកំណត់របស់ច្បាប់ ដោយគិតចាត់ពីថ្ងៃទី ០២ ខែមីនា ឆ្នាំ២០១៨ រហូតដល់ពេលសងរួច។

៣. បង្គាប់ឲ្យចុងចម្លើយបង់ថ្លៃការខូចខាត សេវាកម្មច្បាប់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក។

អង្គហេតុដែលជាមូលហេតុនៃការទាមទារ តាមរយៈកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ឈ្មោះ ម បានខ្ចីប្រាក់ចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ពីឈ្មោះ ង ។ តាមរយៈកិច្ចសន្យាខ្ចីប្រាក់ដដែលឈ្មោះ ម បានសន្យាថានឹងសងប្រាក់ដែលបានខ្ចីមកកូនក្តីរបស់ខ្លួនវិញត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។ ការខ្ចីប្រាក់របស់ឈ្មោះ ម ធ្វើឡើងក្នុងគោលបំណងដើម្បីទទួលបានប្រាក់ជាទុនក្នុងការធ្វើកសិកម្ម ដែលនេះគឺជាអ្វីតែមួយគត់ដែលធ្វើឲ្យកូនក្តីខ្លួនជឿជាក់ថាឈ្មោះ ម នឹងមានលទ្ធភាពសងប្រាក់កម្ចីខាងលើមកវិញ។

ប៉ុន្តែតាមរយៈការអនុវត្តកិច្ចសន្យានាពេលកន្លងមក កូនក្តីខ្លួនមានក្តីបារម្ភយ៉ាងខ្លាំង ចំពោះលទ្ធភាពនៃការអនុវត្តសិទ្ធិលើបំណុលរបស់គាត់ ដែលក្តីបារម្ភនោះកើតឡើងដោយសារការមិនសហការល្អរបស់លោក ម ដែលស្តែងឡើងតាមរយៈភាពមិនដំណើការក្នុងការធ្វើកសិកម្ម ព្រមទាំងភាពលំបាកក្នុងការទំនាក់ទំនងផ្តល់ និងទទួលព័ត៌មានអំពីបច្ចុប្បន្នភាពនៃគម្រោងធ្វើកសិកម្ម ក៏ដូចជាការធ្លាក់ចុះនូវស្ថានភាពហិរញ្ញវត្ថុរបស់ចុងចម្លើយផងដែរ។

ជាមួយនឹងក្តីបារម្ភនេះ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ ខ្លួនបានធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅលោក ម អំពីការជូនដំណឹងអំពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ខាងលើនោះ ក្នុងគោលបំណងទទួលបានមកវិញនូវការផ្ទេរបដិទានលើប្រាក់កម្ចីចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លារអាមេរិក ប៉ុន្តែមិនត្រូវបានលោក ម អនុវត្តតាមឡើយ។

ក្រោយមកខ្លួនបានព្យាយាមជូនដំណឹងជាច្រើនសារទៀតទៅលោក ម ប៉ុន្តែលោក ម បដិសេធមិនទទួលយកការជូនដំណឹងទាំងនោះ ហើយក៏មិនព្រមសងទឹកប្រាក់កម្ចីទាំងនោះ ទោះបីជាកិច្ចសន្យាខ្ចីប្រាក់ខាងលើត្រូវបានរំលាយហើយក៏ដោយ។

ពាក់ព័ន្ធទៅនិងការលើកឡើងរបស់មេធាវីចុងចម្លើយ មិនទទួលស្គាល់កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ រវាងលោក ម ពីលោក ង ជាការលើកឡើងដែលផ្ទុយពីការពិត ដោយហេតុថាពិតជាមានការខ្ចីប្រាក់ចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ដោយឈ្មោះ ម ពីលោក ង ពិតប្រាកដមែន។ ទោះបីជាទំរង់នៃកិច្ចសន្យាខ្ចីប្រាក់នេះ ធ្វើឡើងជាភាសាបរទេស និងពុំមានចែង លំអិតអំពីចំណុចផ្សេងៗ ដូចកិច្ចសន្យាខ្ចីប្រាក់ទូទៅក្តី ក៏ប៉ុន្តែគូភាគីទាំងពីរបានបង្ហាញឆន្ទៈច្បាស់លាស់ក្នុងការចុះកិច្ចសន្យាខ្ចីប្រាក់ជាមួយគ្នា។ នៅក្នុងកិច្ចសន្យាខ្ចីប្រាក់នេះ បានកំណត់អំពីប្រាក់ដើមដែលបានខ្ចី និងរយៈពេលនៃការសងប្រាក់ ការបរិច្ឆេតនៃការចុះកិច្ចសន្យាអត្តសញ្ញាណរបស់ភូភាគី ហើយនិងមានការផ្តិតស្នាមមេដៃ និងចុះហត្ថលេខាដោយគូភាគី ផងដែរ យោងតាមមាត្រា៣១១ កិច្ចសន្យា គឺកើតចេញពីឆន្ទៈព្រមគ្នារបស់គូភាគី ក្នុងការបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច។ ហេតុដូច្នេះកិច្ចសន្យាខ្ចីប្រាក់ I OWE YOU NOTE ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ គឺពិតជាកិច្ចសន្យាដែលកើតចេញពីឆន្ទៈ ភូភាគី និងគ្មានការក្លែងបន្លំឡើយ។

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

ពាក់ព័ន្ធទៅនិងការអនុវត្តសិទ្ធិលើបំណុល ខ្លួនសូមធ្វើការបដិសេធ ចំពោះកាលើកឡើងរបស់មេធាវី តំណាងឲ្យចុងចម្លើយ ពីព្រោះការមិនទទួលស្គាល់អំពីសិទ្ធិលើបំណុល គឺជាការគេចវេះពីការអនុវត្តកាតព្វ កិច្ចរបស់កូនបំណុលតែប៉ុណ្ណោះ។

ពាក់ព័ន្ធទៅនិងការមិនបានទទួលការជូនដំណឹង ខ្លួនសូមធ្វើការបដិសេធ ចំពោះកាលើកឡើងរបស់មេធាវីតំណាងឲ្យចុងចម្លើយ ដោយហេតុថា លិខិតជូនដំណឹងថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ អំពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ទាំងពីរ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ជាមួយលោក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ជាមួយលោក គឺបានផ្ញើជូនទៅចុងចម្លើយហើយ ចុងចម្លើយបានចុះហត្ថលេខាទទួល នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨ ម្យ៉ាងទៀតទាក់ទងទៅនឹងការជូនដំណឹងជាបន្តបន្ទាប់ទៀត ចុងចម្លើយសុទ្ធតែបានដឹង ហើយចុងចម្លើយបានព្យាយាមទាក់ទងតាមទូរស័ព្ទមកមេធាវីតំណាងដើមបណ្តឹងផងដែរ នេះជាហេតុមួយដែលសបញ្ជាក់ឲ្យឃើញថា ចុងចម្លើយបានដឹងអំពីការជូនដំណឹងស្តីពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ ហើយអនុភាពនៃការរំលាយកិច្ចសន្យា ក៏បានកើតឡើងតាំងពីពេលនោះរួចមកហើយដែរ។ ខ្លួនអាចសន្និដ្ឋានបានថា ចុងចម្លើយមានចេតនាគេចវេះក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ទោះជាខ្លួនធ្លាប់ទទួលស្គាល់ថាខ្លួនបានទទួលប្រាក់គ្រប់ចំនួន ដែលខ្លួនបានខ្ចីពីដើមបណ្តឹងពិតមែនក៏ដោយ។

៣. ឃើញថាអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ បានអះអាងថា ៖

១. ចំពោះចំណុចទី១ សូមធ្វើការច្រានចោលការទាមទាររបស់ដើមចោទ និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

២. ការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុដែលអះអាងដោយដើមចោទ

ទី១. អង្គហេតុស្តីពីការចុះកិច្ចសន្យាខ្ចីប្រាក់ ត្រង់ចំណុចរ៉ូម៉ាំង ២.១ នៃពាក្យបណ្តឹងរបស់ដើមចោទ ចុងចម្លើយមិនទទួលស្គាល់។

ទី២. អង្គហេតុស្តីពីការអនុវត្តសិទ្ធិលើបំណុល ត្រង់រ៉ូម៉ាំង ២.២ នៃពាក្យបណ្តឹងរបស់ដើមចោទ ចុងចម្លើយមិនទទួលស្គាល់។

ទី៣. អង្គហេតុស្តីពីការជូនដំណឹងអំពីការរំលាយកិច្ចសន្យា ចុងចម្លើយមិនបានដឹងនោះទេ។

ទី៤. ការជូនដំណឹងជាបន្តន្ទាប់ត្រង់រ៉ូម៉ាំង ២.៤ ចុងចម្លើយមិនបានដឹងនោះទេ។

៣. ការពន្យល់អំពីទំនាក់ទំនងនៃអង្គហេតុ ដើមចោទបានអះអាងថា ចុងចម្លើយបានខ្ចីប្រាក់ចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លាអាមេរិក ដោយកំណត់ពេលសងនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយគ្មានការប្រាក់ ការទាមទារនេះមិនទាន់មានមូលដ្ឋានតាមផ្លូវច្បាប់នោះទេ ដោយហេតុថា ប្រសិនបើអង្គហេតុនេះ ជាអង្គហេតុខ្ចីប្រាក់ គប្បីតាក់តែងជាលិខិតខ្ចីប្រាក់ ដោយកំណត់អំពីការប្រាក់ គោលបំណងនៃការខ្ចី រយៈពេលនៃការខ្ចី ហើយមានលិខិតប្រគល់ទទួលប្រាក់កម្ចីនោះផងដែរ។ មួយវិញទៀតប្រសិនបើអង្គហេតុនោះ ជាអង្គហេតុខ្ចីប្រាក់មែន ក៏ប្រាក់កម្ចីនោះមិនទាន់ដល់ការកំណត់សងផងដែរ ផ្អែកតាមមាត្រា ៥៧៨ និងមាត្រា ៥៩១ នៃក្រមរដ្ឋប្បវេណី។

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

៤. ឃើញថា ភាគីដើមចោទបានអះអាងថា ចុងចម្លើយពិតជាបានខ្ចីប្រាក់ខ្លួនចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយ ប៉ែតសិបពីរ) ដុល្លារអាមេរិក នោះ តុលាការបានរកឃើញថា ចុងចម្លើយពិតជាបានខ្ចីប្រាក់ពីដើមចោទពិតប្រាកដមែន ពីព្រោះថា ដើមចោទ និងចុងចម្លើយ បានធ្វើកិច្ចសន្យាខ្ចីប្រាក់ និងទទួលប្រាក់ ដូចមាននៅក្នុងលិខិតមួយដែលបាន សរសេរថា " I OWE YOU NOTE " ។ នៅក្នុងលិខិតនេះមានខ្លឹមសារគ្រប់គ្រាន់ ដែលបញ្ជាក់ថា អ្នកឱ្យខ្ចីប្រាក់ (Lender) ឈ្មោះ ដ និងអ្នកខ្ចីប្រាក់ (Borrower) ឈ្មោះ ច ហើយដែលចុងចម្លើយបាន ទទួលប្រាក់កម្ចីចំនួន ៥៣.៧៨២ (ប្រាំម៉ឺនបីពាន់ប្រាំពីររយ ប៉ែតសិបពីរ) ដុល្លារអាមេរិក។ ដូចនេះ តុលាការយល់ ឃើញថា ទម្រង់លិខិត " I OWE YOU NOTE " ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥ ពិតជាលិខិតកិច្ចសន្យាខ្ចីប្រាក់ ដែលគូភាគី ទាំងពីរ មានឆន្ទៈ ពិតប្រាកដ ដោយដើមចោទឱ្យខ្ចីប្រាក់ ហើយចុងចម្លើយទទួលយកប្រាក់កម្ចី។

៥. ឃើញថា អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានធ្វើសេចក្តីអះអាងថា ទោះបីជាចុងចម្លើយបានខ្ចីប្រាក់ពី ដើមចោទក៏ដោយ ក៏កាលបរិច្ឆេទនៃការសងក៏មិនទាន់មកដល់ដែរ គឺនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ ឯណោះ។ ត្រង់ ចំណុចការអះអាងនេះ តុលាការយល់ឃើញថា ជាអះអាងមិនមានមូលដ្ឋានឡើយ ពីព្រោះថា ចុងចម្លើយបានខ្ចីប្រាក់ពី ដើមចោទនេះទៅប្រកបមុខរបរដាំម្រុំ។ ប៉ុន្តែ អាជីវកម្មនេះជាក់ស្តែងឃើញថា មិនដំណើរការរីកចម្រើនទៅមុខឡើយ ហើយធ្វើឱ្យមានហានិភ័យខ្ពស់ ដែលចុងចម្លើយពិតជាមិនអាចសងប្រាក់កម្ចីត្រឡប់ទៅឱ្យដើមចោទវិញបានឡើយ ដូច ដែលដើមចោទបានអះអាងដូចខាងលើនេះ។ ដូច្នេះ ដើមចោទមានសិទ្ធិរំលាយកិច្ចសន្យា និងទាមទារប្រាក់កម្ចីមកវិញ ដោយមិនរង់ចាំដល់ពេលកំណត់សងឡើយ ស្របទៅតាមក្រមរដ្ឋប្បវេណី។

៦. ឃើញថា អ្នកតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានធ្វើសេចក្តីអះអាងថា ចុងចម្លើយមិនបានទទួលដំណឹងពីការ រំលាយកិច្ចសន្យាឡើយ។ ត្រង់អង្គហេតុនេះ តុលាការរកឃើញថា ចុងចម្លើយ ពិតជាបានទទួលការជូនដំណឹងពីការ រំលាយកិច្ចសន្យាកម្ចីប្រាក់ ដែលដើមចោទបានជូនដំណឹង ដូចមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹង ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ អំពីការរំលាយកិច្ចសន្យាខ្ចីប្រាក់ ហើយចុងចម្លើយពិតជាបានទទួលដំណឹងនេះ នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨ ដោយចុងចម្លើយបានចុះហត្ថលេខាទទួលលិខិតជូនដំណឹងនេះ។ ជាងនេះទៅទៀតតុលាការរកឃើញថា ចុងចម្លើយ បានទទួលដំណឹងអំពីការរំលាយកិច្ចសន្យាកម្ចីនេះ ជាបន្តបន្ទាប់ក្រោយៗមកទៀត។

៧. ឃើញថាដើមចោទបានទាមទារឱ្យចុងចម្លើយបង់ការប្រាក់ ៥ (ប្រាំ) ភាគរយ ក្នុងមួយឆ្នាំ តាមការកំណត់របស់ច្បាប់ ដោយគិតចាត់ពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៨ រហូតដល់ពេលសងរួច។ ត្រង់ចំណុចនៃការទាមទារនេះ តុលាការពិនិត្យ ឃើញថា នៅក្នុងកិច្ចសន្យាកម្ចីប្រាក់នោះ គឺមិនបានចែងអំពីបង់ការប្រាក់នោះទេ។ ម្យ៉ាងទៀត តុលាការរកឃើញថា នៅពេលដែលធ្វើកិច្ចសន្យានោះ គូភាគីទាំងពីរគ្មានចេតនា និងឆន្ទៈ ពិតប្រាកដណាមួយយោងទៅដល់បង់ការប្រាក់នោះ ទេ។ ដូច្នេះ តុលាការគួតប្បីច្រានចោលការទាមទាររបស់ដើមចោទ។

៨. ឃើញថាតាមការអះអាង និងការទាមទាររបស់ដើមចោទ ដែលបានទាមទារឱ្យចុងចម្លើយបង់ថ្លៃការខូចខាត សេវាកម្ម ច្បាប់ចំនួន ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក។ ចំពោះចំណុចនេះ តុលាការពិនិត្យ នឹងសម្រេចតាមអង្គហេតុ អង្គច្បាប់ និងការខូចខាតជាក់ស្តែង ដែលកើតមានឡើង។

៨. ឃើញថាចំពោះដើមចោទបានទាមទារឲ្យតុលាការប្រកាសសាលក្រមនេះ អនុវត្តជាបណ្តោះអាសន្ននោះ តុលាការគប្បីច្រានចោលការទាមទារនេះ ដោយតុលាការយល់ឃើញថា ជៀសវាងភាពស្មុគស្មាញ នៃការធ្វើបដិទានឡើងវិញដែលអាចកើតឡើងនៅពេលក្រោយ។

## សេចក្តីសម្រេចបញ្ចប់

១. បង្គាប់ឲ្យចុងចម្លើយឈ្មោះ ច សងប្រាក់កម្ចីចំនួន ៥៣.៧៨២ (ហ្រាំម៉ឺនបីពាន់ប្រាំពីររយប៉ែតសិបពីរ) ដុល្លារអាមេរិក ឲ្យទៅដើមចោទឈ្មោះ ដ ។

២. ច្រានចោលការទាមទារ បង់ការប្រាក់ចំនួន ០៥ (ប្រាំ) ភាគរយ ក្នុងមួយឆ្នាំ របស់ដើមចោទ។

៣. បង្គាប់ឲ្យចុងចម្លើយឈ្មោះ ច បង់ថ្លៃសំណងការខូចខាតចំនួន ២.០០០.០០០ (ពីរលាន) រៀល ឲ្យទៅដើមចោទឈ្មោះ ដ ។ ការទាមទារលើសពីនេះច្រានចោល។

៤. ច្រានចោលការទាមទាររបស់ដើមចោទ ដែលសុំការប្រកាសសាលក្រមនេះ អនុវត្តជាបណ្តោះអាសន្ន។

៥. ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខអ្នកតំណាងដោយអាណត្តិរបស់ដើមចោទ និងចុងចម្លើយ។

ថ្ងៃព្រហស្បតិ៍ ០៣កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩
**ចៅក្រម**
ហត្ថលេខា និងត្រា ៖ **កួយ សៅ**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ០៣កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៩
**ក្រឡាបញ្ជី**

បានឃើញ
**ចៅក្រម**

កួយ សៅ

ផល សុភ័ក្ត្រ

កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

# ឧបសម្ព័ន្ធទី៤

## *សេចក្តីអំពាវនាវរបស់រដ្ឋបាលរាជធានីភ្នំពេញ,គ្មានលេខ,ស្តីពីការផ្ទុះរីករាលដាល នៃមេរោគកូវីដ១៩ ក្នុងព្រឹត្តិការណ៍«សហគមន៍ ២០កុម្ភៈ» នៅរាជធានីភ្នំពេញ,*

## ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ

លេខ:........✓..................

ថ្ងៃសុក្រ ១៣កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី..២៦..ខែមីនា ឆ្នាំ២០២១

### សេចក្តីអំពាវនាវ

ការផ្ទុះរីករាលដាលនៃមេរោគកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ «សហគមន៍ ២០ កុម្ភៈ» នៅរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១ រហូតមកទល់បច្ចុប្បន្ននេះបានធ្វើឱ្យបងប្អូនប្រជាពលរដ្ឋមួយចំនួនបានទទួលរងផលប៉ះពាល់ខ្លាំង ក្នុងនោះអ្នកជួលផ្ទះ ឬជួលបន្ទប់ កំពុងជួបការលំបាកក្នុងការបង់ថ្លៃឈ្នួលផ្ទះ ឬឈ្នួលបន្ទប់ផងដែរ។

ក្នុងន័យនេះ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល និងរដ្ឋបាលរាជធានីភ្នំពេញក្នុងការគិតគូរ និងជួយទ្រទ្រង់ជីវភាពរបស់បងប្អូនប្រជាពលរដ្ឋដែលកំពុងស្នាក់នៅផ្ទះជួល ឬបន្ទប់ជួលនោះ រដ្ឋបាលរាជធានីភ្នំពេញសូមអំពាវនាវដល់អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ដែលជាម្ចាស់ផ្ទះជួល ឬបន្ទប់ជួលទាំងអស់ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដូចខាងក្រោម៖

១. ពិនិត្យលទ្ធភាពបញ្ចុះតម្លៃ ឬលើកលែងការបង់ថ្លៃឈ្នួលផ្ទះ ឬឈ្នួលបន្ទប់ ក្នុងអំឡុងពេលនៃការផ្ទុះព្រឹត្តិការណ៍ «សហគមន៍២០កុម្ភៈ» នេះ រហូតដល់ស្ថានភាពនៃការរីករាលដាលមេរោគកូវីដ-១៩ មានសភាពធូរស្រាលឡើងវិញ។

២. យោគយល់អធ្យាស្រ័យចំពោះការយឺតយ៉ាវក្នុងការបង់ថ្លៃឈ្នួលផ្ទះ ឬឈ្នួលបន្ទប់ពីសំណាក់អ្នកជួលទាំងឡាយ ដោយគួរលើកលែងការពិន័យឱ្យបង់ប្រាក់បន្ថែម ឬដកយកប្រាក់កក់ចំពោះការយឺតយ៉ាវក្នុងការបង់ប្រាក់ថ្លៃឈ្នួល និងបន្តអនុញ្ញាតឱ្យពួកគាត់ស្នាក់នៅបន្តទៅទៀត ដោយមិនគួរបណ្តេញពួកគាត់ចេញឡើយ។

រដ្ឋបាលរាជធានីភ្នំពេញមានក្តីសង្ឃឹមទុកជាមុនថា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ដែលជាម្ចាស់ផ្ទះជួល ឬបន្ទប់ជួលទាំងអស់ នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីអំពាវនាវនេះ ដោយស្មារតីយោគយល់អធ្យាស្រ័យខ្ពស់ និងឈរលើស្មារតីសាមគ្គីជាតិជាធ្លុងមួយ ជាក់ជាមិនខាន។

**អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**